បកដោយពិត

សុវណ្ណមាលិកចេតិយ នៅ កោះសិរីលង្កា

បើចង់បានពេកជាប់ចំណងស្អិត លោកនេះងងឹតមិនជិតសូន្យឈឹង

មិនឃើញផ្លូវចន្ទពុំមានទីពឹង ម្តេចមិនខំប្រឹងនាំគ្នាសិក្សា ។

រៀបរៀងដោយ :

ឧបាសក នា-សុខា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

មកដោយពិត

ឆ្នាំជូត សំរឹទ្ធិស័ក ព.ស.២៥៥២

រៀបរៀងដោយ

ឧបាសក នា សុខា

បានស្កានឡើងវិញសម្រាប់ជាធម្មទាន
ដែលបានអនុញ្ញាតដោយ ឧបាសក នា សុខា

Scan by:

www.5000-years.org

ចំណារ

សម្ដេចព្រះមហាសុមេធាធិបតី
បានពិនិត្យសព្វគ្រប់លើស្នាដៃមនោរម្យ
ពិសេសមានក្នុងសៀវភៅ "មកពីណា"
របស់ឧបាសក ងា ស៊ាម បានសម្រួល
ប្រែចេញណាស់ ក្នុងការលើកបញ្ហាឡើង
សម្ដែងទៅតាមគាថាព្រះពុទ្ធភាសិត
ហើយយកមកពន្យល់ប្រយោជន៍ផ្សេងៗ
ឃើញ ដល់ស្ពានសិក្សា · ប្រតិបត្តិ មាន
សន្តិភាព ភាវនាល្អៗ គួរយល់ និងចិត្តៗ

សូមអនុមោទនាសាធុការពីរ ដោយ
ព្រះធម៌ក្នុងចិត្តប្រើនប្រយោជន៍ របស់
ឧបាសក ពិសេសមានប្រយោជន៍ធំណាស់
ត្រូវតាមសិក្ខាបទព្រះពុទ្ធ នេះ ។

វត្តបទុមវតី ថ្ងៃ៥ ៧ ៣ ២៥៥២ / ២០០៨

សម្ដេចព្រះសង្ឃនាយក

នន់ ង៉ែត

មកដោយពិត

បើចង់បានពេកជាប់ចំណាងស្និត លោកនេះងងឹតបិទជិតសូន្យឈឹង

មិនឃើញផ្លូងចន្ទពុំមានទីពឹង ម្តេចមិនខំប្រឹងនាំគ្នាសិក្សា ។

ឆ្នាំជូត សំរឹទ្ធិស័ក ព.ស.២៥៥២

រៀបរៀងដោយ :

ឧបាសក ឆា-សុខា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលដោយ

១-**ភិក្ខុព្រះមហាឧត្តមវីរិយោ ហ៊ុំ សុន្ធា** ជាសមណនិស្សិតនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ

២-**ឧបាសក ជាំ-កុយ** ផ្នែកខាងអក្សរសាស្ត្រខ្មែរ

៣-**ឧបាសក រី-ស្រ៊ាង** ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រ និងវប្បធម៌ខ្មែរ

បញ្ជីមាតិកាធម៌

ល.រៀង	លំដាប់មាតិកា	ទំព័រ
1	ខ្លឹមសារនៃជីវិត	01
2	មេរៀនសម្រាប់យុវវ័យ (កំណាព្យ)	09
3	បុណ្យចម្រើនព្រះជន្ម	12
4	បណ្តាំគ្រូ (កំណាព្យ)	24
5	ការពិចារណារកការពិត	27
6	ពុទ្ធចរិយា	32
7	សេចក្តីពិស្តារព្រះនាមឈ្មោះតថាគត	36
8	សុខសន្តិភាព	44
9	អត្ថន័យរបស់ពាក្យពិត	48
10	សេចក្តីពិតក្នុងការនិយាយស្តី	52
11	សេចក្តីពិតក្នុងសម្មតិសច្ចៈ	56
12	សេចក្តីពិស្តាររបស់បុគ្គលបញ្ញត្តិ	61
13	សេចក្តីពិតក្នុងបរមត្ថសច្ចៈ	66
14	សេចក្តីពិតក្នុងសភាវសច្ចៈ	75
15	សេចក្តីពិតក្នុងវិរតិសច្ចៈ	83

16	សេចក្តីពិតក្នុងញាណសច្ចៈ	96
17	សេចក្តីពិតក្នុងអរិយសច្ចៈ និងនិព្វានសច្ចៈ	106
18	សតិប្បដ្ឋាន (ជំហានទី ៦)	112
19	មេរៀនជីវិត (កំណាព្យ)	127
20	សំយោគមតិ	131
21	បទពិចារណា	142
22	អំពីលក្ខណាទិចតុក្កៈ	146

អារម្ភកថា

ការសិក្សាស្រាវជ្រាវ តាមផ្លូវលោកនិងផ្លូវព្រះធម៌ ដើម្បីស្វែងរកនូវសេចក្តីសុខស្ងប់ពិត ប៉ុន្តែសេចក្តីសុខដែលយើងត្រូវការប្រាថ្នា មិនចេះបានជួបសោះ ព្រោះប្រព្រឹត្តកម្មមិនត្រូវទំនងថែមទាំង ពុំស្គាល់នូវសភាវធម៌ច្បាស់លាស់ទៀតផង ។

ការពុំបានយល់ជ្រាបពីសភាវពិតរបស់ធម្មជាតិ បណ្តាលឱ្យលោកអន្ទះអន្ទែងស្ទុះស្ទា ប្រៀបដូចសត្វជាប់នៅក្នុងទ្រុងរកកន្លែងចេញមិនរួច ខ្វល់ខ្វាយមិនស្រាកស្រាន្ត ចូលចិត្តរត់រកជំនឿផ្សេងៗ តាមលទ្ធិសាសនាដទៃដែលជាហេតុនាំមកនូវគ្រោះថ្នាក់ច្រើនប្រការ ។

ប្រសិនបើមិនបានសិក្សាពីវិជ្ជាព្រះពុទ្ធសាសនា នឹងមិនអាចដឹងការពិត ព្រោះសេចក្តីសុខស្ងប់ កើតចេញពីការបានជួបនូវការមកដោយពិតរបស់ធម្មៈគឺសច្ចធម៌ដែលព្រះពុទ្ធអង្គ បានត្រាស់ដឹង រួចលើកយកមកសម្តែងមានព្រះអានន្ទជាពុទ្ធុបដ្ឋាក និងជាពហុស្សូតចេះចាំនូវព្រះពុទ្ធវចនៈយ៉ាងច្រើនក្រៃលែង ។

តទៅនេះ នឹងបង្ហាញជូននូវចំណុចពិតខ្លះៗរបស់ពុទ្ធៈ ដែលខ្ញុំបាន ដកស្រង់ប្រមូលរៀបរៀងចងក្រងធ្វើជាសៀវភៅមួយមានចំណងជើងថា "**មកដោយពិត**" ទុកជាកំណប់ទ្រព្យក្នុងព្រះពុទ្ធសាសនា ដើម្បីជាពន្លឺដល់ពុទ្ធបរិស័ទគ្រប់ៗគ្នា ដែលមានសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈ ។

សូមឧទ្ទិសនូវមហាកុសលនេះ ជូនដល់បុព្វការីជន មានមាតាបិតាជាដើម និងសូមគោរពជូនលោកគ្រូអគ្គបណ្ឌិតជាម្ចាស់ ព្រមទាំងញាតិសាច់សាលោហិតនិងធម្មមិត្ត ទុកជាចំណែកបុណ្យជួយរុញច្រានឱ្យរួចផុតចាកទុក្ខទាំងពួង ។

សូមមេត្តាជួយកែសម្រួលដោយសេចក្តីរីករាយ

រាជធានីភ្នំពេញ

ថ្ងៃ ១០ រោច ខែ អាសាឍ

ឆ្នាំជូត សំរឹទ្ធិស័ក ព.ស.២៥៥២

រៀបរៀងដោយ

ឧបាសក នា សុខា

ខ្លឹមសារនៃជីវិត

មកដោយពិត បង្ហាញប្រាប់ផ្លូវត្រូវត្រង់ដល់មហាជនដែលកំពុងដេកលក់នៅក្នុងស្រោមអវិជ្ជាថា :

មនុស្សយើង មានជាតិមកហើយក៏មិនគួរប្រាថ្នាចង់បាននូវអ្វីៗច្រើនហួសកម្រិតពេក ព្រោះរបស់ទាំងនោះមិនជាសារៈសំខាន់សម្រាប់ជួយជ្រោមជ្រែងជីវិត ឱ្យមានសោភណភាពប្រសើរឧត្តុង្គឧត្តម ឬជាមធ្យោបាយល្អប្រសើរ នាំឱ្យបានរួចផុតចាកទុក្ខគ្រាន់តែជាសម្បកខាងក្រៅសម្រាប់បច្ច័យ ៤ ដល់ជីវភាពរស់នៅក្នុងការជួយទំនុកបម្រុង ឬជាឧបការៈដល់ សីល សមាធិ បញ្ញាប៉ុណ្ណោះ ។ ឯការពិតដែលព្រះពុទ្ធអង្គទ្រង់ដឹកនាំសត្វឱ្យឆ្លងផុតពីវដ្តសង្សារ ដោយគុណធម៌បានដល់ សេចក្តីល្អគ្រប់យ៉ាងរបស់ចិត្តក្នុងមហាកុសល ៨ ដួង មានបញ្ញាជាដើមដែលត្រូវអប់រំ បន្ទុំបារមី យ៉ាងខ្លាំងក្លា ទើបស្វែងរកសុខស្ងប់បាន ។

ការមានទ្រព្យសម្បត្តិ ជាកត្តាមួយរបស់លោកប្រកប ដោយកិលេស តណ្ហា ទិដ្ឋិ មានះ និងមិនអាចថាមិនមានមិនបាន ប៉ុន្តែយើងក៏ត្រូវចេះពិចារណាថា មនុស្សយើងកើតមក ពុំមានអ្វីយកមកជាមួយ មានតែកម្មជ្ជរូបនិងលោកិយវិបាក។ លុះដល់ស្លាប់ទៅវិញ ក៏មិនបានយកទ្រព្យសម្បត្តិទាំងនោះ ដែលខ្លួនខំស្វែងរកដោយអំពើល្អខ្លះ អំពើអាក្រក់ខ្លះទៅជាមួយ មានតែចិត្តសន្សំប្រមូលនូវកម្មសនិងកម្មខ្មៅជាប់តាម បើពោលឱ្យលើសពីនេះ បានសេចក្តីថា ស្លាប់ទៅគ្មានបានយកអ្វីទៅជាមួយ គឺទទេស្អាត ចំណែកទ្រព្យសម្បត្តិនៅសល់ទាំងប៉ុន្មាន ដែលពុំទាន់បានចាត់ចែងធ្វើទានឬបានធ្វើខ្លះៗ ត្រូវបន្សល់ទុកឱ្យកូនចៅ ទទួលកេរមរតកបន្ត។ ដូច្នោះមនុស្សយើង លុះស្លាប់ទៅក៏ទទេពិតប្រាកដជាក់ស្តែងមែន ព្រោះហេតុនោះបានជា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់នូវព្រះគាថា ***សព្វេ ធម្មា នាលំ អភិនិវេសាយាតិ*** ប្រែថា: ធម៌ទាំងឡាយទាំងពួង មិនគួរ ប្រកាន់ថាជារបស់មាំមួនដោយមិនប្រកាន់អ្វីៗក្នុងលោក ទោះបរិក្ខារ ឬសម្ភារទាំងឡាយ មិនមានចិត្តវិញ្ញាណ ឬមានវិញ្ញាណ ដូចជា មនុស្សសត្វ ទ្រព្យសម្បត្តិជាដើម ក៏មិនគួរប្រកាន់ ចាប់យកមកធ្វើជារបស់ខ្លួន តាមការប្រកាន់ ៣ យ៉ាងដែរ :

១- **ឯតំ មម** នុះជារបស់អញ (តួតណ្ហា)

២- **ឯសោ ហមស្មិ** នុះជាអញ (តួមានះ)

៣- **ឯសោ មេអត្តាតិ** នុះជាខ្លួនរបស់អញ (តួទិដ្ឋិ) ។

តាមការពិត សង្ខារទាំងឡាយ តាក់តែងឡើងពីហេតុប្បច្ច័យ ពុំមានអ្នកណាម្នាក់ធ្វើឱ្យកើតមានឡើយ ប្រៀបដូច កំណាត់ឈើមួយដុំដែលអណ្តែតតាមចរន្តទឹក ក៏ចេះតែអណ្តែតទៅៗ តាមហេតុរបស់វា ឬកំណាត់ឈើនេះ គេចាប់គ្រវែងចោលទៅក្នុងលំហអាកាស រួចត្រូវធ្លាក់ចុះតាមទំនាញស្រូប របស់ចលនាអាកាសធាតុផែនដី ជួនធ្លាក់មកខាងគល់មុន ឬខាងចុងមុន ឬចំកណ្តាល ស្រេចហើយនៅលើរឿងហេតុប្បច្ច័យ ។ កំណាត់ឈើ ប្រៀបដូចសង្ខារទាំងឡាយកើតឡើងតាមរឿងរ៉ាវរបស់វា ពុំមានអ្នកណាមួយមានអំណាច មកហាមឃាត់រារាំង ឬទប់ស្កាត់ ឬចាប់ទាញ ប៉ះពាល់ដោយប្រការយ៉ាងណានីមួយ ធ្វើឱ្យទ្រឹង ឬឋិតថេរចិរកាលរៀងរហូតគ្មានព្រំដែន ឈប់សម្រាកឱ្យនៅស្ងៀម តែងកើតឡើងហើយ ត្រូវរលត់ទៅវិញជាធម្មតា ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើមានអ្នកណាម្នាក់ ប្រើឫទ្ធិអំណាចទៅប្រកាន់ដោយវចីកម្មនិងមនោកម្ម នូវរបស់ទាំងនោះ គឺ

សង្ខារនេះ ធ្វើមិនឱ្យមានការប្រែប្រួលផ្លាស់ប្តូរ នូវរបស់ទាំងនេះ ឬសង្ខារទាំងឡាយទាំងពួង អាចឈប់នៅស្ងៀមមួយកន្លែង ទៀងទាត់ប្រាកដ ព្រោះមានខ្លួនយើងទៅប្រព្រឹត្តស្ទាប ចាប់ ប៉ះពាល់ ឬប្រកាន់នូវរបស់ទាំងនោះ ដោយ **សេចក្តីត្រេកអរ រីករាយ** ថា មានខ្លួនជាអ្នកចាត់ចែងរៀបចំលោក ឱ្យមានសុខទុក្ខ ឬមិនសុខមិនទុក្ខ (អទុក្ខមសុខ) តាមកម្លាំងតណ្ហា ដឹកនាំ ដែលជាកត្តាធ្វើឱ្យលោកមានភាពទៀងទាត់ឋិតថេរ ដោយ សក្កាយទិដ្ឋិ ថាសត្វស្លាប់ទៅទៀង មានខ្លួនជាអ្នកទៅកើតទៀត ព្រោះជាប់សេចក្តីប្រកាន់ នូវសង្ខារទាំងនោះ គឺ **រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ** ដូចដែលព្រះសាស្តា ទ្រង់ត្រាស់សម្តែង នៅក្នុង សំយុត្តនិកាយ ខន្ធវារវគ្គ បិដកភាគ ៣៨/១០៣ ថា ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះ អាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគភ៌មិនសម្រាលបុត្រ ព្រះចន្ទ ព្រះអាទិត្យមិនរះមិនលិច តាំងនៅនឹងដដែលដូចជាសសរខឿន ។ កាលបើវេទនាមាន ។បេ។ កាលបើសញ្ញាមាន ។ កាលបើ សង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យ នូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា

ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគតិមិនសម្រាលបុត្រ ព្រះចន្ទ ព្រះអាទិត្យមិនរះមិនលិច តាំងនៅនឹងដដែលដូចជាសសរខឿន ។

សេចក្តីនេះមានយ៉ាងណា ប្រសិនបើសង្ខារទាំងពួងមានពិតប្រាកដដូចយ៉ាងនោះមែន លោកនេះ និយាមធម្មជាតិ អាស្រ័យ ហេតុប្បច្ច័យនិងធាតុទាំងឡាយ មាន ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ អាកាសធាតុនិងវិញ្ញាណធាតុទាំងនោះ ឋិតថេរទៀងទាត់ពុំមានអ្វីកើត ពុំមានអ្វីរលត់ ធ្វើឱ្យតម្រូវការនូវអ្វីផ្សេងៗ និងការស្រេកឃ្លានរបស់សត្វទាំងឡាយក៏ពុំមានដែរ តែមិនដូច្នោះទេ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវធម្មទេសនា បន្តទៀត ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិកើតឡើងយ៉ាងនេះថា ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្រីមានគតិមិនសម្រាលបុត្ត ព្រះចន្ទ ព្រះអាទិត្យមិនរះមិនលិច តាំងនៅនិងដដែល ដូចជាសសរខឿនដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ វេទនាទៀង

ឬមិនទៀង ។ បេ ។ សញ្ញា ។ សង្ខារទាំងឡាយទៀង ឬមិនទៀង ។បេ។ វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខព្រះអង្គ ។ ចុះរបស់មិនទៀងជាទុក្ខមានសភាពប្រែប្រួលទៅ បើមិនអាស្រ័យនូវរបស់នោះទេ តើគួរមានទិដ្ឋិយ៉ាងនេះថា «ខ្យល់មិនបក់ ស្ទឹងមិនហូរ ស្ត្រីមានគភ៌មិនសម្រាលបុត្រ ព្រះចន្ទនិងព្រះអាទិត្យមិនរះមិនលិច តាំងនៅនឹងដដែល ដូចជាសសរខឿនដែរឬទេ មិនដូច្នេះទេ ព្រះអង្គ» ។

សភាពពិតទាំងនេះ នៅត្រង់ការមាន សតិសម្បជញ្ញៈ ឃើញសង្ខារធម៌ទាំងឡាយ គឺ ខន្ធ ធាតុ អាយតនៈ មានការវិនាសប្រែប្រួលជាធម្មតា ពុំចាំបាច់ត្រូវការអ្វីទាំងអស់ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងប្រាប់នូវធម្មជាតិទាំងនោះ តាមសេចក្តីពិតធ្វើឱ្យសត្វលោកចេះពិចារណាដោះស្រាយខ្លួនឯង ក្នុងការរកច្រកផ្លូវចេញពីលោកដោយបញ្ញា មិនដូចអ្នកខ្លះ យល់ថា មនុស្សយើងកើតមកហើយរួចស្លាប់ទៅវិញពុំឃើញ មានអ្វីប្លែកជាងនេះ។ ការណ៍នេះ យើងគួរជួយអាណិតអាសូរគ្នា ព្រមទាំង មានមេត្តាចិត្តកើតឡើងដល់សព្វសត្វទូទៅ ក្នុងបំណងជួយប្រាប់ផ្លូវដល់អ្នកវង្វេង ដែលមួយថ្ងៃទៅមួយថ្ងៃ សន្សំតែសេចក្តីទុក្ខ យកមក

ដាក់ក្នុងខ្លួន ព្រោះពុំបានដឹងថា មនុស្សយើងមិនមែន មាន ត្រឹមតែរឿងមួយប៉ុណ្ណោះ អាចមានមធ្យោបាយល្អៗយ៉ាងឯក កាលណាបើបានទៅសេពគប់ជាមួយអ្នកប្រាជ្ញបណ្ឌិត ក៏បាន ដឹងថា ផ្លូវល្អប្រពៃគឺសេចក្ដីសុខស្ងប់មានមែន នៅចំផ្លូវកណ្ដាល ក្នុងការបដិបត្តិតាមឱវាទានុសាសនីរបស់ព្រះពុទ្ធអង្គ ដែលក្នុង សម័យបច្ចុប្បន្ន រវាងមនុស្សអាយុក្រោម ១០០ ឆ្នាំចុះ ជាសម័យ យ៉ាងកម្សត់ក្រៃលែង តែអាចនៅមានព្រះធម៌សម្រាប់ដឹកនាំសត្វ ចេញចាកភព ។ របស់ក្រមិនដែលមានច្រើន ជារបស់មានតិច ឬ មានត្រឹមតែមួយដងមួយគ្រា យ៉ាងណា ការកើតឡើងនៃព្រះពុទ្ធ ទាំងឡាយ ពុំមានច្រើន មានតែមួយអង្គម្ដង នៃការត្រាស់ ដឹងធម៌ ព្រោះជានិយាមធម្មជាតិ ។

ដូច្នោះ ជីវិតត្រូវតែរៀបចំឱ្យមានភាពថ្លៃថ្នូរឧត្តុង្គឧត្ដម ប្រសើរឡើង សម្រាប់ជួយជ្រោមជ្រែងខ្លួនឯងនិងអ្នកដទៃ ដែល រស់នៅជុំវិញឱ្យបានសុខគ្រប់ៗគ្នា។ ជីវិតមនុស្សយើង មាន តម្លៃខ្លាំងណាស់ ត្រូវចេះតស៊ូអត់ទ្រាំ ព្រោះកើតពីបុណ្យដោយ កុសលវិបាក ចំណែកពួកសត្វតិរច្ឆានកើតឡើង ដោយអកុសល វិបាកបដិសន្ធិ ដែលយើងគួរណាស់សាងសន្សំបុណ្យតទៅទៀត

កុំសាងអំពើបាបនាំឱ្យជីវិតធ្លាក់ទៅកន្លែងថោកទាប **សុខោ បុញ្ញស្ស ឧច្ចយោ** ប្រែថា : ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ព្រមទាំងទទួលយកបាននូវធម៌ ៧ ប្រការ បានដល់ សទ្ធា សីល ហិរិ ឧត្តប្បៈ សុតៈ ចាគៈ បញ្ញា របស់ជីវិតដែលមានការអប់រំចិត្ត ដោយសតិប្បដ្ឋានវិបស្សនា សំដៅពួកធម៌ត្រាស់ដឹងមាន រូបធម៌នាមធម៌ជា អារម្មណ៍ ធ្វើឱ្យកម្ចាត់បង់នូវកិលេសជាខណៈ។ ទើបជីវិត **មកដោយពិត** មានសារៈខ្លឹមសារ ។

ការចូលដល់ រូបធម៌នាមធម៌ ដោយការកំណត់ដឹងមិនមែនចាប់ផ្តើមរៀនសូត្រ ស្តាប់ធម៌ត្រឹមមួយអត្តភាពនេះទេ ព្រោះធ្លាប់ស្តាប់ច្រើនជាតិ ឬ រាប់កប្បយូរមកហើយ ទើបអាចធ្វើឱ្យមានបញ្ញាយល់ជ្រួតជ្រាប នូវសភាវធម៌យ៉ាងល្អិតសុខុមជាឫសគល់នៃបច្ច័យុប្បន្នធម៌ទាំងឡាយ ដែលមានត្រឹមតែហេតុប្បច្ច័យមិនអាចគណនាបាន ។ កាលណាគេបានដឹងរបស់ពិតដោយពុទ្ធៈ ធ្វើឱ្យមាន ស្មារតីអាចរំដោះខ្លួនចេញចាកលោក ។

លក្ខណាទិចតុក្កៈ របស់ មេត្តា

១- **ហិតាការប្បវត្តិលក្ខណា** : មានការប្រព្រឹត្តទៅ ដើម្បីជួយសម្រួល នូវប្រយោជន៍ជាសុខដល់សត្វទាំងឡាយ ជាលក្ខណៈ

២- **ហិតូបសំហារសា** : មានការនាំសេចក្ដីសុខទាំងឡាយដល់សត្វ ជាកិច្ច

៣- **អាឃាតវិនយបច្ចុប្បដ្ឋានា** :មានការកម្ចាត់អាឃាត គឺ សេចក្ដីក្រោធ ជាផល

៤- **មនាបភាវទស្សនបទដ្ឋានា** : មានការពិចារណាដល់សេចក្ដីល្អពេញចិត្ត របស់សត្វ ជាបទដ្ឋាន ។

មេរៀនសម្រាប់យុវវ័យ

✦ សិស្សតូចសិស្សធំ សូមមកជួបជុំ ស្ដាប់គ្រូពន្យល់
វិជ្ជាទាំងឡាយ យកចិត្តរវល់ ត្រិះរិះឱ្យស្គាល់
នូវសេចក្ដីពិត ។

✦ មេរៀនប្លែកៗ កុំអាលប្រកែក ពិចារណាគិត
បើមិនទាន់ច្បាស់ ខិតចូលឱ្យជិត សួរហើយពិនិត្យ
ផ្ទៀងត្រចៀកស្ដាប់ ។

✦ បើរៀនបានល្អ ហុចផលមិនក្រ អាចសម្រេចឆាប់
រស់នៅបច្ចុប្បន្ន ឃើញមិនទាន់ស្លាប់ ផលតាមលំដាប់
ឧបត្ថម្ភនាមកាយ ។

✦ បើអ្នកមិនខ្ជិល ចេះមើលរមិល ដល់គុណទាំងឡាយ
ត្រៃសរណគមន៍ គុណជិតមិនឆ្ងាយ អ្នកនឹងសប្បាយ
សុខសួគ៌ទេវលោក ។

✦ កូនរៀនចេះដឹង ជួនមិនសូវប្រឹង ផលហួរស្រោចជោគ
បុណ្យពីអតីត ចូលមកប្រឡូក រុញដល់លើគោក
មិនឱ្យខ្សត់ខ្សោយ ។

✦ ម្យ៉ាងទៀតឪផ្តាំ កូនកត់ចំណាំ ស្តាប់ឱ្យញឹកញយ
ពាក្យប្រៀនប្រដៅ អ្នកកុំរាថយ ប្រាជ្ញាកើតដោយ
ប្រតិបត្តិត្រូវ ។

✦ កុំចូលចិត្តគេង ក្រោកហើយដើរលេង សប្បាយតាមផ្លូវ
ស្រីស្រាល្បែងរាំ ចោកទាបកុំសូវ ចូរកូនដើរទៅ
ទីណាថ្លៃថ្នូរ ។

✦ បើកូនរាប់អាន សាច់ញាតិសន្ដាន កុំភ្លេចធ្វើទាន
អានិសង្សច្រើន ទុកគ្រាន់ជាស្ពាន សត្រូវមិនហ៊ាន
បៀតបៀនកូនឡើយ ។

✦ សំខាន់មានមិត្ត ស្រឡាញ់ជិតស្និទ្ធ ផ្ដេកផ្ដិតកៀកកើយ
ជួយរក្សាគ្នា បន្ទួរទុក្ខស្បើយ មិនទាន់ដល់ត្រើយ
ក៏គង់ស្រាកខ្លះ ។

✦ ទៅណាមកណា ប្រយ័ត្នហេតុការណ៍ កើតឡើងជាក់ច្បាស់
ផលវិបាកកម្ម ហុចឱ្យមិនខ្វាស ព្រះទ្រង់បានត្រាស់
ប្រាប់ការពិតកូន ។

✦ បើគប់មិត្តខុស បុណ្យសក្ដិធ្លាក់ចុះ រហូតដល់សូន្យ
អំពើលាមក អាប់ដល់បងប្អូន ដូចកូនក្រៅស្បូន
មិនសូវគ្រប់ទឹក ។

✦ បើកូនរៀនចេះ កុំធ្វេសប្រហែស ចង់ក្រាញនៅស្ពឹក
ស្រូតដល់ការពិត បើញញឹដុះស្លឹក ចេញផ្កាលែងនឹក
ត្រឡប់ក្រោយវិញ ។

បុណ្យចម្រើនព្រះជន្ម

មកដោយពិត លើកឡើងពីការធ្វើបុណ្យចម្រើនព្រះជន្ម ដោយសេចក្តីថា ចម្រើនអាយុសង្ខាររបស់សត្វទាំងឡាយ ឱ្យទទួលបាន នូវសេចក្តីសុខស្ងប់ត្រជាក់ចិត្ត ព្រោះមនុស្សយើងកើតមក ដោយកុសលវិបាក ។

ពាក្យថា **ជន្ម** គឺជីវិតបានដល់ ជីវិតិន្ទ្រិយចេតសិក

ពាក្យថា **អាយុ** គឺដំណើរប្រព្រឹត្តទៅនៃជីវិត ។

សួរថា ការធ្វើបុណ្យចម្រើនព្រះជន្ម នាំមកនូវសារៈសំខាន់អ្វីខ្លះទៀត បានជាគេចូលចិត្តធ្វើទាំងក្មេងទាំងចាស់គ្រប់ៗ គ្នា ។

ជីវិត គឺជីវិតិន្ទ្រិយចេតសិកកើតជាមួយចិត្ត ទោះកុសលក្តី អកុសលក្តី អាស្រ័យពីកម្ម ជាអ្នករៀបចំចាត់ចែង មានការ ទាក់ទងពីអាហារនិងឧតុក្នុងបវត្តិកាល ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែង ។

☸ អាស្រ័យពីកម្ម

នៅក្នុងអង្គុត្តរនិកាយ ទសកនិបាត បិដកភាគ ៥១/១៧២ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វលោកប្រព្រឹត្ត ទៅតាមកម្មដែលកម្មនោះបែងចែកជា ៥ ចំណែក :

១- **កម្មស្សកា** : កម្មជារបស់ខ្លួន

២- **កម្មទាយាទា** : កម្មជាទាយាទ (អ្នកបម្រើ)

៣- **កម្មយោនី** : កម្មជាកំណើត

៤- **កម្មពន្ធូ** : កម្មជាផៅពង្ស

៥- **កម្មប្បដិសរណា** : កម្មជាទីរលឹក

យំ កម្មំ ករោន្តិ កល្យាណំ វា

បាបកំ វា តស្ស ទាយាទា ភវន្តិ ។

ប្រែថា : ម្នាលភិក្ខុទាំងឡាយ ទោះសត្វធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។

ដោយទ្រង់ជ្រាបនូវសេចក្តីនេះ ព្រះដ៏មានព្រះភាគព្រះអង្គមិនទ្រង់សម្តែង នូវការអស់ទៅនៃកម្មទាំងឡាយប្រកបដោយ

ចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវ ផលទេ ឯផលនោះឯងរមែងកើតក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន និងក្នុងអត្តភាពដទៃក៏មាន ។

ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតទុក្ខ ព្រោះមិនទាន់ទទួលផលនៃកម្មប្រកបដោយចេតនា ដែលសត្វធ្វើហើយសន្សំហើយទេ ។

នៅក្នុងបរមត្ថជោតិកៈ មហាអភិធម្មមត្ថសង្គហដីកា បរិច្ឆេទទី ៥ វិធីមុត្តសង្គហៈ (ជំពូកទី ២) ទ្រង់សម្តែងពង្រីកនូវកម្មទាំង ៥ ជា ១៦ កម្ម ចតុក្កៈ មាន ៤ ពួក ដូចខាងក្រោមនេះ :

✲ **ឈ្មោះថាកម្ម ពោលដោយកិច្ចមាន ៤ យ៉ាង**

១- **ជនកកម្ម** : កម្មរមែងធ្វើឱ្យវិបាកកើតឡើង

២- **ឧបត្ថម្ភកកម្ម** : កម្មរមែងជួយឧបត្ថម្ភកម្មដទៃ

៣- **ឧបបីឡកកម្ម** :កម្មរមែងចូលទៅបៀតបៀនកម្មដទៃ

៤- **ឧបឃាតកកម្ម** : កម្មរមែងចូលទៅកាត់កម្មដទៃ

ឬកាត់ ផលរបស់កម្មដទៃៗ ។

✵ ពោលដោយលំដាប់នៃកម្មឱ្យផលមាន ៤ យ៉ាង

១- **គរុកកម្ម** : កម្មយ៉ាងធ្ងន់ដែលកម្មដទៃៗ មិនអាចឱ្យផលបាន

២- **អាសន្នកម្ម** : កម្មធ្វើទុកពេលជិតនឹងស្លាប់ អាចរលឹកចាំបាន

៣- **អាចិណ្ណកម្ម** : កម្មធ្លាប់ធ្វើទុករឿយៗ

៤- **កដត្តាកម្ម** : កម្មធ្វើទុកល្មមប្រមាណមានកម្លាំងអន់ថយ មិនដូចកម្មទាំងបីនោះ ឬកម្មដែលធ្លាប់ធ្វើទុកក្នុងអតីតភព ។

✵ កម្មឱ្យផលមាន ៤ យ៉ាង

១- **ទិដ្ឋធម្មវេទនីយកម្ម** : កម្មដែលបានទទួលផលក្នុងរវាង ៧ ថ្ងៃ ឬក្នុងបច្ចុប្បន្នជាតិនេះ

២- **ឧបបជ្ជវេទនីយកម្ម** : កម្មដែលបានទទួលផលក្នុងជាតិទី ២

៣- **អបរាបរិយវេទនីយកម្ម**: កម្មដែលបានទទួលផល

ក្នុងជាតិទី ៣ ជាដើមតរៀងទៅរហូត ដូចស្រមោល

អន្ទោលតាមប្រាណ

៤- **អហោសិកម្ម** : កម្មដែលមិនឱ្យផល ។

✵ កម្មក្នុងឋានៈឱ្យផលមាន ៤ យ៉ាងដូចគ្នា

១- **អកុសលកម្ម** : ឱ្យផលជាទុក្ខក្នុងអបាយភូមិ៤

២- **កាមាវចរកុសលកម្ម:** ឱ្យផលជាសុខក្នុងកាម

សុគតិភព

៣- **រូបាវចរកុសលកម្ម** : ឱ្យផលជាសុខក្នុងរូបភព

៤- **អរូបាវចរកុសលកម្ម** : ឱ្យផលជាសុខក្នុងអរូបភព ។

ការលាតត្រដាង នូវកិច្ចនិងផលរបស់អំពើរួចមក ជា **គតិបណ្ឌិត** មួយ សម្រាប់ពិចារណារកការពិតក្នុងជីវិត ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញថា សត្វលោករស់នៅតាមកម្មចាត់ចែង មិនថាល្អ ឬអាក្រក់ សុទ្ធតែត្រូវទទួលនូវផលវិបាកគ្រប់ៗ គ្នា ។

កម្ម ប្រែថា អំពើ មាន ២ ចំណែក សំដៅដល់កម្ម ពីអតីត តាំងពីកន្លងយូរយារមកហើយមិនដឹងខាងដើមពីត្រឹមណា

និងកម្មបច្ចុប្បន្ន ហើយក៏មិនដែលចេះអនុគ្រោះអត់ឱនដល់អ្នកណាម្នាក់ ឱ្យតែដល់ពេលកំណត់ កម្មនឹងឱ្យផលជាក់ជាមិនខាន មិនអាចគេចចៀសវាងផុត **នត្ថិ កម្មំ សមំ ពលំ** ប្រែថា : កម្លាំងអ្វី ស្មើដោយកម្លាំងកម្មមិនមាន ។ ជាសំខាន់មនុស្ស យើងត្រូវមាន សតិរវាំងប្រយ័ត្នក្នុងជីវភាពកំពុងរស់នៅព្រោះ បច្ចុប្បន្ន ប្រៀបដូចជាទ្វារសម្រាប់បើកឱកាសទទួលកម្មពីអតីត កន្លងយូរមកហើយ ។

កាលណាបើយើងសាងសន្សំអំពើអាក្រក់ជាគតិវិបត្តិ, កម្មមិនល្អពីអតីតហូរចូលមកជួយទំនុកបម្រុង នាំឱ្យមានកម្លាំងធ្វើអាក្រក់ផ្សេងៗ ប្រសិនបើយើងសាងកម្មល្អជាគតិសម្បត្តិ ក៏កម្មល្អពីអតីត អាចចូលមកជួយឧបត្ថម្ភដ៏មានកម្លាំង នាំឱ្យធ្វើកុសលមានការ ធ្វើទាន សមាទានសីល ធ្វើសមថៈ អប់រំបញ្ញា ជាដើមដូចជាឱកាសធ្វើបុណ្យចម្រើនព្រះជន្ម ឬចម្រើនអាយុនេះជាដើម ។ ក្នុងពេលកំពុងធ្វើបុណ្យ ចេតនាជាតួកម្មកើតឡើង មានសទ្ធាជឿគុណព្រះរតនត្រៃ ជ្រះថ្លាក្នុងការកសាងសន្សំបុណ្យដោយមហាកុសល ៨ ដួង ណាមួយ ប្រារព្ធយកការធ្វើទានចំពោះទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងព្រះពុទ្ធសាសនា មានព្រះភិក្ខុសង្ឃសាវ័កជាស្រែបុណ្យ ដើម្បីប្រគេននូវទេយ្យវត្ថុ មានចង្ហាន់

បិណ្ឌបាតព្រមទាំងបច្ច័យ ៤ រូប និមន្ត ធម្មទិកសម្ដែងព្រះធម្មទេសនា ឬសមាទាននូវឧបោសថសីល ឬ កំពុងស្ដាប់ធម៌ ឬមានការធ្វើអភ័យទាន និងអំណោយផ្សេងៗដល់ស្ងួម ទុកជាអារម្មណ៍តាមចិត្តប្រាថ្នាឱ្យទៅជាមហាកុសល ហៅថា បុណ្យចម្រើនព្រះជន្ម គឺចម្រើនអាយុជីវិតឱ្យ **សម្បូណ៌កុសល** ចៀសវាងពីការបៀតបៀនដោយអកុសលវិបាកណាមួយ ។ ឯការមានអាយុយឺនយូរវែងខ្លីយ៉ាងណា ស្រេចតែនៅលើកម្មទាំងពីររួមផ្សំគ្នា រៀបចំដូចបានជម្រាបជូនមកហើយ ។ ប៉ុន្តែបើ ការធ្វើបុណ្យប្រាសចាកកុសល ក៏ពុំបានជួយចម្រើនអាយុ ឱ្យមានសុខភាព ល្អផ្លូវចិត្តបែរជានាំឱ្យជីវិតធ្លាក់ក្នុងអំពើលាមក ថោកទាប មាន កិលេសជាគ្រឿងចងរួបរឹតចិត្ត ចម្រើនទៅដោយ អកុសលធម៌ មិនមែនហៅថាបុណ្យចម្រើនព្រះជន្មទេ បុណ្យចម្រើនព្រះជន្ម មានន័យថាចម្រើនមហាកុសលហ្នឹងឯង ។

កាលណាមហាកុសលសម្រេចកិច្ចហើយ អ្វីៗទាំងអស់កើតឡើង ព្រោងព្រាតតាមលំដាប់ជាមួយគ្នា ព្រោះជីវិតលាយឡំទៅដោយ សោភណចេតសិក ជាតួបុណ្យនៅក្នុងមហាកុសលទាំង ៨ ដួង ណាមួយ ដូចជាមហាកុសល **សោមនស្ស សហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ទី១** មានចេតសិក ចុះ **៣៨** ដួង

បានដល់ អញ្ញសមានាចេតសិក **១៣** និងសោភណចេតសិក **២៥** គឺ ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ និង មនសិការៈ ទាំង ៧ នេះ ហៅថា **សព្វចិត្តសាធារណចេតសិក** ។ វិតក្កៈ វិចារៈ អធិមោក្ខៈ វីរិយៈ បីតិ ឆន្ទៈ នេះហៅថា **បកិណ្ណកចេតសិក** មាន ៦ + សព្វចិត្តសារណចេតសិក ៧ បានជា **អញ្ញសមានាចេតសិក** ១៣ ។ សទ្ធា សតិ ហិរិ ឱត្តប្បៈ អលោភៈ អទោសៈ តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុគតា ចិត្តុជុគតា សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ករុណា មុទិតា និងបញ្ញិន្ទ្រិយ សុទ្ធតែជាសោភណចេតសិក តួបុណ្យ ។ ចំណែក **សោភណចិត្ត** មាន ៥៩ ដួង (២៤ + ១៥ + ១២ + ៨ ឬ ៤០) ដោយពិស្តារ មាន ៩១ ដួង និងអសោភណចិត្ត ៣០ (១២ + ១៨) ឯចេតសិក កើតរួមមាន១៩(២៥-៦) ហៅថា **សោភណសាធារណចេតសិក** គឺចេតសិកកើតទូទៅ ។ ចំពោះសោភណចេតសិក ៦ គឺវិរតិ ៣ + អប្បមញ្ញា ២ + បញ្ញិន្ទ្រិយ មិនកើតទូទៅដល់ សោភណចិត្ត នេះទេ ។

ការឃើញយ៉ាងនេះ សន្និដ្ឋានបានតាមបញ្ហាជាក់ស្តែង ដើម្បីបង្ហើបប្រាប់នូវសុខទុក្ខរបស់ជីវិតក្នុងការរស់នៅ ដែលមានអាយុវែងឬខ្លី ក៏អាស្រ័យពីចិត្តសម្បយុត្តជាមួយសោភណចេតសិក និងអកុសលចេតសិក ប៉ុន្តែបុណ្យចម្រើនព្រះជន្មាយុសំដៅត្រង់មហាកុសល ដែលមានចេតសិកតួបុណ្យ កើតយ៉ាងច្រើន ធ្វើហេតុឱ្យអាយុរបស់សត្វទាំងឡាយ បានរស់នៅយូរអង្វែងខ្លះដែរ អាស្រ័យពីផលវិបាករបស់កម្មកន្លង រួចមកហើយ តែទោះជាយ៉ាងណាក៏មិនហួសពីក្នុងរវាងអាយុ មនុស្ស ១០០ ឆ្នាំ ចុះ ឬ ១០០ ឡើងបន្តិច ។

❁ ទាក់ទងពីអាហារ និងឧតុ

សេចក្តីនេះ ក៏គួរពិចារណាតទៅទៀតថា មនុស្សយើងមានអាយុវែងខ្លី មិនមែនត្រឹមតែចិត្តបុណ្យកើតឡើងទាំងអស់នោះទេ ជួនណា អ្នកខ្លះអាចស្លាប់ក្រោយថ្ងៃធ្វើបុណ្យចម្រើនព្រះជន្មរួចក៏មាន ព្រោះរូបកាយទ្រុឌទ្រោមមានជំងឺរោគាបៀតបៀនច្រើន អ្នកខ្លះមានសុខភាពល្អមាំមួន អាស្រ័យពីអាហារ និងឧតុផ្សំថែមទៀត នេះជាការសម្តែងរបស់ព្រះសម្មាសម្ពុទ្ធ នៅត្រង់ ពាក្យប្រៀនប្រដៅថា **ភោជនេមត្តញ្ញុតា** ប្រែថា

ការដឹងប្រមាណក្នុងភោជន គឺជាអ្នកមិនបរិភោគឱ្យឆ្អែតពេក មិនបរិភោគចំណីចំណុកអាក្រក់ ដែលជាអាហារនាំមកនូវគ្រោះថ្នាក់ ដូចជាអាហារមានជាតិពុល ឬជាតិគីមីច្រើន ឬ **អាហារមិនប្រកបដោយធម៌** ជាដើម ។ ការរស់នៅក្នុងទីកន្លែងចង្អៀត គ្មានខ្យល់ចេញចូល ងងឹតអាប់អួ ខ្វះពន្លឺ បណ្ដាលឱ្យមានរោគាព្យាធិ អាចធ្វើអន្តរាយដល់អាយុជីវិតផងដែរ ។ កន្លែងសម្រាក ដូចជា លំនៅដ្ឋាន បន្ទប់ ត្រូវមានអនាម័យ ក៏ជាជំនួយដល់សុខភាព ក្នុងដំណើរប្រព្រឹត្តទៅនៃជីវិត ជាសំខាន់ជាងនេះ ត្រូវមាន **គុណធម៌** គឺសេចក្ដីល្អនៅក្នុងខ្លួនឱ្យសម្បូណ៌ ព្រោះអំពើល្អជាឈ្មោះរបស់បុណ្យនាំមកនូវសេចក្ដីសុខ អ្នកទាំងឡាយចូរកុំខ្លាចបុណ្យ សម្ដែងដោយព្រះដ៏មានព្រះភាគ ។

ម្យ៉ាងទៀត អាហារប្បច្ច័យនេះ ជាចំណែកមួយក្នុងបច្ច័យ ៤ សម្រាប់ផ្គត់ផ្គង់ជីវិតប្រចាំថ្ងៃរបស់រូបកាយ ដែលមានៈ

១- **ចីវរប្បច្ច័យ** ទុកដូច សីល ជាសម្លៀកបំពាក់របស់ចិត្ត ឬជាគ្រឿងអលង្ការរបស់ចិត្ត **សីលំ អាភរណំ សេដ្ឋំ** ពិសេសជាង រូបកាយ ក្នុងការការពារនូវកិលេសទាំងឡាយ ដូចជា សម្ផស្ស របោម មូស ខ្យល់ ក្ដៅ ត្រជាក់ ពស់តូច និងពស់ធំ ដូច្នោះដែរ ។

២- **បិណ្ឌបាតបច្ច័យ** គឺជាអាហារប្រចាំថ្ងៃបានដល់ **ការឱ្យទាន** ព្រោះពេលណាបានធ្វើទានរួចហើយ សភាពនៃចិត្ត ហាក់ដូចមាន អារម្មណ៍ម្យ៉ាងគួរជាទីរីករាយ ធ្វើឱ្យចិត្តសុខស្ងប់ មិនស្ងួវកង្វល់ពីកិលេសទាំងឡាយ មានលោភៈ ទោសៈ មោហៈ ជាដើម ។

៣- **សេនាសនបច្ច័យ** បានដល់ ការអប់រំចម្រើនភាវនា ធ្វើឱ្យចិត្តស្ងប់ ក្នុងការរលឹកដល់គុណទាំងឡាយនៅក្នុង អនុស្សតិ ១០ មានគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទុកជា រមណីយដ្ឋានគួរជាទីរីករាយ ឬ ប្រកបដោយមេត្តា ករុណា ដល់ សព្វសត្វ ធ្វើឱ្យចិត្តត្រជាក់ក្សេម គ្មានអ្វីប្រៀប ហៅថាផ្ទះ របស់ចិត្ត ដែលមានសម្ភារៈប្រើប្រាស់ តុបតែងទៅដោយគ្រឿង សង្ហារិមច្រើនមុខ មានអាងទឹកជាដើម ទុកជាកម្មដ្ឋាន ផ្សេងៗ មាន **ខន្តី** ជារបងផ្ទះ លំអទៅដោយសួនច្បារ គឺសីល សមាធិ បញ្ញា ។

៤- **ភេសជ្ជបច្ច័យ** បានដល់ វិបស្សនា គឺប្រាជ្ញាបានដឹង នូវអ្វីៗសុទ្ធតែ ជាទុក្ខដែលមិនក្រៅ ពីរូបធម៌នាមធម៌ ប្រព្រឹត្ត ទៅក្នុង **តេភូមិកធម៌** ឃើញច្បាស់ថា ជាអនត្តាដោយបញ្ញា បានកំណត់ដឹងត្រឹមតែនាមរូបពុំមានអ្វីសោះ និងមិនត្រូវការអ្វី ទាំងអស់ ប្រៀបដូចជាពន្លឺព្រះចន្ទ គ្រាន់តែបំភ្លឺលោក ឬដូចជា

ពន្លឺប្រទីប ដែលមានត្រឹមតែវិថីចិត្តកើតឡើងដឹងអារម្មណ៍ រួចក៏រលត់ទៅវិញ ធ្វើឱ្យកំណត់ដឹងនូវ ទុក្ខសច្ចៈ នាំឱ្យរំលត់តណ្ហា ជាតទង្គប្បហានរហូតជាសមុច្ឆេទប្បហាន ព្រមទាំងបានដឹងពីការអស់ទៅនៃទុក្ខ ព្រោះអស់តណ្ហា នេះ ហៅថា ព្រះនិព្វាន ។ (ដកស្រង់ ពីកាសែតលេខ ១ សម្ដែងដោយលោកគ្រូ អគ្គបណ្ឌិតនាពិធីបុណ្យកឋិន នៅថ្ងៃ ១៥-១០-០៨ ខេត្តបាត់ដំបង) ។

ប្រសិនបើយើងចេះរៀបចំជីវិត ឱ្យរស់នៅស្រួលដូចបានសរសេរនៅក្នុងសៀវភៅ "លោកទស្សនៈ" រួចមកហើយ ដោយសង្កត់ធ្ងន់ទៅលើស្ថាប័នអប់រំជាដំបូង អាចជាជំនួយឱ្យជីវិតទទួលបាននូវភាពសុខស្ងប់ត្រជាក់ចិត្ត ពុំសូវកង្វល់ពីអ្វីផ្សេងៗប្រាសចាកពីជីវិតទុព្វល ក៏ជាកត្តាមួយ នាំឱ្យចម្រើនបញ្ញាស្មារតីវាងវៃ ឆ្លៀវឆ្លាស់ក្នុងការងារ ព្រោះគិតតែពីសេចក្ដីត្រេកអរីករាយក្នុងកងការកុសល មិនគិតអ្វីក្រៅពី ធ្វើបុណ្យសន្សំបញ្ញា ចូលដល់ការពិតនៃធម្មៈ ហាក់ដូចស្រោចទឹកជីវិត ឱ្យលូតលាស់មានសម្រស់ស្រស់បំព្រង ចៀសវាងពីភាពស្រពាប់ស្រពោន ដោយកិលេស ឬគ្រោះថ្នាក់ផ្សេងៗ ហៅថា បុណ្យចម្រើនព្រះជន្ម ឋិតនៅក្នុងភាពទំនេរ សម្រាកពីការងារ **អកុសល ដោយកុសល** ។ ដូច្នោះ បុណ្យចម្រើនព្រះជន្ម

ក៏ជាចំណែកមួយ ដល់ការជួយរៀបចំ អាយុជីវិតរបស់សត្វទាំងឡាយ ដែលនៅសេសសល់ តិចក្តី ច្រើនក្តី ឱ្យមានថាមពលសម្រាប់ទប់ទល់នឹង ការយល់ខុសផ្សេងៗ គឺតម្រង់ផ្លូវ ដើម្បីចៀសវាងពីការវង្វេងភន្តច្រឡំក្នុងពេលរៀបនឹងចុតិទៀតផង ។

បណ្តាំគ្រូ

✧ បើចេះដឹង កុំស្រវឹង នឹងលាភយស
មិនខ្ពង់ខ្ពស់ ព្រោះរឿងកាម តាមយ៉ាងស្អិត
ក្នុងលោកិយ ចេះព្រមល្មម ឃើញការពិត
សាងសុចរិត ប្រើសីលធម៌ សាមគ្គីគ្នា ។

✧ កុំបំបែក នាំរហែក វិនាសខ្លួន
គេគុំកួន តាមព្យាបាទ ឱ្យគ្រាំគ្រា
ជួយមិនរួច យូរអង្វែង រងវេទនា
មានសទ្ធា ទើបស្រង់បាន ប្រាណផុតភ័យ ។

បើចេះរស់ សាងកុសល កល់ឡើងលើ
ធ្វើអំពើ ឱ្យស្មោះត្រង់ ទើបជោគជ័យ
មិនសម្លឹង ដល់ទោសតូច អ្នកដទៃ
ចេះរំពៃ ឃើញតែបុណ្យ គ្រាន់ជាងបាប ។

បើសង្គ្រោះ ដោយករុណា ដល់សព្វសត្វ
ជួយបំបាត់ គ្រោះអាសន្ន ធ្ងន់ដុនដាប
ការស្រេកឃ្លាន ស៊ូអត់ទ្រាំ ជួយបន្សាប
នូវក្លិនស្អាប កើតបញ្ហា ផ្តាច់ទាក់ទង ។

ជីវិតខ្លី ឬរស់យូរ ដោយសារកម្ម
តាមចំណាំ ការបរិភោគ កុំរំលង
ជាហេតុជិត ធ្វើអាយុ ស្រស់បំព្រង
តាមទំនង មិនទៀងទាត់ ព្រោះអាហារ ។

អាកាសធាតុ ក្តៅត្រជាក់ អាស្រ័យហេតុ
ពិនិត្យភ្លែត ដល់អារម្មណ៍ ដោយប្រាជ្ញា
ជីវិតរស់ ព្រោះសម្ពន្ធ សញ្ចេតនា
កុំប្រាថ្នា ឱ្យខុសពី ធាតុខាងដើម ។

មកដោយពិត ជីវិតរស់ ផលបច្ច័យ
កុំតថ្លៃ ថាមានគេ ធ្វើបំផើម
ដូចដើមឈើ មានឫសដុះ ទប់ជ្រែងដើម
ស្គាល់ចិត្តថ្លើម ជួបជុំគ្នា មិនរលាយ ។

រលំដើម នៅឫសគល់ ទុកដុះទៀត
ត្រូវខំឆ្លៀត គាស់រំលើង ទោះមិនងាយ
ប្រើបញ្ញា យកព្យាយាម កុំរាយមាយ
រួចរើចស្លាយ នូវការពិត ទុកជាកេរ ។

ការធ្វើបុណ្យ ចម្រើនជន្ម ជីវិតរស់
មិនចេះទាស់ អ្វីកើតឡើង ទៅទទេ
ចេះសម្រួល តាមការពិត បានទំនេរ
រស់ខ្ញុំគេ គ្មានឥស្សរៈ ខានស្តាប់ធមិ ។

ជីវិតរស់ ដោយសារបុណ្យ នៅពីក្រោយ
ផ្សំបណ្តោយ តាមខ្សែចិត្ត ជួយទល់ទ្រ
ក្នុងបច្ចុប្បន្ន ចម្រើនគុណ ហុចផលល្អ
ដូចទូងស្គរ ប្រមូលគ្នា សាងកុសល ។

✦ បុណ្យប្រាជ្ញា កើតពេលណា តែងបានសុខ
បង្ហាញមុខ ជូនសត្វលោក ទាំងសាកល
មិនឱ្យព្រួយ រីកចម្រើន ខាងហេតុផល
ឆាប់បានដល់ សន្តិភាព ត្រជាក់ក្សេម ។

ការពិចារណារកការពិត

មកដោយពិត បញ្ជាក់បង្ហាញប្រាប់ពី ធម្មជាតិទាំងឡាយ មានអាថិកំបាំងងងឹតជ្រៅក្រៃលែង ដែលភ្នែកយើងធម្មតាពុំអាច សម្លឹងមើលឃើញជ្រាបដឹងបាន ព្រោះក្នុងសាកលលោកចក្កវាឡ ធម្មជាតិទាំងឡាយតែងមានគូនឹងគ្នា ដាច់ខាត ពុំមានតែមួយៗ ឬម្នាក់ឯង បើមានខាងក្នុង ក៏ត្រូវមានខាងក្រៅដែរ បើមាន សរសើរនិន្ទាក៏មាន ដូចយ៉ាងតថាគតកាលនៅជាសុមេធបណ្ឌិត ក្នុងគម្ពីរពុទ្ធវង្ស (សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំសៈ ចរិយាបិដកភាគ ៧៧/២៣) បានត្រិះរិះម្នាក់ឯងនៅក្នុងទីស្ងប់ស្ងាត់ថា កាលបើសេចក្តីទុក្ខមាន សេចក្តីសុខក៏មានយ៉ាងណា កាលបើភពមាន ការប្រាសចាកភពបុគ្គលគួរតែ

ប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្ដៅមាន ត្រជាក់ដទៃក៏មានយ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ កាលបើបាបមានបុណ្យក៏មាន កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នាក៏មានយ៉ាងនោះដែរ ។ បុរសដែលប្រឡាក់ដោយលាមក កាលបើឃើញ ស្រះពេញទៅដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះមិន មែនជា ទោសនៃស្រះយ៉ាងណា កាលបើស្រះគឺទីដ៏ក្សេមផុតទុក្ខមានហើយ បុគ្គលមិនខំស្វែងរកស្រះសម្រាប់លាងជម្រះនូវមន្ទិលគឺកិលេសចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺនិព្វានទេ ជាទោសរបស់បុរសក៏យ៉ាងនោះដែរ ។ ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្ដីទុក្ខការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្ដីទុក្ខ ដូចគ្នា (សេចក្ដីស្លាប់ប្រកបដោយមោហៈនាំមកនូវសេចក្ដីទុក្ខ រូបដែល ជរា ញាំញីហើយ ក៏នាំមកនូវទុក្ខ) អាត្មាអញមានជាតិ ជាធម្មតា មាន ជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញ នឹងស្វែងរកនូវព្រះនិព្វានដែលមិនចាស់មិនស្លាប់ជាទីក្សេមក្សាន្ត ។

បើដូច្នោះ គួរតែអាត្មាអញដាក់ធុរៈស្វែងរកប្រយោជន៍ដ៏ធំលះបង់ប្រយោជន៍តូច និងអ្វីៗក្នុងលោក សំខាន់ជាងគេ គឺកាយ

ស្អុយដែលពេញទៅដោយសាកសពផ្សេងៗចេញ មិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូបនោះ ប្រៀបដូចជាបុរស ស្ត្រី ទាំងឡាយទៅបន្ទោបង់នូវករីសៈក្នុងបង្គន់រួចហើយឥតមានការស្រណោះ ឥតមានសេចក្តីត្រូវការ រួចដើរចេញទៅយ៉ាងនោះដែរ ។

សេចក្តីសុខ បើបុគ្គលមិនខំស្វះស្វែងរក មិនងាយនឹងបានជួបបានសម្រេច ព្រោះធម្មជាតិ នៅក្នុងលោក (ខ្លួនយើង) ចង្អៀតស្អុគ្រស្អាញ កាលបើបានស្រណុកសុខស្រួលបន្តិចបន្តួច ក៏យល់ថានេះជាសុខ ដូចយ៉ាងប្រាថ្នារកទ្រព្យសម្បត្តិបានច្រើន ក៏យល់ថាសុខហើយ ។ គិតទៅ សុខនៅក្នុងកាមភពមានច្រើនបែបណាស់ បើប្រៀបធៀបទៅនឹងសុខរបស់មនុស្សយើងសព្វថ្ងៃ អ្នកមិនមានរោគាព្យាធិ មានសេចក្តីសុខច្រើនជាងអ្នកមានរោគា អ្នកមានទ្រព្យសម្បត្តិប្រសើរជាងអ្នកគ្មានទ្រព្យសម្បត្តិ ចំណែកសេចក្តីសុខរបស់មនុស្សយើង អន់ជាងសុខរបស់ពួកទេវតានៅឋានសួគ៌ ៦ ជាន់ ឯសេចក្តីសុខរបស់ពួកព្រហ្មប្រសើរជាងសុខរបស់កាមសុខ ៦ ជាន់ ទៅទៀត ព្រោះគេចូលចិត្តកាន់យក នូវការហួងហែងប្រកបដោយ ឆន្ទរាគៈ ជាប់ស្អិតនឹងវត្ថុកាម ដូចក្មេងលេងដីខ្សាច់កសាងបានជាកូនផ្ទះ ដែលមនុស្សក្នុងលោកខ្លះ

មានប្រាជ្ញាទន់ទាប ចូលចិត្តត្រេកត្រអាលនឹងសម្ភារទាំងឡាយដែលជាទុក្ខ ហើយភ្លេចគិតដល់គុណប្រយោជន៍ក្នុងការស្វែងរកសុខពិត ។

តាមការសិក្សាស្រាវជ្រាវ សភាវសុខមិនមែនស្ថិតនៅលើមានទ្រព្យសម្បត្តិច្រើន មានបរិវារច្រើន មានគេស្រឡាញ់រាប់អានច្រើន មានញាតិច្រើន មានបុត្រនិងភរិយាជាទីស្រឡាញ់ពេញចិត្ត មានគេថែរក្សាថ្នាក់ថ្នម មានបុណ្យសក្តិខ្ពង់ខ្ពស់ ដែលជាគ្រឿងសៅហ្មងចិត្តរបស់អន្ទាក់នៃកិលេសមារ សេចក្តីសុខពិតនៅត្រង់ការមានបញ្ញា ចេះរំដោះខ្លួនចេញពីគ្រឿងសៅហ្មងស្មោគគ្រោកក្នុងចិត្ត ដូចបានជម្រាបជូនពីខាងដើមរួចមកហើយ ។

សរុបសេចក្តី ហៅថា លះបង់ឧបាទានក្ខន្ធ ដោយបញ្ញាដ៏ប្រពៃ ទើបស្វែងរកសុខសន្តិភាពបាន ចំណែកពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងពីការជួយស្រោចស្រង់សត្វ ឱ្យរួចពីសេចក្តីទុក្ខ ប្រាប់បង្ហាញពីសុខពិតតាមផ្លូវដ៏ប្រសើរបានដល់ **អរិយមគ្គមានអង្គ ៨** នេះឯង ដែលសត្វលោកមានចំនួនច្រើនរាប់មិនអស់ បានសម្រេចអមតធម៌ គឺបរមសុខពុំមានមធ្យោបាយណា ក្រៅពីការអប់រំចម្រើនផ្លូវចិត្ត ចូលដល់រូប

ធម៌នាមធម៌ដូចទ្រង់ត្រាស់សម្ដែង ថែមទាំងជាពាក្យពិត ពុំមានវាចាណាមួយ ពោលឡើងខុសឃ្លាតរវាតចាកពីការពិត ធ្វើឱ្យមនុស្ស និងទេវតា អបអរសាទរគាំទ្រកក្រើកផែនពសុធា សូម្បីគ្រាន់តែពិចារណាពុទ្ធការកធម៌ ក្រោយសម័យដែល ព្រះសម្មាសម្ពុទ្ធទីបង្ករព្យាករួច ផែនដីកក្រើកញាប់ញ័រ ទាំង **មួយម៉ឺនលោកធាតុ** ផ្អើលដល់មនុស្សម្នាមហាជនភិតភ័យ ញាប់ញ័រ បានមកទូលសួរដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ម្យ៉ាងទៀតសេចក្ដីសុខពិត នៅត្រង់ការពិចារណារកហេតុផល ព្រោះអ្វីៗកើតឡើងមិនដែលប្រាសចាកហេតុៗយ៉ាងណា ផលត្រូវតែយ៉ាងនោះ តាមកម្មជាអ្នករៀបចំ ប៉ុន្តែសត្វលោកខ្វះបញ្ញា ពុំមានសទ្ធា ក៏ចូលចិត្តទំនាស់នឹងច្បាប់កម្មផលដែលបណ្ដាលឱ្យមាន អំពើខុសឆ្គងសាងសន្សំពូជអាក្រក់ទុកក្នុងចិត្ត សម្រាប់ទទួលទុក្ខតទៅខាងមុខ ពុំមានឱកាសណារៀបចំជីវិតឱ្យមានខ្លឹមសារ ។

ជីវិតថ្លៃថ្នូរមានតែក្នុងព្រះពុទ្ធសាសនានោះឯង បើអស់ព្រះពុទ្ធសាសនា ជីវិតក៏មិនសូវមានតម្លៃ ព្រោះចម្រើនទៅដោយអកុសលកម្មបថ ១០ ។

ពុទ្ធចរិយា

មកដោយពិត សម្តែងប្រាប់ថា ព្រះសម្មាសម្ពុទ្ធទ្រង់ បាន កសាងសន្សំអភិនិហារបារមីជាបញ្ញាធិក ចំនួន **៤ អសង្ខេយ្យ និងមួយសែនមហាកប្ប** ចាប់តាំងពីព្រះពុទ្ធទីបង្ករ ទ្រង់ព្យាករ ហើយពិចារណារកផ្លូវត្រង់ពិត ក៏បានឃើញនូវបារមី ៣០ ដែល ជាមធ្យោបាយនាំទៅរកការត្រាស់ដឹងធម៌ ។ ក្រោយពីបានសម្រេច នូវសម្មាសម្ពោធិញ្ញាណ ព្រះអង្គទ្រង់និមន្តយាង ទៅប្រោសពួក បញ្ចវគ្គិយភិក្ខុ មាន **ព្រះអញ្ញាកោណ្ឌញ្ញ** សម្រេច មគ្គផល មុនគេ បង្អស់ បន្ទាប់មក **ភទ្ទិយៈ វប្បៈ មហានាម និងអស្សជិ** ដែលបាន ឆ្លងផុតពីវាលវដ្តសង្សារជា បន្តបន្ទាប់ ព្រមទាំងពួកព្រហ្ម ១៨ កោដិ នៅ **ព្រៃឥសិបតន-មិគទាយវ័ន** ។ រួចហើយ ព្រះអង្គទ្រង់ យាងទៅប្រោសព្រះបាទ ពិម្ពិសារនៅក្រុងរាជគ្រឹះ ដែនមគធៈ ដោយទ្រង់សម្តែងពីទោស របស់កាម និងទ្រង់ពុទ្ធដំណើរយាង ទៅប្រោស ព្រះវររាជបិតា នៅក្រុងកបិលវត្ថុ, ទ្រង់សំដែងពី វេស្សន្តរជាតក មានពួកសត្វ ៨ ម៉ឺន ៤ ពាន់ រូប បានត្រាស់ដឹង

ធមិនាពេលនោះផងដែរ មិនតែប៉ុណ្ណោះទ្រង់និម្មិតភ្នំសិនេរុ ជាកន្លែងរីករាយធ្វើជាទី ចង្ក្រមនៅ កណ្តាលផ្ទៃអាកាស ។ ព្រះអង្គទ្រង់ធ្វើបាដិហារ្យ ដោយទ្រង់ ស្ដាត់នូវបាដិហារ្យ ៣ គឺឥទ្ធិបាដិហារ្យ១ អាទេសនាបាដិហារ្យ ១ និងអនុសាសនីបាដិហារ្យ១ ទ្រង់បើកលោកនាំឱ្យកើតចេញពន្លឺ ភ្លឺក្នុងលោកទាំងពីរ រហូតដល់លោកន្តរនរក ដើម្បីឱ្យសត្វ មើលឃើញគ្នា ដោយអំណាចបាដិហារ្យយ៉ាងអស្ចារ្យនោះ ។ ជាអវសាន ព្រះអង្គទ្រង់យាងទៅប្រោសពួកសត្វទាំងឡាយ រហូត រំលត់ ខន្ធបរិនិព្វាន ជាគំរប់ ៤៥ ព្រះវស្សា ។

ព្រះអង្គជាសាស្ត្រាចារ្យផង ជាទង់ផង ជាទង់ជ័យផង ជាប្រាសាទផង ជាទីពឹងប្រព្រឹត្តទៅខាងមុខផង ជាប្រទីបរបស់សត្វផង និងទ្រង់ឧត្តមជាងសត្វជើងពីរផង ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសនូវរឿងគឺ គោត្រ ១ អាយុ ១ ដើមពោធិព្រឹក្ស ១ សាវកសាវិកាសន្និបាត ១ ឧបដ្ឋាក ១ មាតា ១ បិតា ១ បុត្រ ១ ភរិយា ១ ជាដើម ដែលព្រះជិនស្រីអតីតពុទ្ធទាំងឡាយ ទ្រង់សម្តែងចងក្រងទុកជាប់តមក ចាប់តាំងពីព្រះពុទ្ធទីបង្ករ ជាប្រយោជន៍ក្នុងលោកព្រមទាំងទេវលោកដោយប្រាជ្ញាដែលប្រព្រឹត្ត

ទៅតាមបុព្វេនិវាស ។ (ដកស្រង់ពីក្នុងខុទ្ទកនិកាយពុទ្ធវិសៈ ចរិយាបិដកភាគ ៧៧/២០) ។

ម្យ៉ាងទៀតព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរ ហើយក៏មិនឃ្លៀងឃ្លាតចាកការពិត ដែលទ្រង់ពោលវាចាឡើង សុទ្ធតែទ្រង់ជ្រាបច្បាស់ដោយព្រះប្រាជ្ញាញាណក្នុងបំណងជួយស្រោចស្រង់សត្វឱ្យរួចពីសេចក្តីទុក្ខ ជាវាចាពិតពុំមានពាក្យពីរ ដោយទ្រង់ត្រាស់យ៉ាងណា ក៏ទ្រង់ធ្វើយ៉ាងនោះមិនឱ្យខុសពីប្រក្រតីឡើយ ព្រោះព្រះអង្គចេញផុតពីលោក មិននៅក្នុងលោក ទាំងព្រះវរកាយ ព្រះវាចា និងចិត្តសុទ្ធតែជា ធម្មៈគឺធម្មជាតិដែលមានឈ្មោះថាជាស្តេចនៃអ្នកប្រាជ្ញ ឬធម្មរាជាហៅថា ព្រះតថាគត គឺទ្រង់គ្របសង្កត់លើលោកទាំងមូល រហូតដល់ព្រហ្មលោក សូម្បីព្រះវាចាទ្រង់ពោលសម្តែង ព្រះធម្មទេសនា ដែលមាននៅក្នុងអដ្ឋកថា លោភសូត្រខុទ្ទកនិកាយ ឥតិវុត្តកលេខ៨៥/ភាគ៤/៣៩ ថា : **សំឡេងសម្តែងធម៌របស់ព្រះដ៏មានព្រះភាគតែមួយភាសា (មគធៈ) ប្រព្រឹត្តទៅក្នុងខណៈតែមួយ ជាសំឡេងដែលសត្វទាំងឡាយមានភាសាផ្សេងៗអាចទទួលស្តាប់ព្រមគ្នាតាមភាសារៀងៗខ្លួន រមែងប្រព្រឹត្តទៅឱ្យ**

យល់ជ្រាបដឹងសេចក្ដីបាន ដោយអំណាចពុទ្ធានុភាព ជាអចិន្ដេយ្យ ដែលព្រះអានន្ទបានចងចាំទ្រង់លើកយកមកសម្ដែង ។

នៅក្នុងខុទ្ទកនិកាយ មហានិទ្ទេស សារីបុត្តសុត្តនិទ្ទេសទី ១៦ ភាគ ៦៦/២២១ ទ្រង់សម្ដែងថា ព្រះមំសចក្ខុ ទ្រង់ទត ឃើញមួយយោជន៍ដោយជុំវិញ ទោះយប់ក្ដីថ្ងៃក្ដី ឬងងឹតប្រកប ដោយអង្គ ៤ គឺ ព្រះអាទិត្យអស្ដង្គត ១ ថ្ងៃឧបោសថចំណែក ខាងរនោច ១ ដងព្រៃជិតស្លប់ ១ ភ្លៀងធំខុសកាលតាំងឡើង ១ ។ ព្រះអង្គមិនមានជញ្ជាំង ឬសន្ទះទ្វារ កំពែង ឬភ្នំ គុម្ពឈើ ឬវល្លិ ជាគ្រឿងរាំងនូវកិរិយាឃើញនូវរូបទាំងឡាយទេ បើទុកជា គេដាក់គ្រាប់ល្ង ១ គ្រាប់ ក្នុងរទេះពេញទៅដោយល្ង ធ្វើជា គ្រឿងចំណាំ ក៏នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ង នោះបានវិញដដែល ។

នៅក្នុងបរមត្ថទីបនី អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកភាគ ៤ លេខ ៤៥ភាគ៤/២៣០ មានសម្ដែងពីសេចក្ដីសម្គាល់ ៨ យ៉ាង នូវព្រះនាមព្រះសម្មាសម្ពុទ្ធឈ្មោះ តថាគត ដូចខាងក្រោមនេះ ។

១- ឈ្មោះថាតថាគត ព្រោះស្ដេចមកដូចយ៉ាងនោះ

២- ឈ្មោះថាតថាគត ព្រោះស្ដេចទៅដូចយ៉ាងនោះ

៣- ឈ្មោះថាតថាគត ព្រោះទ្រង់ដឹងលក្ខណៈពិត

៤- ឈ្មោះថាតថាគត ព្រោះត្រាស់ដឹងធម៌ពិតដោយសេចក្ដីពិត

៥- ឈ្មោះថាតថាគត ព្រោះទ្រង់ឃើញសេចក្ដីពិត

៦- ឈ្មោះថាតថាគត ព្រោះទ្រង់មានព្រះវាចាពិតឬទូន្មានពិត

៧- ឈ្មោះថាតថាគត ព្រោះទ្រង់ធ្វើតែសេចក្ដីពិត

៨- ឈ្មោះថាតថាគត ព្រោះអត្ថថាគ្របសង្កត់លើលោកទាំងមូល

សេចក្ដីពិស្ដារ

✦ -ឈ្មោះថា **តថាគត** ព្រោះស្ដេចមកយ៉ាងនោះ ដោយសេចក្ដីថា ទ្រង់បំពេញបារមី ៣០ គ្រប់គ្រាន់ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី១០ និងទ្រង់ប្រកបនូវមហាបរិច្ចាគ ៥ ប្រការ គឺបរិច្ចាគអវយវៈ ១ បរិច្ចាគខ្លួនឬជីវិត ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគបុត្រភរិយា ១ និងបរិច្ចាគរាជសម្បត្តិ១ ។

✦ -ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅដូចយ៉ាងនោះដោយសេចក្ដីថា នៅពេលដែលព្រះពោធិសត្វប្រសូតចាកព្រះគភ៌ នៃមាតាភ្លាម ទ្រង់សណ្ឋិត (ឈរលើផែនដី) ដោយព្រះបាទជាន់

ស៊ប់ ជាបុព្វនិមិត្តនៃឥទ្ធិបាទ ៤. ទ្រង់បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅមុខបាន ៧ ជំហាន ជាបុព្វនិមិត្តនៃពោជ្ឈង្គ ៧ ប្រការ ។ កាលដែល មហាជនកំពុងបាំងស្វេតច្ឆត្រថ្វាយ ក៏រមិលមើលនូវសព្វទិសទាំងពួង ដោយពោលនូវអាសភិវាចា (វាចាដ៏ឧត្តម) ប្រៀបដូច រាជសីហ៍ ឈរនៅលើកំពូលភ្នំថា **អគ្គោហមស្មិ លោកស្ស** បានសេចក្ដីថា អញជាបុគ្គលខ្ពង់ខ្ពស់លើលោក, **ជេដ្ឋោហមស្មិ លោកស្ស** ប្រែថា អញជា ចម្បងបំផុតលោក, **សេដ្ឋោហមស្មិ លោកស្ស** ប្រែថា អញជា បុគ្គលប្រសើរលើលោក នេះជាកំណើតចុងក្រោយរបស់អញ ចំណែកភពថ្មីតទៅទៀតមិនមាន ។

✦ ឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងលក្ខណៈពិតដោយសេចក្ដីថា ព្រះអង្គទ្រង់ដឹងសាមញ្ញលក្ខណៈព្រមដោយលក្ខណៈរបស់រូបធម៌នាមធម៌ទាំងពួង ដែលបានចាក់ធ្លុះដោយ **ញាណគតិ** ។

✦ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិតដោយសេចក្ដីថា ត្រាស់ដឹងនូវអរិយសច្ចធម៌ ៤ ជាធម៌ពិត ដោយពាក្យគតស័ព្ទក្នុងទីនេះមានសេចក្ដីថា ការត្រាស់ដឹងដ៏ក្រៃលែង ។

✦ ឈ្មោះថា **តថាគត** ព្រោះទ្រង់ឃើញសេចក្ដីពិតដោយសេចក្ដីថា ព្រះតថាគតជាម្ចាស់ ទ្រង់ដឹង ទ្រង់ឃើញដោយអាការទាំងពួង នូវរូបារម្មណ៍តាមចក្ខុទ្វាររបស់សត្វទាំងឡាយប្រមាណមិនបាន ក្នុងលោកធាតុ ។ ពេលទ្រង់ដឹងទ្រង់ឃើញយ៉ាងនេះក៏បានចែកនូវរូបារម្មណ៍នោះគួរជាទីប្រាថ្នា ឬដោយការបានបទក្នុង ទិដ្ឋៈ សុតៈ មុតៈ វិញ្ញាតៈ ដោយន័យមានជាអាទិ នូវរូបសម្ដែងចេញជាពន្លឺ អាស្រ័យពីមហាភូតរូប ៤ ប៉ះខ្ទប់គ្នាភ្លាមកើតមានពណ៌ខៀវ ពណ៌លឿង ជាដើម ចេញឈ្មោះច្រើនប្រការ ឬដោយ ១៣ វារៈ ឬដោយ ៥២ ន័យនូវការពិតតែម្យ៉ាង ។ ក្នុងសំឡេងតាម សោតទ្វារក៏មានន័យ ដូចគ្នា ។

✦ ឈ្មោះថា **តថាគត** ព្រោះទ្រង់ទូន្មានដោយវាចាពិតដោយសេចក្ដីថា ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណរហូតរាត្រីណា ស្ដេចទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ក្នុងរវាងនេះ ពាក្យទូន្មានមាន សុត្តៈ គេយ្យៈ ជាដើមណាដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់សម្ដែងហើយ ក្នុងវេលា ៤៥ វស្សា ទាំងអស់នោះបរិសុទ្ធបរិបូណ៌ ញុំាញីនូវសេចក្ដីស្រេកឃ្លាន អន្ទះសាក្នុងរាគៈជាដើម ជារបស់ ពិត ។

✦ ឈ្មោះថា **តថាគត** ព្រោះទ្រង់ប្រព្រឹត្តធ្វើតែសេចក្តីពិត ដោយសេចក្តីថា កាយរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ រមែង អនុលោមតាមវាចា ចំណែកវាចាក៏អនុលោមតាមកាយ ព្រោះ ហេតុដូច្នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបជាអ្នកពោល យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះនិងធ្វើយ៉ាងណាក៏ពោលយ៉ាងនោះ ដូចគ្នា ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់ ថា **យថាវាទី ភិក្ខវេ តថាគតោ តថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោតិ វុច្ចតិ ។**

ប្រែថា : ម្នាលភិក្ខុទាំងឡាយ តថាគតពោលយ៉ាងណា ក៏ទ្រង់ធ្វើ យ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះតថាគត ពោលយ៉ាងណាទ្រង់ធ្វើយ៉ាងនោះ និងធ្វើយ៉ាងណាក៏ពោលយ៉ាង នោះដោយពិត ទើបឈ្មោះថា តថាគត ។

✦ ឈ្មោះថា **តថាគត** ព្រោះទ្រង់គ្របសង្កត់នូវលោកទាំងមូល ដោយសេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់គ្របសង្កត់ដល់ភវគ្គព្រហ្ម ជាន់លើ និងអវិចិនរកជាន់ក្រោមបំផុត ព្រមទាំង សព្វសត្វក្នុង លោកធាតុប្រមាណមិនបាននូវគុណរបស់ព្រះអង្គ មិនអាចស្ទង់ វាស់ដោយសីលខ្លះ ដោយសមាធិខ្លះ ដោយបញ្ញាខ្លះ ដោយ

វិមុត្តិខ្លះ ដោយវិមុត្តិញាណទស្សនៈខ្លះ តាមសភាពពិត ដែល ទ្រង់ដឹកនាំសត្វ ឱ្យរួចផុតចាកទុក្ខរាប់មិនអស់ ។ ព្រះអង្គ ជាទេវតាក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ទាំងឡាយ ជាព្រហ្មក្រៃលែងជាងព្រហ្មទាំងឡាយ ប្រសើរបំផុតជាងសត្វទាំងឡាយ ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា **សទេវកេ ភិក្ខវេ លោកេ ។ បេ ។ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី តស្មា តថាគតោតិ វុច្ចតិ ។**

ប្រែថា : ម្នាលភិក្ខុទាំងឡាយ តថាគត ជាអ្នកធំក្រៃលែង ពុំមានអ្នកណាគ្របសង្កត់បាន ទ្រង់ឃើញនូវរបស់គ្រប់យ៉ាង ញ៉ាំងសត្វលោកព្រមទាំងទេវលោក ។ ល ។ ឱ្យនៅក្នុងអំណាច ក្នុងពពួកសត្វព្រមទាំងទេវតានិងមនុស្ស ពាក្យពោលទេសនាទាំងឡាយដូចជាឱសថសក្តិសិទ្ធិ និងធ្វើឱ្យមានការសន្សំបុណ្យ ទុកក្នុងខ្លួន ។ ព្រះដ៏មានព្រះភាគមានអនុភាពច្រើន ទ្រង់ញ៉ាំញី ពួកសត្វដែលទទឹងរឹងរូស ដូចពេទ្យបង្ក្រាបសត្វពស់ ដោយ ថ្នាំទិព្វដូច្នោះ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ប្រើពាក្យពិសេស ក្នុងការពោលវាចាដោយពិតតាមសេចក្តីពិត មិនប្រែប្រួលក្នុងការគ្របសង្កត់លោកទាំងពួង ដូចមានសម្តែងនៅក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេសភាគ ៦៧/១៨៥ ដោយព្រះគាថា

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ

អថោ អវិញ្ញាតមជានិតព្វំ

សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ

តថាគតោ តេន សមន្តចក្ខូតិ ។

ប្រែថា: វត្ថុណានីមួយៗក្នុងលោកនេះ ដែលព្រះមានព្រះភាគមិនឃើញ ឬមិនដឹង មិនគប្បីដឹង មិនមានទេ ព្រះតថាគតទ្រង់ជ្រាបច្បាស់នូវវត្ថុទាំងអស់ ដែលគួរជ្រាប ហេតុនោះព្រះតថាគតឈ្មោះថា សមន្តចក្ខុ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ឈ្មោះ **តថាគតោ** ទ្រង់ផ្លាស់អក្សរ "ទ" មកជាអក្សរ "ត" វិញ ដោយប្រការដូច្នេះ ។

ប្រការមួយផ្សេងទៀត ឈ្មោះថា តថាគត ព្រោះដឹងគឺត្រាស់ដឹងដោយសេចក្ដីពិត[(១)] អធិប្បាយថា ព្រោះដឹងដោយខ្លួនឯង រួចទើបញ៉ាំងឱ្យដឹងដល់លោកទាំងអស់ ដោយ **តីរណបរិញ្ញា** ដែលពិត ។ ឈ្មោះថា តថាគត ព្រោះលះលោកសមុទយ (តណ្ហាជា ហេតុឱ្យកើតលោក) ដោយ **បហានបរិញ្ញា ដែលពិត** ។ ឈ្មោះថា តថាគត ព្រោះចាក់ធ្លុះ លោកនិរោធ (រំលត់តណ្ហាជាហេតុ ឱ្យកើតលោក) ដោយធ្វើឱ្យពិតនូវការពិត ។

---

(១) សំដៅដល់ទីបំផុតលោក

ឈ្មោះថា តថាគត ព្រោះទ្រង់ដំណើរទៅគឺ បដិបត្តិលោកនិរោធគាមិនីបដិបទា (បដិបទាធ្វើឱ្យដល់ការរលត់តណ្ហាជាហេតុឱ្យកើតលោក) ដោយ ភាវនាដែលពិតសមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា **លោកោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ ។បេ។ តស្មា តថាគតោតិ វុច្ចតិ ។**

ប្រែថា : ម្នាលភិក្ខុទាំងឡាយ តថាគតត្រាស់ដឹងក្រៃលែងលោក តថាគតវៀកចេញចាកលោកហើយ ម្នាលភិក្ខុទាំងឡាយ តថាគត ត្រាស់ដឹងក្រៃលែងដល់លោកសមុទយ តថាគត លះលោកសមុទយបានហើយ តថាគតត្រាស់ដឹងក្រៃលែងលោកនិរោធ តថាគត ធ្វើឱ្យជាក់ច្បាស់នូវលោកនិរោធហើយ តថាគត ត្រាស់ដឹងក្រៃលែងលោកនិរោធគាមិនីបដិបទា តថាគត ចម្រើនលោកនិរោធគាមិនី-បដិបទាជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ខ. ដែលតថាគត ត្រាស់ដឹងក្រៃលែងដល់របស់ទាំងពួង របស់ទេវលោក ព្រមទាំងមនុស្សលោកនោះ ទើបឈ្មោះថា តថាគត ដោយប្រការដូច្នេះ ។

នៅមានលក្ខណៈពិសេសដទៃផ្សេងៗ ច្រើនទៀត ដូចជាថា ព្រះសាស្តា ជាមេពួកដឹកនាំសត្វឱ្យ ឆ្លងផុតពីសេចក្តីទុក្ខ មានព្រះសូរសៀងទន់ពីរោះផ្អែមល្ហែម ព្រះសូរសៀងគួរជាទីស្រឡាញ់

ព្រះសូរសៀងជាទីគាប់ចិត្តដល់ អ្នកស្តាប់ ព្រះសូរសៀងដូច សំឡេងព្រហ្ម ព្រះសូរសៀងដូច សំឡេងសត្វករវិក ដែលផ្សាយចេញពីព្រះឱស្ឋរបស់ព្រះមាន ព្រះភាគនោះ ប្រកបដោយអង្គ ៨ គឺ ក្បោះក្បាយ ១ គប្បី ដឹងបានដោយងាយ ១ ទន់ពីរោះ ១ ស្រួលស្តាប់ ១ មូល ១ មិន បែកព្រែក ១ លាន់រំពង ១ (ស្រង់ចាកសារីបុត្តសុត្តនិទ្ទេសទី ១៦ បិដកភាគ ៦៦/២១៣ ក្នុងខុទ្ទកនិកាយមហានិទ្ទេសតតិយភាគ) ។ ព្រោះតែព្រះសាស្តា ទ្រង់ដឹង ទ្រង់ជ្រាប ទ្រង់ប្រព្រឹត្តនូវចរិយា ប្រពៃរកសត្វណាប្រៀបមិនបាន ទាំងព្រះវាចាដែលពិត ប្រកប ដោយអាការ ៨ ប្រការ ព្រមទាំងលក្ខណៈសម្បត្តិយ៉ាងច្រើន មិនអាចគណនាបាននេះហើយ ទើបធ្វើឱ្យមនុស្សម្នាមហាជន ព្រមទាំងទេវតា មារ ព្រហ្ម ផ្ញើលអបអរសាទរយ៉ាងក្រៃលែង ធ្វើឱ្យលោកធាតុញាប់ញ័រ ទៀតផង ។

តាមធម្មតាផែនដីកម្រើកញាប់ញ័រដោយហេតុ ៨ ប្រការ ដូចខាងក្រោមនេះ :

១- ធាតុកម្រើក

២- អានុភាពរបស់អ្នកមានបុណ្យ

៣- ព្រះពោធិសត្វយាងចុះកាន់ព្រះគភ៌

៤- ព្រះពោធិសត្វប្រសូតចេញចាកព្រះគភ៌នៃមាតា

៥- ទ្រង់បានចាក់ធ្លុះ នូវព្រះសម្មាសម្ពោធិញ្ញាណ

៦- ទ្រង់សម្តែងព្រះធម្មចក្រ

៧- ទ្រង់ដាក់អាយុសង្ខារ

៨- ស្តេចទ្រង់រំលត់ខន្ធបរិនិព្វាន ។ និងទ្រង់មានហេតុពិតដទៃទៀតច្រើនទៀត ដែលពុំបានលើកយកមកជម្រាបជូន ។

សុខសន្តិភាព

មកដោយពិត ទ្រង់លើកឡើងនូវព្រះគាថា **សុខោ ពុទ្ធានមុប្បាទោ** ប្រែថា : ការកើតឡើងនៃព្រះពុទ្ធទាំងឡាយនាំមកនូវសេចក្តីសុខដល់លោក ព្រោះព្រះអង្គជាធម្មរាជា ស្តេចនៃអ្នកប្រាជ្ញត្រាស់ដឹងធម៌ដែលពិត រួចនាំយកធម៌ពិតទាំងនោះមកសម្តែង មកបង្ហើបបង្ហាញនូវសេចក្តីពិតក្នុងធម្មជាតិ របស់លោក (បបញ្ចធម៌) ដែលតែងតែបៀតបៀនលោក ធ្វើឱ្យវង្វេង

ជ្រប់ងប់វិលវល់ នៅតែក្នុងវដ្តសង្សារ កើតចាស់ ឈឺ ស្លាប់ ជាធម្មតា ពុំមានមធ្យោបាយ ឬផ្លូវស្អាតល្អ យកមកជួយឧបត្ថម្ភដល់ជីវិតកំពុងទ្រុឌទ្រោមនៅក្នុងសេចក្តីតក់ស្លុតភ័យខ្លាច រាល់ថ្ងៃ ដោយភាពទន់ជ្រាយ ខ្វះភាពក្លាហានក្នុងការជួយរំដោះជីវិតខ្លួនឯងទៅរកសេចក្តីស្ងប់ ដោយប្រើបញ្ញា មកកាប់ឆ្ការកិលេសពីក្នុងចិត្តសន្តាន ដែលគិតតែពីត្រេកអរពេញចិត្តស្វែងរករបស់ពីខាងក្រៅខ្វះការពិត យកមកបបោសអង្អែលចិត្ត បោកបញ្ឆោតកុហក ត្រឹមមួយពេល ឬមួយគ្រាតូច រួចបោះបង់ចោល ឱ្យនៅកំព្រាគ្មានទីពឹង ។

ពាក្យថាជីវិត ជាផលនៃបច្ច័យរបស់តំណចិត្ត ដែលចេះតែបន្តភពជាតិរហូតពុំដឹងទីបញ្ចប់ត្រឹមណា ។ កាលបើសត្វលោកនៅមានអវិជ្ជា ពោល គឺ តណ្ហា ទិដ្ឋិ មានះ ការកង្វល់ស្រេកឃ្លានខឹងស្អប់ វង្វេង នៅតែមាន ដែលជាហេតុធ្វើឱ្យលោក ងងឹតសូន្យឈឹងមិនអាចរកកន្លែងណាឱ្យបានភ្លឺស្រឡះមើលឃើញ ពន្លឺរស្មីវិវដ្តៈឡើយ ។

ពាក្យថា អវិជ្ជា ជាឈ្មោះនៃអ្នកមានកិលេសជាប់ជំពាក់ដោយសក្កាយទិដ្ឋិ ប្រកាន់ជាប់នៅក្នុងរូប សំឡេង ក្លិន រស

ផោដ្ឋព្វៈ ជាប្រធាននៃសេចក្តីទុក្ខមានតណ្ហាដឹកនាំអាស្រ័យបច្ច័យទាក់ទងគ្នា នៅក្នុងរូបរាងកាយនៃមនុស្សសត្វ ដូចតទៅ ៖

១- អវិជ្ជា ជាបច្ច័យនាំឱ្យកើតសង្ខារ

២- សង្ខារ ជាបច្ច័យនាំឱ្យកើតវិញ្ញាណ

៣- វិញ្ញាណ ជាបច្ច័យនាំឱ្យកើតនាមរូប

៤- នាមរូប ជាបច្ច័យនាំឱ្យកើតសឡាយតនៈ

៥- សឡាយតនៈ ជាបច្ច័យនាំឱ្យកើតផស្សៈ

៦- ផស្សៈ ជាបច្ច័យនាំឱ្យកើតវេទនា

៧- វេទនា ជាបច្ច័យនាំឱ្យកើតតណ្ហា

៨- តណ្ហា ជាបច្ច័យនាំឱ្យកើតឧបាទាន

៩- ឧបាទាន ជាបច្ច័យនាំឱ្យកើតភព គឺកម្មភព

១០- កម្មភព ជាបច្ច័យនាំឱ្យកើតឧប្បត្តិភព

១១- ឧប្បត្តិភព ជាបច្ច័យនាំឱ្យកើតជាតិ

១២- ជាតិ ជាបច្ច័យនាំឱ្យកើតជរាមរណៈ ។

កាលណាអស់អវិជ្ជា វិជ្ជាកើតឡើង សេចក្ដីទុក្ខគឺ ជាតិ ជរា មរណៈ ក៏អស់ទៅដែរ ធ្វើឱ្យមនុស្សលោកលែងឈ្លោះទាស់ទែងគ្នា លែងដណ្ដើមគ្នារស់ ព្រោះអស់តណ្ហាជាសមុទយទុក្ខនោះហើយជាទីបំផុតលោក ។ នេះជាដំណើរផ្លូវត្រូវត្រង់ក្នុង **សច្ចធម៌** បើខុសពីនេះ សាកលលោកទាំងមូល ដោះស្រាយមិនរួច ព្រោះតណ្ហា ធ្វើឱ្យទំនាស់រវាងគ្នានិងគ្នាជាយថាហេតុរៀងរាល់ពេលឥតស្រាកស្រាន្ត ។

ការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ នាំមកនូវការពិតក្នុងធម្មជាតិ ទ្រង់សម្ដែងឱ្យឃើញនូវអ្វីៗក្នុងលោក ដែលពុំធ្លាប់ឃើញ ពុំធ្លាប់ដឹង ពុំធ្លាប់យល់ ឱ្យបានកាន់តែជ្រាបហាក់ដូចជាគេផ្ការបស់ផ្កាប់ ជួយដុះខាត់កិលេសទាំងឡាយឱ្យជ្រុះជាបណ្ដើរៗ រហូតបានជាសមុច្ឆេទ ។

ព្រះពុទ្ធសាសនា ជាសាសនាធម្មជាតិ ដែលព្រះអង្គទ្រង់សម្ដែងឡើងសុទ្ធតែជាធម្មៈ ជាធម៌រួចផុតចាកលោក ព្រោះធម្មជាតិ ចង្អុលបង្ហាញប្រាប់ពីការពិតទាំងអស់ បើអ្វីៗមិនពិតមិនមែនជាធម្មជាតិ ។ ធម្មជាតិមិនដែលចេះ ភូតភរកុហកកាលបើពោលយ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ដូចបាន ជម្រាបជូនមកហើយ ចំណែកលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០

របស់ព្រះដ៏មានព្រះភាគក៏ល្អស្អាតបរិសុទ្ធ ពុំមានមន្ទិល សូម្បីធូលីដីក៏មិនអាចជាប់ដល់ព្រះវរកាយព្រះអង្គបានដែរ ។

ព្រះគោតមដ៏ចម្រើន ទ្រង់ប្រតិស្ឋានស្មាមព្រះបាទទាំងគូ ដែលមានកង់ចក្រ កើតនៅត្រង់ផ្ទៃព្រះបាទខាងក្រោម **មានកាំ ១000** ព្រមទាំងខ្នងកង់និងដុំបរិបូរណ៍ទៅដោយអាការទាំងពួង នៅច្រើនកន្លែង, ទុកជាទីសក្ការៈ សម្រាប់ពុទ្ធបរិស័ទនមស្ការគោរពបូជា ។ (ដកស្រង់ពីក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក, បិដកភាគ ២៥/១០៨) ។

អត្ថន័យរបស់ពាក្យពិត

មកដោយពិត ប្រកាសនូវសភាវធម៌ទាំងឡាយ តាមសេចក្ដីពិត និងពន្យល់ប្រាប់នូវពាក្យពិត ដែលភាសាបាលី ហៅថា **សច្ច ឬសច្ចៈ**, ពាក្យសំស្ក្រឹត ហៅថា **សត្យា** ដោយសេចក្ដីថា "**ពិត**" ដែលសរសេរនៅក្នុងវ/ន សម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ ថា ដំណើរទៀងទាត់, ត្រង់ ប្រាកដ, ការណ៍មែន, អរិយមគ្គ, ព្រះនិព្វាន ។ សច្ចកាល គឺ កាលពិត ឬពេលវេលាដែលត្រូវនិយាយ ឬត្រូវប្រកាសសេចក្ដីពិត (វេវ.ភូតកាល)

ពេលនេះ ជាសច្ចកាល ជាភូតកាល របស់យើង ។ សច្ចកិរិយា គឺការធ្វើសច្ចៈ ការប្រកាសពាក្យសច្ចៈ ។ សច្ចញ្ញាណ គឺការដឹងសេចក្ដីពិត ។ ប្រាជ្ញាដែលដឹងអរិយសច្ចច្បាស់ ។ សច្ចបាន គឺការផឹកទឹកសំបថ ដើម្បីឱ្យជឿចិត្តគ្នា (យ៉ាងដូចផឹកទឹកប៉ាយហួយជាដើម). ធ្វើសច្ចបាន ។ សច្ចបារមី គឺបារមីដែលមាន សច្ចៈជាទីតាំង (ម.ព.ទសបារមីផង) ។ សច្ចប្បណិធាន គឺការតាំងប្រកាស ពាក្យពិត. ការសំបូងសង្រូង (ធ្វើសច្ចប្បណិធាន) ច្រើននិយាយ ថា សច្ចាប្រណិធានក៏បាន ។ សច្ចវាចា គឺពាក្យពិត ។ សច្ចវាទី គឺ អ្នកពោលតែពាក្យពិត ។ សច្ចានុមតិ គឺការយល់ស្របតាមសេចក្ដីពិត. សេចក្ដីនេះ អាងបញ្ជាក់ថែមតាមយថាភាពនូវអំពើ ឬពាក្យសន្យាដែលបាន ធ្វើរួចហើយ ។ សច្ចានុមតិនៃរដ្ឋសភា ។ សច្ចាប័ន ឬសត្យាប័ន ដូចគ្នា នឹងសច្ចការ ។ ល ។

ដូចបានបញ្ជាក់មកនេះ ពាក្យពិត គឺសច្ចៈ ជាឈ្មោះរបស់ធម្មៈ ដែលជាសភាវៈទៀងទាត់មិនអាចប្រែក្រឡាស់បាន កាលបើចិត្តថ្លាស្អាត មានកិរិយាប្រព្រឹត្តត្រឹមត្រូវ ជាចិត្តចូលដល់ធម៌ នឹងពិតជាបាននូវសេចក្ដីសុខ ព្រោះក្នុងលោក ពុំមានការពិតតែងផ្លាស់ប្ដូរប្រែប្រួលជានិច្ចកាល នាំមកនូវ សេចក្ដីទុក្ខ ។

សេចក្តីសុខមាននៅក្នុងសេចក្តីពិត ដែលជាកុសលប្រជុំចុះនៅក្នុងសភាវៈទាំងឡាយ មានបញ្ញាសម្រាប់រំដោះចិត្តកំព្រាដែលញាំញីដោយកិលេសតណ្ហាធ្វើឱ្យមានពន្លឺរស្មីឃើញសច្ចធម៌ ។ ដូច្នេះ ពាក្យថា **មកដោយពិត** មានតែក្នុងព្រះពុទ្ធសាសនា ជាធម៌អ្នកត្រាស់ដឹង **ព្រោះព្រះពុទ្ធសាសនា គេសិក្សាពីការអប់រំចិត្ត ចំណែកវិជ្ជាផ្លូវលោក គេសិក្សាពីការកសាងសម្ភារៈខាងក្រៅសម្រាប់សម្រួលដល់ចិត្តខាងក្នុងទៅវិញ ។** ម្យ៉ាងទៀតពាក្យថា ដោយពិត គឺពាក្យថា ដាច់ខាត ឥតសង្ស័យ ឥតងឿងឆ្ងល់ មិនបែកជាពីរ មិនមានចំពាមពីរ ជាពាក្យស្រោចស្រង់ ជាពាក្យមិនខុស ជាពាក្យតាំងមាំ(ដកស្រង់ពីក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ភាគ ៦៧/១៨៧) ។ ដទៃក្រៅពីនេះ ពុំមែនជាការពិត គ្រាន់តែជាពាក្យពោល ស្មានៗ បញ្ឆោត បន្លំ ជាសម្បកខាងក្រៅ ទោះបីមានអ្នកណាគេនិយាយថា អ្វីនោះពិត គឺអ្វីនោះមិនពិតទេ (តួទិដ្ឋិ) ព្រោះអាស្រ័យពីកិលេសតណ្ហា លើកលែងតែ កល្យាណបុថុជ្ជន និងព្រះអរិយបុគ្គល មានព្រះសោតាបន្នបុគ្គលឡើងទៅបានចាក់ធ្លុះឃើញធម៌ សមុច្ឆេទនូវកិលេស ។ ប៉ុន្តែពាក្យពិតនេះ គេអាចយកមកប្រើប្រាស់បណ្តោះអាសន្នក្នុងលោក សម្រាប់ជួយសម្រួលដល់កិច្ចការខ្លះៗ តែពុំមានជម្រៅដូចក្នុងធម៌ឡើយ ។

តាមការសិក្សាស្រាវជ្រាវសម្តែង ដោយលោកគ្រូអគ្គបណ្ឌិតជាម្ចាស់ សេចក្តីពិតមាន ៨ យ៉ាង តទៅទៀត ៖

១- វចីសច្ច ៖ សេចក្តីពិតក្នុងការនិយាយស្តី

២- សម្មតិសច្ច ៖ សេចក្តីពិតដោយការសន្មតិ

៣- បរមត្ថសច្ច ៖សេចក្តីពិតរបស់ចិត្ត ចេតសិក រូបនិងនិព្វាន

៤- សភាវសច្ច ៖ សេចក្តីពិតដោយភាពកើតឡើងនៃធម៌ជាដំបូង

៥- វិរតិសច្ច ៖ សេចក្តីពិតដោយចេតនាវៀរចាកបាប

៦- ញាណសច្ច ៖ សេចក្តីពិតដោយប្រាជ្ញាញាណ

៧- អរិយសច្ច ៖ សេចក្តីពិតដោយការឆ្លងចាកលោក

៨- និព្វានសច្ច ៖ សេចក្តីពិតដោយការរំលត់កិលេស ។

សរុបទាំងអស់ សច្ចៈមានត្រឹម ២ គឺ សម្មតិសច្ចៈ និងបរមត្ថសច្ចៈ ។

សេចក្តីពិតក្នុងការនិយាយស្តី

មកដោយពិត សម្តែងឡើងពីការពោលនូវអ្វីៗទាំងពួង គួរប្រុងប្រយ័ត្នឱ្យណាស់ដោយសេចក្តីថា ពាក្យសម្តី ជាឈ្មោះនៃវចីវិញ្ញត្តិ ក្នុងវិញ្ញត្តិរូប ២ ដែលមានចិត្តជាសមុដ្ឋាន នៅក្នុងចំណែកនៃសីលផង និងកុសលកម្មបថ ១០ ផង ។ ពាក្យពោលទាំងឡាយ ចែកចេញជាពីរចំណែក :

➤ **វាចាអាក្រក់** សំដៅទៅលើ អកុសលកម្មបថ បានដល់ពាក្យពោល បៀតបៀនខ្លួនឯងនិងអ្នកដទៃ ដុតបំផ្លាញប្រយោជន៍ឱ្យវិនាស នាំមកនូវគ្រោះថ្នាក់ដល់អាយុជីវិត ព្រោះប្រាសចាកបញ្ញា ដែលពុំទាន់បានទៅ ប៉ះពាល់ដល់រូបរាងកាយអ្នកដទៃ ឬធ្វើទុក្ខ បុកម្នេញ ដោយ កាយកម្ម វចីកម្ម ឬប្រើគេឱ្យធ្វើដោយប្រការណាមួយ ។

ពាក្យសម្តីប្រកបដោយទោស បើចែកឱ្យល្អិតទៅទៀត មាន ៤ យ៉ាង :

១- **មុសាវាចា** : ការពោលមិនពិតជាពាក្យកុហក បោកប្រាស់

២- **បិសុណាវាចា** :ពោលពាក្យញុះញង់បំបែកបំបាក់

៣- **ផរុសវាចា** : ពោលពាក្យអាក្រក់ទ្រគោះបោះបោក ដូចជាគេកាប់ចិញ្ច្រាំដោយពូថៅ

៤- **សម្ផប្បលាបោ** :ពោលពាក្យរោយរាយឥតប្រយោជន៏ ពោលពាក្យមិនជាអត្ថ មិនជាធមិ ប្រៀបដូចជាគេទូងស្គរ គ្រាន់តែដើម្បីឱ្យឮសំឡេងប៉ុណ្ណោះ ។ ពិតមែនតែយើង មានសិទ្ធិនឹងនិយាយស្តី តែបើពោលពាក្យអសប្បុរស វាចាលាមក ៤ ជំពូកនេះ ទោសទុក្ខទាំងឡាយត្រូវធ្លាក់ មកលើខ្លួនយើង ហាក់ដូចជាស្រែកហៅឱ្យគេមកបៀតបៀន ឬប្រហារខ្លួនឯង ដោយមិនដឹងខ្លួន ដូចជាកង្កែប ចូលរូងក្តាម រួចស្រែកឱ្យគេដឹង ទីបំផុតត្រូវស្លាប់ ទាំងពីរ ព្រោះពាក្យសម្តី ។

➢ **វាចាប្រកបដោយគុណ** ក្នុងកុសលកម្មបថ បានដល់កុសលធមិជួយធ្វើឱ្យគេបានសុខស្ងប់ ជាវាចាប្រាសចាកនូវពាក្យអាក្រក់ ៤ ជំពូក ជាវាចារបស់សប្បុរស ចេះពោលតែពាក្យពិត

មិនកុហក ពាក្យណាមិនមានអត្ថ មិនមានប្រយោជន៍ដល់អ្នកស្តាប់ មិនពោលឡើយ ព្រោះពាក្យសម្តីជាខ្លឹមរបស់សច្ចភាព បើចិត្តគិតយ៉ាងណា ការពោលស្តីក៏ធ្វើយ៉ាងនោះ ដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះគាថាទុក ។

មនោ បុព្វង្គមា ធម្មា មនោ សេដ្ឋា មនោមយា

មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា

តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី

ប្រែថា : ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត អ្វីៗសម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តី ធ្វើក្តី ក៏ល្អទាំងអស់ ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងនៅជាប់បុគ្គលនោះ ដូចស្រមោលអន្ទោលតាមប្រាណយ៉ាងដូច្នោះឯង ។

ម្យ៉ាងទៀតវាចាល្អ ជាការកសាងបញ្ញាក្នុងព្រះពុទ្ធសាសនា ធ្វើឱ្យរីកចម្រើនខាងផ្លូវចិត្ត សន្សំបានជាឧបនិស្ស័យ សម្រាប់ឆ្លងវដ្តសង្សារនាំមកនូវសេចក្តីសុខស្ងប់ ។ ក្នុងបវត្តិកាលជួយឧបត្ថម្ភដល់ជីវិតខ្លួនឯងឱ្យមានសេចក្តីថ្លៃថ្នូរ ប្រកបដោយចិត្ត មេត្តា ករុណា មុទិតា និងឧបេក្ខា ដែលពួកសត្វលោកត្រេកអរពេញចិត្ត

និងសូមឱ្យពរសព្ទសាធុការ រហូតដល់ជួយជ្រោមជ្រែងហែរហម ថែរក្សាការពារ មិនឱ្យមានអន្តរាយអ្វីមកបៀតបៀន ដោយអំណាចគុណធមិ ។ ចំណែកផលសម្រេច ទៀងតែមានពិតប្រាកដ ទោះបីពាក្យនោះអាក្រក់ ល្អ យ៉ាងណា ដូចជាការអនុមោទនាបុណ្យជាដើម ដែលមានរឿងតំណាលពីការអនុមោទនាបុណ្យ របស់មិត្តសម្លាញ់នាងវិសាខា ក្នុងពេលនាងបានធ្វើ **បតិទានមយ:** ក៏មិត្តរបស់នាងទាំងនោះ បានទទួលនូវចំណែក បុណ្យពិតប្រាកដ ។

ម្យ៉ាងទៀត ខាងផ្នែកអាក្រក់វិញ ដូចជា សុប្បពុទ្ធកុដ្ឋិកាលពី អតីតជាតិ បានពោលប្រមាថមើលងាយដល់ព្រះបច្ចេកពុទ្ធមួយព្រះអង្គថា សមណៈនេះឃ្លំជីពរ ដូចមនុស្សកើតឃ្លង់ លុះស្លាប់ទៅក៏ត្រឡប់ កើតជាមនុស្សឃ្លង់មែន ព្រោះមានការពោលតិះដៀលដល់បុគ្គលអ្នកមានគុណធមិខ្ពង់ខ្ពស់រកអ្វីប្រៀបពុំបាន ។

សេចក្តីនេះ មានយ៉ាងណា ក្នុងការពោលស្តី អាចនាំឱ្យមានទោស ឬកើតបុណ្យ សូមមេត្តាមានការប្រុងប្រយ័ត្ន កុំចេះតែ និយាយលេងសើចឥតប្រយោជន៍ ។ ការពោលពាក្យមានប្រយោជន៏ ដូចជាព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ធ្វើឱ្យ

សត្វលោកស្តាប់យល់ បានសម្រេចមគ្គផលច្រើនរាប់មិនអស់ ព្រមទាំងពួកទេវតាថ្នាក់ទាប ថ្នាក់ខ្ពស់ឡើងទៅក៏ត្រេងត្រាប់ស្តាប់ចាប់យកបាន គ្រប់ៗគ្នា ។

សេចក្តីពិតក្នុងសម្មតិសច្ចៈ

មកដោយពិត នាំយកនូវពាក្យសន្មត ហៅតាមការបញ្ញត្តិរបស់សភាវសច្ចៈដែលជាឈ្មោះនៃការពិតដោយសន្និតបានដល់ បញ្ញត្តិធម៌ មានអត្ថន័យជ្រាលជ្រៅ លុះត្រាតែមានអ្នកត្រាស់ដឹងធម៌ ទើបអាចសម្តែងប្រាប់ឱ្យយល់ស្តាប់បាន ។

ព្រះយោគាវចរ អ្នកមានការព្យាយាមសិក្សាបដិបត្តិព្រះធម៌ក៏ ត្រូវឱ្យហ្មត់ចត់ល្អិតល្អន់ ក្នុងការអប់រំបញ្ញាចូលដល់រូបធម៌ នាមធម៌ ថ្នាក់នាមរូបបរិច្ឆេទញ្ញាណ ជាប្រាជ្ញាចែករូបធម៌ នាមធម៌ ឱ្យដាច់ចេញពីគ្នារហូតដល់វិបស្សនាញ្ញាណថ្នាក់លើក៏ នៅមិនទាន់យល់ ឱ្យបានច្បាស់លាស់ដែរ ព្រោះបញ្ញត្តិអាស្រ័យ បរមត្ថ បើគ្មានបរមត្ថ បញ្ញត្តិក៏មិនមាន ។

បរមត្ថ គឺសភាវពិត បានដល់រូបធម៌នាមធម៌ សម្រាប់អ្នកត្រាស់ដឹងធម៌ឃើញធម៌ ឯបញ្ញត្តិសម្រាប់មហាជនអាស្រ័យវដ្តទុក្ខនៅក្នុងបដិច្ចសមុប្បាទ មានទុក្ខសច្ចៈនិងសមុទយសច្ចៈ ដែលតែងតែអន្ទោលទៅស៊ុះទៅក្នុងសង្សារវដ្តជារឿយៗ របស់ខន្ធបញ្ចកៈ ។

ពាក្យបញ្ញត្តិមានច្រើនដូចជា ហៅថា មនុស្ស សត្វ ប្រុស ស្រី ដើមឈើ ព្រៃភ្នំ បឹង ទន្លេ សមុទ្ទ អាកាស ជាដើម ។ល។ ទាំងអស់នេះសុទ្ធតែជាធម៌ កើតឡើងអាស្រ័យបច្ច័យគ្រប់គ្រាន់របស់ខ្លួនឯង ដែលពុំមានអ្នកណាម្នាក់មានអំណាចទៅរៀបចំចាត់ចែង ធ្វើឱ្យសង្ខារលោកទាំងនេះមានហើយត្រឡប់ទៅជាមិនមានទៅវិញដោយប្រការផ្សេងៗ ព្រោះលោកទាំងអស់មិនទៀងឋិតថេរ ឱ្យតែមានការកើត ការវិនាសទៅវិញជារឿងធម្មតា ។

ក៏ប៉ុន្តែសត្វលោក មិនអាចមានសមត្ថភាព ឃើញសច្ចធម៌ គឺ សេចក្តីពិតក្នុងបញ្ញត្តិ ក៏តែងតែសម្គាល់ទៅតាមរឿងដែលធ្លាប់មានមកពីដើម ដោយសម្គាល់ថានេះ សត្វ បុគ្គល ស្រី ប្រុស គេ យើង ព្រៃ ភ្នំ ដើមឈើ សមុទ្ទ អាកាស តាមការធ្លាប់ចំណាំទុកមក ។ បរមត្ថជាគន្លងនៃបញ្ញត្តិ កាលបើស្គាល់បរមត្ថហើយ

អាចដឹងស្គាល់បញ្ញត្តិបាន ដូចនៅក្នុង វជិរាសូត្រ សំ-ស-ភ/១៥ ខ.៥៥៤ របស់អភិធម្ម ជោតិកៈថា ៖

យថា ហិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ

ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោតិ សម្មុតិ ។

ប្រែថា ៖ សេចក្តីពិត កាលណាខន្ធទាំងឡាយមាន ការសន្មតិហៅថា សត្វក៏មានឡើង ដូចហៅថា រថ ក៏ព្រោះយកចំណែកផ្សេងៗ មកប្រជុំរួមចូលគ្នាយ៉ាងដូច្នោះ ។ តែអ្នកស្គាល់នោះមានតិចគ្នាណាស់ លុះត្រាតែសិក្សាបដិបត្តិអប់រំសតិប្បដ្ឋាន ឱ្យមានប្រាជ្ញាចម្រើនឡើងតាមលំដាប់ថ្នាក់វិបស្សនាញាណ ១៦ រហូតចាក់ធ្លុះនូវសភាវធម៌តាមសេចក្តីពិត ទើបស្គាល់បញ្ញត្តិដែលសម្តែងដោយលោកគ្រូ អគ្គបណ្ឌិតជាម្ចាស់ ព្រោះហេតុនោះបានជាមានអ្នកចាក់ធ្លុះឃើញធម៌ ត្រឹមតែស្តាប់នូវពាក្យសម្តែងធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ការសម្តែងធម៌ ជាវោហារទេសនាលើកយកពីបុគ្គលបញ្ញត្តិក៏ពិតមែន តែបង្កប់នូវបរមត្ថធម៌ខាងក្នុងធ្វើឱ្យយើងមិនយល់ដឹង លុះត្រាតែមានការព្យាយាមអប់រំឱ្យស្គាល់ពីលក្ខណៈរបស់សភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ នឹងអាចជ្រាបបាន ដូចជាព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងធម៌ ក៏ដោយសារ

ទ្រង់ជ្រាបពីធាតុទាំងឡាយ រួចលើកឡើងពីសភាវបដិច្ចសមុប្បាទមកពិចារណា សាចុះសាឡើងក៏បានឃើញនូវ អរិយសច្ចៈទាំង ៤ គឺ ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និងមគ្គសច្ចៈ ដោយព្រះអង្គឯង ពុំមានគ្រូអាចារ្យណាបង្ហាត់បង្រៀនឡើយ ។

ក្នុងន័យនេះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះទ័យខ្វល់ខ្វាយតិចដោយទ្រង់ត្រិះរិះពិចារណាថា ធម៌ដែលតថាគតទ្រង់ត្រាស់ដឹង សត្វលោកមិនងាយនឹងត្រងត្រាប់ស្តាប់បាន ព្រោះសត្វទាំងនោះ កំពុងត្រេកត្រអាលដោយឆន្ទរាគៈងងឹតបិទបាំងជិតព្រោះអវិជ្ជាកំពុងចាក់ស្រេះ មុខជានឹងមិនយល់ធម៌សម្រាប់នាំសត្វឱ្យដល់ព្រះនិព្វាន ជាធម៌ល្អិតសុខុមជ្រាលជ្រៅដែលសត្វ ឃើញបានដោយកម្រ ។ ក្នុងខណៈពេលនោះភ្លាម សហម្បតិព្រហ្មបានជ្រាបនូវព្រះបរិវិតក្កៈក្នុងព្រះហឫទ័យ នៃព្រះដ៏មានព្រះភាគក៏បាត់អំពីព្រហ្មលោក, យាងចុះមកប្រតិស្ឋាននៅចំពោះព្រះភក្ត្រ ព្រះដ៏មានភាគ ក៏សូមនិមន្ត ឱ្យព្រះអង្គទ្រង់សម្តែងធម៌ អស់វារៈ ៣ ដង ។

ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់នឹងមហាព្រហ្មនោះ ដោយព្រះគាថា ដូច្នេះថា

អបារុតា តេ អមតស្ស ទ្វារា

យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

វិហឹសសញ្ញី បគុណំ ន ភាសឹ

ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

ប្រែថា ទ្វារនៃព្រះនិព្វាន គឺអរិយមគ្គ បើកដល់អ្នកហើយ សត្វទាំងឡាយណាមានសោតប្បសាទ សត្វទាំងនោះចូរបញ្ចេញនូវសទ្ធាមកចុះ ម្នាលព្រហ្ម តថាគតសម្គាល់នូវសេចក្តីនឿយលំបាក បានជាមិនទាន់សម្តែងធម៌ដ៏ឧត្តម ដែលតថាគត ស្ទាត់ហើយក្នុងសម្នាក់មនុស្សទាំងឡាយ (ដកស្រង់ពីក្នុងទីឃនិកាយ មហាវគ្គ បិដកលេខ ១៦/៨៣) ។

នេះជាពុទ្ធនិយាមគ្រប់ៗព្រះពុទ្ធអង្គ នៅពេលបានត្រាស់ដឹងធម៌ ត្រូវតែមានមហាព្រហ្ម ចុះមកសូមអារាធនា ឱ្យទ្រង់សម្តែងធម៌ ម្ល៉ោះហើយបានជាសម័យសព្វថ្ងៃ កាលណា មានធ្វើពិធីបុណ្យអ្វីម្តងៗហើយមាននិមន្តព្រះភិក្ខុសង្ឃជាធម្មកថិកសម្តែងធម្មទេសនា ត្រូវតែមានអារាធនាលំនាំបទ ព្រហ្មជាមុន ។

ក្នុងការសម្តែងធម៌ ព្រះអង្គទ្រង់លើកឡើងពីបុគ្គលប្បញ្ញត្តិជាវោហារទេសនា ល្មមឱ្យសត្វត្រងត្រាប់ចាប់យកស្តាប់ បាន

ទៅតាមចំណោះដឹងរៀងៗខ្លួន របស់ធម្មជាតិដែលមាន ត្រឹមតែខន្ធ ធាតុអាយតនៈរហូតដល់បានសម្រេចមគ្គផល យ៉ាងច្រើនរាប់មិនអស់ ដូចទ្រង់សម្តែងព្រះធម្មទេសនាប្រោស ពួកបញ្ចវគ្គិយនៅព្រៃឥសិបតនមិគទាយវ័ន សព្វថ្ងៃហៅថា សារាណាថ។ ម្យ៉ាងទៀត នៅក្នុងអដ្ឋកថា វេបុល្លបព្វតសូត្រ ឧទ្ទកនិកាយលេខ ៤៥ ភាគ ៤/១៦០ ព្រះដ៏មានព្រះភាគត្រាស់ បុគ្គលកថា ដោយហេតុ ៨ ប្រការ ដើម្បីសម្តែងដល់ហិរិ និងឱត្តប្បៈ ១ ដើម្បីសម្តែងសេចក្តី ដែលសត្វទាំងឡាយ មាន កម្មជារបស់ខ្លួន ១ ដើម្បីសម្តែងសេចក្តីព្យាយាមចំពោះខ្លួន ១ ដើម្បីសម្តែងអនន្តរិយកម្ម ១ ដើម្បី សម្តែងព្រហ្មវិហារធម៌ ១ ដើម្បីសម្តែងបុព្វេនិវាសានុស្សតិញាណ ១ ដើម្បីសម្តែង ទក្ខិណាវិសុទ្ធិ ១ ដើម្បីមិនលះលោកសម្មតិ ១ ។

សេចក្តីពិស្តារ

មកដោយពិត អធិប្បាយពង្រីកនូវហេតុ ៨ ប្រការ :

១- **ដើម្បីសម្តែងហិរិនិងឱត្តប្បៈ** សង្ខារធម៌គាត់តែងឡើងពីហេតុប្បច្ច័យ ពុំមានសត្វបុគ្គលអ្នកប្រព្រឹត្តធ្វើអំពើអ្វីឡើយ

តែងកើតឡើងរឿយៗ និងវិនាសទៅវិញក៏រឿយៗ ។ ហិរិនិង ឱត្តប្បៈ ជាទេវធម៌ផង ជាលោកបាលធម៌របស់សត្វទាំងឡាយ ផង ជាអារម្មណ៍ ដែលមានការខ្មាសខ្លើមបាបផង ។ កាលណា ពោលពីខន្ធ ធាតុ អាយតនៈ ខ្មាស ខ្លើមបាប គួររង្កៀស គួរខ្លាច មហាជនរមែង វង្វេង ព្រោះស្តាប់មិនបាន ។ លុះពោលថា សត្វបុគ្គល ស្រី ប្រុស ក្សត្រិយ៍ ព្រាហ្មណ៍ គួររង្កៀសគួរខ្លាច មហាជនរមែងដឹងមិនវង្វេង ព្រោះហេតុដូច្នោះ ទើបត្រាស់ បុគ្គលកថា ដើម្បីសម្តែង ហិរិ និងឱត្តប្បៈ ។

២- **ដើម្បីសម្តែងសេចក្តី ដែលសត្វទាំងឡាយមានកម្មជា របស់ខ្លួន** : ពាក្យថាកម្មស្សកតា ត្រូវយកបុគ្គលបញ្ញត្តិមក សម្តែងទៀត ដើម្បីចៀសវាងពីការមិនដឹង ព្រោះបើពោល ត្រឹមតែខន្ធ ធាតុ អាយតនៈ ក៏មានន័យនេះដូចគ្នា ព្រោះហេតុ ដូច្នោះ ព្រះអង្គទើបត្រាស់បុគ្គលកថា ដើម្បីសម្តែងសេចក្តី ដែលសត្វទាំងឡាយមាន កម្មជារបស់ខ្លួន ។

៣- **ដើម្បីសម្តែងសេចក្តីព្យាយាមចំពោះខ្លួន** : ដោយថា ការ ប្រព្រឹត្តធ្វើអ្វីៗត្រូវមានការព្យាយាម មានការសិក្សា រៀនសូត្រ ការអំណត់អត់ធន់ ដូចជាធ្វើស្រែចំការច្បារដំណាំ ការងារនៅ ការិយាល័យ ការធ្វើសំណង់អ្វីមួយ មានសំណង់ អាគារឬ

មហាវិហារវត្តវេឡុវ័នជាដើម ត្រូវតាំងចិត្តព្យាយាម ប្រសិនបើពោលថា ខន្ធ ធាតុ អាយតនៈជាអ្នកប្រព្រឹត្ត នូវអំពើទាំងនោះ មហាជនមិនដឹង ព្រោះហេតុដូច្នោះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវបុគ្គលប្បញ្ញត្តិ ។

៤- **ដើម្បីសម្តែងអនន្តរិយកម្ម** : រឿងនេះមានយ៉ាងណា កាលបើពោលថា ខន្ធ ធាតុ អាយតនៈសម្លាប់មាតាបិតា សម្លាប់ព្រះអរហន្ត ធ្វើសង្ឃភេទ ក៏មានន័យដូចគ្នាដែរ ត្រូវតែលើកយកបុគ្គលបញ្ញត្តិ ទើបមហាជន មិនវង្វេង ហើយស្តាប់បាន តែសេចក្តីពិត គឺ ខន្ធ ធាតុ អាយតនៈ នេះឯងជាសង្ខារធម៌ និង ជាអ្នកសម្លាប់ ។

៥- **ដើម្បីសម្តែងព្រហ្មវិហារធម៌** : ក្នុងការសម្តែងនូវព្រហ្មវិហារធម៌ ដែលជាជម្រករបស់សត្វទាំងឡាយ ដោយមេត្តា ករុណា មុទិតា ឧបេក្ខា ត្រូវតែមានសត្វជាអារម្មណ៍ កាលបើពោលថា ខន្ធ ធាតុ អាយតនៈ មហាជន វង្វេងស្តាប់មិនបាន ម្ល៉ោះហើយ ទើបព្រះដ៏មានព្រះភាគលើកយកបុគ្គលបញ្ញត្តិមកសម្តែងទៀត ។

៦- **ដើម្បីសម្តែងបុព្វេនិវាសញ្ញាណ** : តាមធម្មតា ការរលឹកដល់បុព្វេនិវាស ជាការប្រព្រឹត្តទៅក្នុងចិត្តរបស់សត្វទាំងឡាយ ដែលបាននូវអភិញ្ញា ហើយក៏មិនមែនដទៃអ្វីក្រៅពីចិត្ត ចេតសិក តែបើពោលថា ខន្ធ ធាតុ អាយតនៈ រលឹក ក៏ស្តាប់មិនបានដូចគ្នា ហេតុនេះ ទើបព្រះដ៏ មានព្រះភាគទ្រង់លើកឡើងពីបុគ្គលបញ្ញត្តិ ។

៧- **ដើម្បីសម្តែងទក្ខិណាវិសុទ្ធិ** : ទក្ខិណាវិសុទ្ធី (ការបរិសុទ្ធ និងមិនបរិសុទ្ធរបស់ទាន) មាន ៤ យ៉ាង ។ នៅក្នុងវិភង្គ ទក្ខិណាវិភង្គសូត្រ ទក្ខិណាវិសុទ្ធី បិដកលេខ ២៨/២២៧ មជ្ឈិមនិកាយ ឧបរិបណ្ណាសក នវមភាគ ទ្រង់ត្រាស់ថា ម្នាល អានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឱ្យ មិនបរិសុទ្ធខាងអ្នកទទួល ១ ម្នាល អានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឱ្យ បរិសុទ្ធខាងអ្នកទទួល ១ ម្នាល អានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឱ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ១ ម្នាល អានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឱ្យផង បរិសុទ្ធខាងអ្នកទទួលផង មហាជនអាចស្តាប់បាន តែបើពោល ថា ខន្ធ ធាតុ អាយតនៈក៏មហាជនវង្វេង ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់បុគ្គលកថា ដើម្បីសម្តែងទក្ខិណាវិសុទ្ធិ ។

៨- **ដើម្បីមិនលះលោកសម្មតិ** : ព្រោះទ្រង់សម្តែងធម៌យ៉ាងល្អ ឥតខ្ចោះតាំងនៅជាសាមញ្ញរបស់លោក ដើម្បីជួយរំដោះទុក្ខដល់សត្វទាំងឡាយ មិនទ្រង់សម្តែងចងសត្វទុកក្នុងភព ដូច្នោះ ត្រូវរកវិធីឬមធ្យោបាយយ៉ាងណា តាមព្រះប្រាជ្ញាញាណ ក្នុងការជួយសម្រួល ឱ្យសត្វបានយល់ជ្រាបចាក់ធ្លុះនូវអរិយសច្ចធម៌ ។ ចំណែកធម៌ដែលត្រាស់ដឹងនោះ ជាបរមត្ថមែនហើយ ប៉ុន្តែបើទ្រង់សម្តែងពីបរមត្ថសុទ្ធ ក៏មិនអាចនឹងជួយសត្វលោកឱ្យរួច ពី

ទុក្ខ គ្រាន់តែថា សត្វខ្លះមានធូលីក្រាស់ស្តើងបានដល់ពួកកិលេស ដែលធ្វើឱ្យ ព្រះពុទ្ធអង្គជ្រើសរើសតាំងពីពេលវេលា ឡើងទៅ សូម្បីមិនទាន់ដល់កាល ឬខ្វះកន្លះបន្តិចបន្តួចក្តី ក៏ ព្រះពុទ្ធអង្គ ទ្រង់រង់ចាំដែរ ។ ដោយហេតុដូច្នោះ ទើបព្រះអង្គទ្រង់ត្រាស់ បុគ្គលកថា ជាសម្មតិវោហារ ក្នុងប្រសូត្រ ។

ម្យ៉ាងទៀត ពួកសត្វខ្លះជាតិហេតុកបុគ្គល មានប្រាជ្ញា ក្រាស់មកពីនាយ ក៏អាចស្តាប់ធមិចាក់ធ្លុះនូវអរិយសច្ចធមិយ៉ាង រហ័សភ្លាម គ្រាន់តែព្រះអង្គទ្រង់សម្តែងធមិបន្តិចបន្តួច អាច ត្រងត្រាប់ចាប់យកបាន ពុំចាំបាច់ប្រើវោហារទេសនាជាសម្មតិ ត្រឹមតែជាបរមត្ថធមិប៉ុណ្ណោះ ដូចយ៉ាងព្រះពាហិយជាដើម ។

ដូច្នោះការសម្តែងធមិរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់មាន ២ យ៉ាង :

ទី១- ជាសម្មតិវោហារ ក្នុងព្រះសូត្រហៅថា វោហារ ទេសនា ដោយលើកឡើងពីបុគ្គលប្បញ្ញត្តិ ដើម្បីធ្វើឱ្យសត្វងាយ យល់ជ្រួតជ្រាបបាន ។

ទី២- លើកឡើងពីបរមត្ថសុទ្ធគឺ ខន្ធ ធាតុ អាយតនៈ ហៅថា បរមត្ថទេសនាក្នុងព្រះអភិធម្ម ដែលសត្វលោកមាន

ប្រាជ្ញាច្រើន គឺប្រាជ្ញាមានមកពីកំណើត ឈ្មោះថា សជាតិកបញ្ញា ក៏ឆាប់ត្រេងត្រាប់ស្តាប់យល់បានសម្រេចមគ្គផលយ៉ាងរហ័ស ។

សេចក្តីពិតក្នុងបរមត្ថសច្ចៈ

មកដោយពិត ទ្រង់បង្ហើបឱ្យដឹងនូវអាថិកំបាំងរបស់សច្ចធម៌ ដែលមានសុទ្ធតែបរមត្ថធម៌ ។

អ្វីទៅហៅថា បរមត្ថ ?

ពាក្យថា បរមត្ថ បានដល់ ធម៌មានអត្ថដ៏ឧត្តមក្រៃលែង (ព្រះអភិធម្ម), **ពាក្យសត្យ, ជាសេចក្តីពិតដែលបញ្ជាក់ប្រាប់នៅក្នុងវ/នរបស់សម្តេចព្រះសង្ឃរាជ ជួន-ណាត ជោតញ្ញាណោ ។ ដូច្នោះ** ពាក្យបរមត្ថសំដៅដល់ ចិត្ត ចេតសិក រូប និងនិព្វាន តែក្នុង ទីនេះ លើកឡើងត្រឹម ចិត្ត ចេតសិក រូប ។

ការសិក្សាពីបរមត្ថធម៌ ក៏ជាការកម្រមួយក្នុងព្រះពុទ្ធសាសនា ព្រោះជាធម៌ត្រាស់ដឹងរបស់ព្រះដ៏មានព្រះភាគ ដែលពុំមានអ្នកប្រាជ្ញណាឬសាសនាដទៃណា មកបង្ហាត់បង្រៀន

ព្រះអភិធម្ម គឺចិត្ត ចេតសិករូប និងនិព្វាន ឱ្យបានយល់ជាក់ច្បាស់ពិតប្រាកដរបស់ធម្មជាតិនៅក្នុងខ្លួនយើង ដូចព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹង ។ កាលបើមិនមានព្រះពុទ្ធអង្គ ព្រះអភិធម្មនៅក្នុងខ្លួនយើងម្នាក់ៗ ពុំមានបុគ្គលណា ឬបរិស័ទណានឹកឃើញលើកយកមកសម្តែងឱ្យបានដឹង ដែលទ្រង់សម្តែងប្រោសពុទ្ធមាតានៅឋានតាវត្តិង្ស ក្នុងរវាងវស្សាទី ៧ និងទី ៨ ។

ព្រះអភិធម្ម ជាមូលដ្ឋាននៃការពិតរបស់សច្ចធម៌ សម្រាប់អ្នកបដិបត្តិ ដើម្បីរំដោះខ្លួនចេញចាកទុក្ខ គ្រាន់តែថា ក្នុងលោកសព្វថ្ងៃ ពុំទាន់មានអ្នកណាមួយបានសម្រេចមគ្គផល សម្តែងដោយលោកគ្រូអគ្គបណ្ឌិតជាម្ចាស់ ចំណែកនៅទេវលោកវិញ មានព្រះអរិយបុគ្គលយ៉ាងច្រើន ស្ថិតនៅតាំងពីសម័យ ព្រះសម្មាសម្ពុទ្ធគង់ធរមានម្ល៉េះ ដូចជាព្រះនាងវិសាខា អនាថបិណ្ឌិកសេដ្ឋីជាដើម ។

ពាក្យថា បរមត្ថធម៌ គេបង្ហាញប្រាប់ពីជីវិតពិតរបស់ខន្ធ ៥ បានដល់រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលតែងតែ កើតឡើងហើយត្រូវវិនាសប្រែប្រួលទៅវិញជាធម្មតា ពុំមានម្ចាស់ ហួងហែងថែរក្សា ជ្រោមជ្រែងទប់ស្កាត់យ៉ាងណាថា កុំឱ្យបែក ធ្លាយទៅវិញ ហៅថា អនត្តាធម៌ ដែលជាការពិតរបស់ ខន្ធ ថាកុំឱ្យឈឺ ចាស់ ស្លាប់ មិនបាន ។ បទនេះ

គ្រាន់តែលើកឡើងពីសេចក្ដីពិតរបស់បរមត្ថធម៌ ដែលធ្លាប់បាន សិក្សាខ្លះៗ រួចមកហើយ ដោយបានសរសេរចងក្រងទុកក្នុង សៀវភៅ ក្រសែជីវិត និងលោកទស្សនៈ បើចង់ជ្រាបច្បាស់ ជាងនេះ សូម សិក្សាស្រាវជ្រាវតទៅទៀតផងចុះ ។

ចិត្ត ចេតសិក រូប របស់ខន្ធទាំង ៥ ដែលសន្មតិហៅថា ខ្លួន នោះឯង ឯការពិតវិញ ជាបរមត្ថសុទ្ធ ព្រោះពុំមានតួខ្លួន អ្នកធ្វើអ្វីៗ មានត្រឹមតែសង្ខារធម៌តាក់តែងឡើងពីហេតុប្បច្ច័យ ប៉ុណ្ណោះ ។ រូបជាធាតុមិនដឹង ឯនាមក្ខន្ធ ៤ ជាអ្នកធ្វើសកម្មភាព នៅក្នុងរូបរាងកាយនៃយើង ។ ចិត្តមានត្រឹម ១ ដួង ចែកចេញជា អកុសល កុសល និងអព្យាកតៈត្រូវជា ៨៩ ដួង ឬ ១២១ ដួង ដោយពិស្ដារ ។ ចិត្ត កើតឡើងដឹងអារម្មណ៍ បើពុំមានអារម្មណ៍ តាមចក្ខុទ្វារ តាមសោតទ្វារ តាមឃានទ្វារ តាមជិវ្ហាទ្វារ តាមកាយទ្វារ តាមមនោទ្វារ ចិត្តមិនអាចកើតឡើងបាន សំខាន់ គឺទ្វារវិថីចិត្តនេះឯង ។ **លក្ខណាទិចតុក្កៈ** របស់ ចិត្ត

១- **វិជាននលក្ខណំ** : ចិត្តមានការដឹងអារម្មណ៍ ជាលក្ខណៈ

២- **បុព្វង្គមរសំ** : ចិត្តមានការកើតមុន និងជាប្រធានក្នុង ធម៌ទាំងពួង ជាកិច្ច

៣- **សន្ទានបច្ចុប្បដ្ឋានំ** :ចិត្តមានការកើតឡើងបន្តគ្នា មិនដាច់ ជាផល ឬជាអាការប្រាកដ

៤- **នាមរូបបទដ្ឋានំ** : មាននាមរូបឱ្យកើត ជាហេតុជិត ។

ការពិតរបស់លោកសុទ្ធតែជាធាតុទាំងអស់ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹង ប្រសិនបើមិនទ្រង់បញ្ញត្តហៅយ៉ាងនេះទេ មិនអាចស្គាល់ថាអ្វីឡើយ ដូច្នោះទើបបានកំណត់នូវវិសេសលក្ខណៈ គឺ លក្ខណាទិចតុក្កៈ ទុកសម្គាល់និងដើម្បីសិក្សាឱ្យបានយល់ ក្នុងកិច្ចកម្ចាត់កិលេស ចេញពីខន្ធសន្តានរបស់សភាវៈនិមួយៗ តាមមុខនាទីរៀងៗខ្លួន ។

៥. លក្ខណាទិចតុក្កៈ របស់ ចេតសិក

១- **ចិត្តនិស្សិតលក្ខណំ** : ចេតសិកអាស្រ័យនឹងចិត្តទើបកើតឡើង ជាលក្ខណៈ

២- **អវិយោគុប្បាទនរសំ** : ចេតសិកមានការកើតរួមជាមួយចិត្ត ជាកិច្ច

៣- **ឯកាលម្ពណបច្ចុប្បដ្ឋានំ** : ចេតសិកមានការទទួលអារម្មណ៍ម្យ៉ាងជាមួយចិត្ត ជាផល

៤- **ចិត្តុប្បាទបទដ្ឋាន៍** : ចេតសិកមានការកើតឡើងជាមួយចិត្ត ជាបទដ្ឋាន ។

សភាវធម៌ទាំងពីរនេះ កើតឡើងនិងរលត់ជាមួយគ្នា ដែលចិត្តមួយដួងៗ កើតឡើងត្រូវមានចេតសិកសម្បយោគ យ៉ាងតិចត្រឹម ៧ គឺ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ និង មនសិការ ជាតួសព្វចិត្តសាធារណចេតសិក និង យ៉ាងច្រើន ៣៨ គឺ អញ្ញសមានាចេតសិក ១៣ និង សោភណចេតសិក ២៥ ។ ការកើតឡើងនៃ ចិត្តចេតសិក គឺជាការកើតឡើងនៃនាមធម៌ អាស្រ័យពីរូបធម៌ ដែលមាន ចេតសិក ជាអ្នកតាក់តែងចិត្តឱ្យល្អឬអាក្រក់ ក្នុងជីវិតប្រចាំថ្ងៃ ទៅតាមកម្លាំងរបស់កម្មវដ្ដៈ ជានិច្ចនិរន្តរបស់ ក្រសែជីវិតម្នាក់ៗ ពុំមាន សត្វ បុគ្គល អ្នកធ្វើកិច្ចអ្វីឡើយ ។

បរមត្ថធម៌មួយទៀត គឺ រូប ជាធាតុមិនដឹង កើតឡើងពី កម្ម ចិត្ត ឧតុ និងអាហារ នៅក្នុងរូបរាងកាយនៃយើងដែល មានវិថីចិត្តដឹងអារម្មណ៍ ចំនួន ១៧ ខណចិត្តធំ ត្រូវជា ៥១ ខណចិត្តតូច គឺ ឧប្បាទៈ ឋិតិ ភង្គៈ ទើបរូបធម៌ កើតម្ដង រួចត្រូវវិនាសទៅវិញជាធម្មតា ព្រោះកើតឡើង ជាមួយនឹងចិត្ត ដូចគ្នា ។

៤.១ លក្ខណាទិចតុក្កៈ របស់ រូប

១- **រុប្បនលក្ខណំ** : រូបមានការប្រែប្រួលបែកធ្លាយជាលក្ខណៈ

២- **វិកិរណរសំ** : រូបមានការបែកចេញពីចិត្ត ជាកិច្ច

៣- **អព្យាកតបច្ចុប្បដ្ឋានំ:** រូបមានអព្យាកតធម៌ ជាផល

៤- **វិញ្ញាណបទដ្ឋានំ** : រូបមានវិញ្ញាណ ឬនាមធម៌ជាបទដ្ឋាន ។

ការដឹងលក្ខណៈរបស់ចិត្តចេតសិកនិងរូប ធ្វើឱ្យយើងអាចស្គាល់ ឬចំណាំនៅក្នុងចិត្ត ដើម្បីសិក្សាពីសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃរបស់ សីល សមាធិ បញ្ញា ទុកជាការរំដោះខ្លួនចេញឱ្យ ផុតពីវដ្តៈ ព្រោះបរមត្ថធម៌ ជាសង្ខារពិតប្រាកដជាក់ច្បាស់ ពុំមានអ្វីក្លែងក្លាយថា ចិត្ត មិនមែនចិត្ត ថាចេតសិកមិនមែនចេតសិក ថារូបមិនមែនរូប ដែលជាការយល់ច្រឡំរបស់អ្នកមិនត្រាស់ដឹង ហើយសម្គាល់ថា មានតួខ្លួន ស្រី ប្រុស សត្វបុគ្គល អ្នកធ្វើអ្វីៗសព្វគ្រប់តាមភាពល្ងង់ខ្លៅ រួបរិតដោយសក្កាយទិដ្ឋិ មានអវិជ្ជា តណ្ហា ឧបាទាន ប្រកាន់មាំក្នុងរបស់គ្មាន

ខ្លឹមសារ ថាពិត ថាទៀង ថាឋិតថេរ សំដៅទៅលើអត្តាតួខ្លួនមានមែន ។

ការត្រាស់ដឹងនូវលក្ខណៈពិតរបស់ចិត្ត ចេតសិក រូប ធាតុ អាយតនៈ និងលក្ខណៈពិសេសរបស់បដិច្ចសមុប្បាទធម៌ ធ្វើឱ្យព្រះយោគាវចរ អ្នកមានការសិក្សាព្យាយាម រំភើបញាប់ញ័រយ៉ាងក្រៃលែង ព្រោះជាការកម្រក្នុងមួយអត្តភាពដែលត្រូវបានជួបនឹងព្រះសម្មាសម្ពុទ្ធ ព្រះធម៌ ព្រះសង្ឃ គុណកែវដ៏វិសេសរកអ្វីមកប្រៀបពុំស្មើ និងមានតែការបដិបត្តិបូជាចំពោះព្រះមហាករុណាទិគុណ ដោយយកចិត្តទុកដាក់យ៉ាងក្រៃលែងឱ្យអស់ពីសមត្ថភាពរបស់ខ្លួន គឺបូជានូវ **សាច់ ឈាម ឆ្អឹង សរសៃ** ទាំងស្រុងដល់ព្រះរតនត្រ័យ ដើម្បីចូលដល់ សេចក្ដីសុខស្ងប់ពិត គឺកំណត់ដឹងនូវរូបធម៌នាមធម៌ ។

ម្យ៉ាងទៀតព្រះដ៏មានព្រះភាគ ទ្រង់បង្ហាញប្រាប់ពីលក្ខណៈ របស់ខន្ធ ៥ ដែលពុំមានអ្នកណាមកថែមថយ ឱ្យលើសឬខ្វះពី ៥ ។ នេះជាការសម្ដែងប្រាប់នូវសភាពពិតរបស់រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ដោយសម្មតិហៅជា លោកវោហារ ថាខ្លួនយើង សព្វថ្ងៃ ។ ចំណែកអាយតនៈមានត្រឹម ១២ គឺ ខាងក្នុង ៦ និងក្រៅ ៦ ឯធាតុមាន ១៨ ។

ចក្ខុធាតុ	**រូបធាតុ**	**ចក្ខុវិញ្ញាណធាតុ**
សោតធាតុ	**សទ្ទធាតុ**	**សោតវិញ្ញាណធាតុ**
ឃានធាតុ	**គន្ធធាតុ**	**ឃានវិញ្ញាណធាតុ**
ជិវ្ហាធាតុ	**រសធាតុ**	**ជិវ្ហាវិញ្ញាណធាតុ**
កាយធាតុ	**ផោដ្ឋព្វធាតុ**	**កាយវិញ្ញាណធាតុ**
មនោធាតុ	**ធម្មធាតុ**	**មនោវិញ្ញាណធាតុ**

ដែលព្រះពុទ្ធអង្គទ្រង់សម្តែងត្រឹម ១៨ ទោះបីមានច្រើនយ៉ាងណាក៏មិនហួសពីធាតុ ១៨ នេះបានដែរ បើសង្ខេបជាងនេះនៅត្រឹម ៦ គឺ បឋវីធាតុ តេជោធាតុ វាយោធាតុ អាបោធាតុ អាកាសធាតុ និងវិញ្ញាណធាតុ ។

* សម្មតិសច្ចៈ ជាវោហារទេសនា លើកឡើងពីបុគ្គលប្បញ្ញត្តិ ធ្វើឱ្យសត្វងាយយល់ស្តាប់បាន របស់ខន្ធបញ្ចកៈ ។

* ការពិតនៃលោក ត្រូវនិយាយឱ្យយល់ស្តាប់គ្នាបានថា មានស្រី មានប្រុស មានសត្វ បុគ្គល ពិតប្រាកដមែន មិនអាចយកទៅកាឡៃឱ្យចេញជាអ្វីផ្សេងក្រៅពី មនុស្ស ថាមនុស្ស ស្រី ថាស្រី ប្រុស ថាប្រុស សត្វ ថាសត្វមានមែន ព្រោះជាតំណ

នៃចិត្តរបស់រឿងក្នុងមនោទ្វារ កើតឡើងច្រើនវារៈបានជា **ឃនសញ្ញា** រួចក៏សម្គាល់ទៅតាមមនោគតិរបស់ចិត្តនឹកគិត ធ្លាប់ឃើញ ធ្លាប់ឮ ធ្លាប់ដឹង និងធ្លាប់សម្គាល់ តាមខន្ធប្បវត្តិនោះៗ ដោយ បញ្ជាក់ប្រាប់ថា : "លោក" ជារបស់ មិនពិត មិនទៀង ។ កាលណា យើងថ្វាយបង្គំមាតាបិតា ត្រូវកំណត់ដឹងថា ត្រឹមតែខន្ធ ធាតុ អាយតនៈ តែមាតាបិតាមិនមាន ទោះបីជា ខន្ធ ធាតុ អាយតនៈពិតប្រាកដក៏បញ្ញត្តិថា មាតាបិតា នឹងទទួលបាននូវមហាកុសលញាណសម្បយុត្តយ៉ាងច្រើនអនេក ។

យើងមិនញញើត និងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ដែលមានត្រឹមតែរូបបដិមានៅក្នុងព្រះវិហារ តែទឹកចិត្តគោរពស្មោះចំពោះដល់ព្រះគុណរបស់ព្រះអង្គ ក៏ជាមហាកុសលខ្លាំងក្លាក្នុងការបង្អោនចិត្ត ហាក់ដូចជាមានព្រះពុទ្ធពិតៗនៅចំពោះមុខ ។ ថ្វាយបង្គំព្រះភិក្ខុសង្ឃមាននៅសព្វថ្ងៃ ដើម្បីបង្អោនចិត្តទៅរកព្រះសង្ឃសាវ័កពុទ្ធដែលជាទក្ខិណេយ្យបុគ្គលពិតៗ និងត្រូវបានទទួលបុណ្យច្រើនរាប់មិនអស់ដែរ នឹករលឹកដល់គុណរបស់ព្រះនាង-វិសាខា អនាថបណ្ឌិកសេដ្ឋី និងគុណទេវតា ក៏ជាការបានទទួលនូវ មហាកុសលច្រើនជាអនេកដូចគ្នា ។

រួមសេចក្តីមក ទោះបីសត្វ បុគ្គលអ្វីក៏ដោយ ដែលប្រព្រឹត្តទៅមានចរិយាយ៉ាងណា ក៏នៅត្រឹមតែ ខន្ធ ធាតុ អាយតនៈ ទាំងអស់ ព្រោះសត្វបុគ្គលមិនមាននៅក្នុងបរមត្ថ ដោយហេតុដូច្នោះបានជាព្រះសម្មាសម្ពុទ្ធលើកឡើងពីសម្មតិសច្ចៈ គឺបុគ្គលប្បញ្ញត្តិ សម្តែងធម៌ប្រោសដល់ពពួកវេនេយ្យសត្វ អាចនឹងស្តាប់យល់បានសម្រេច មគ្គផលច្រើនរាប់មិនអស់តាមកម្លាំងបុណ្យរៀងៗខ្លួន ។

សេចក្តីពិតក្នុងសភាវសច្ចៈ

មកដោយពិត បានឆ្កេះកកាយនូវឫសគល់របស់ធម៌ ឱ្យផ្ងារឡើងចេញមកក្រៅ ដើម្បីមើលឃើញនូវសភាវធម៌ កើតឡើងពីហេតុប្បច្ច័យ ពុំមានសត្វ បុគ្គល តួខ្លួន អ្នកប្រព្រឹត្តអ្វីឡើយ ។

នៅក្នុងវ/ន របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ បានសរសេរថា :

សភាវៈ ដូចគ្នានឹងសភាព បានន័យថា ដំណើរកើតឯង ធម្មតា, ធម្មជាតិ, ប្រប្រតី, អធ្យាស្រ័យ, ការតាំងចិត្ត, ហេតុ, ការណ៍, ការប្រព្រឹត្ត, សេចក្ដីពិតតាមធម្មតា, មានសភាពល្អ, សភាពយ៉ាងនេះ, មានសភាពជាអ្នកឆាប់ខឹង, តាមសភាពដើម ។

សភាវៈ ឬសភាវធម៌ ជាធម្មជាតិដើម, គោលរបស់ធម្មតា ។ សភាវសណ្ឋិត : ដែលស្ថិតនៅស៊ប់តាមកំណើតដើម, អ្នកដែលនៅស៊ប់ក្នុងធម្មតា ។ល។ មកពីពាក្យ **ភូធាតុ** គឺ ដំណើរកើតឡើង ។

១- ពាក្យថា ធម្មតា ឬធម្មៈ បានន័យថា សភាពមានជាប្រក្រតីក្នុងលោក ដែលតែងតែធ្វើឱ្យលោកប្រែប្រួល ត្រឡប់ចុះត្រឡប់ឡើង គ្មានលំនឹងពិតប្រាកដ គ្មានទីកន្លែងណាមួយឱ្យពិត ។ ពាក្យនេះជា សាមញ្ញទេ ប៉ុន្តែមានជម្រៅ ។

២- ពាក្យថា ធម្មជាតិ ជាឈ្មោះនៃធម៌ មានលក្ខណៈ ៣ យ៉ាង :

សង្ខារទាំងឡាយ មិនទៀង

សង្ខារទាំងឡាយ ជាទុក្ខ

ធម៌ទាំងឡាយ ជាអនត្តា ។

៣- ពាក្យថា ដំណើរកើតឯង ក៏ជាឈ្មោះនៃធម្មជាតិដូចគ្នា គឺសំដៅទៅលើហេតុប្បច្ច័យ ។

៤- ពាក្យថា ហេតុ ជាឈ្មោះនៃធម្មៈ ក្នុងជីវិតប្រចាំថ្ងៃ អាស្រ័យហេតុប្បច្ច័យ នាំឱ្យសភាវធម៌កើតឡើងចេញពីបច្ច័យ ធំៗ ២៤ មានក្នុងគម្ពីរមហាបដ្ឋាន ។

តាមធម្មតា សភាវធម៌មួយកើតឡើង មានហេតុប្បច្ច័យច្រើនប្រការណាស់ ប្រៀបដូច ដើមឈើ ឬដើមឫស្សី ជាដើម ត្រូវមានហេតុ គឺឫសយ៉ាងច្រើន មានឫសតូច ឫសធំ ឫសកែវ សម្រាប់ជួយ ឧបត្ថម្ភដើមឈើ គឺសង្ខារ ឬ សភាវកើតឡើង បើខ្វះហេតុណាមួយ ក៏មិនអាចនឹងកើតបានដែរ ។

សភាវៈ ពិតមែនតែជាឈ្មោះនៃហេតុនាំឱ្យកើតធម៌ មុនដំបូង តែក៏ជាសង្ខារធម៌តាក់តែងពីហេតុប្បច្ច័យ ដែលជាតួសភាវៈមានបច្ច័យប្រជុំតាក់តែង បៀតបៀន ដុតរោល ប្រែប្រួលវិនាសទៅវិញជាធម្មតានៅពេលអស់ហេតុប្បច្ច័យ ហៅថាសង្ខារធម៌ប្រចាំ វដ្តៈរបស់បដិច្ចសមុប្បាទធម៌ ឬ **ទុក្ខសច្ចៈ** ។

សភាវៈ ខុសគ្នាពីបរមត្ថធម៌ នៅត្រង់ពុំមាន **និព្វានធាតុ** ជាអសង្ខតធម៌ សម្រាប់បន្តកំណើត របស់អាយុរូបធម៌នាមធម៌

ឱ្យឋិតនៅវៀងរហូត មិនចេះដាច់ គ្មានទីបញ្ចប់ អាចហៅបានថា ធម្មដ្ឋិតិ ជាធម៌តាំងនៅ សំដៅយកអនត្តាធម៌ដែលមាន លក្ខណៈពិតរបស់លោកដោយព្រះអនាវរណញ្ញាណ ទ្រង់ជ្រាបលើកយកមកសម្តែង ។

ការបានដឹងនូវលក្ខណៈពិតរបស់សភាវសច្ចៈ អាចធ្វើឱ្យលះបង់ នូវសេចក្តីប្រកាន់បន្តិចម្តងៗ ដោយមិនគួរទៅចាប់យកនូវសង្ខារមួយណាមកធ្វើជារបស់ខ្លួន ព្រោះសុទ្ធតែជាសេចក្តីទុក្ខទាំងអស់ ។

ព្រះខីណាស្រព ព្រះអង្គពុំមានអ្វីទាល់តែសោះ សម្រាប់ខ្លួនព្រះអង្គ ព្រោះលោកអស់សេចក្តីប្រកាន់ ។ កាលណាបើនៅមានអ្វីៗលោកកំណត់ថាជាទុក្ខ លុះត្រាតែគ្មានអ្វីសោះទើបដេកជាសុខដោយមានត្រឹមតែសង្ខារសុទ្ធរបស់សភាវៈ កើតឡើងប៉ុណ្ណោះ កន្លែងនេះហើយដែលលោកសមុច្ឆេទកិលេសគ្មានការសង្ស័យទៅលើអ្វីបន្តិចបន្តួច ដោយប្រគល់នូវអ្វីៗទាំងនោះឱ្យទៅ ម្ចាស់ត្រៃលក្ខណ៍ធម៌ទាំងអស់ ពុំមានតួខ្លួនយើងគេជាអ្នកចាត់ចែងធ្វើអ្វីៗ ។

ដើម្បីសម្តែងការពិតយ៉ាងពីរោះក្បោះក្បាយ របស់រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ឱ្យបានកាន់តែជាក់ច្បាស់នូវគន្លងបញ្ញត្តិជាងនេះបន្តិច សូមសិក្សាពី **លក្ខណាទិចតុក្កៈ** ឱ្យបានពិស្តារដូចតទៅ :

ចំពោះរូបក្ខន្ធជាធាតុមិនដឹង និងជាទីអាស្រ័យរបស់នាមក្ខន្ធ ៤ មានការបែកធ្លាយទៅវិញជាធម្មតា បានសរសេរជូនជ្រាបរួចហើយ គឺនៅសល់នាមក្ខន្ធ ៤ ទៀត បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ត្រូវសិក្សាជាបន្ត ។

- **លក្ខណាទិចតុក្កៈ របស់វេទនាខន្ធ ឬវេទនាចេតសិក** កើតពី ផស្សៈ បានដល់ការដឹងសុខទុក្ខ និងឧបេក្ខា ។

១- **អនុភវនលក្ខណា** : មានការសោយអារម្មណ៍ ជាលក្ខណៈ

២- **វិសយរសសម្ភោគរសោៈ** មានការសោយរសរបស់អារម្មណ៍ ជាកិច្ច

៣- **សុខទុក្ខបច្ចុប្បដ្ឋានា** : មានសេចក្តីសុខ និងទុក្ខ ជាផល

៤- **ផស្សបទដ្ឋានា** : មានផស្សៈ ជាហេតុជិត ។

- **លក្ខណាទិចតុក្កៈ របស់ សញ្ញាខន្ធ** បាន ដល់ការកំណត់បាន ឬកំណត់ដឹង គឺកំណត់ដឹងអាការគ្រឿងសម្គាល់លក្ខណៈ ផ្សេងៗ ដែលជាហេតុឱ្យចាំអារម្មណ៍ ។

១- **សញ្ជាននលក្ខណា :** មានការចាំ ជាលក្ខណៈ

២- **បុនសញ្ជាននបច្ចយនិមិត្តករណរសា :** មានការចាំបាន និងធ្វើគ្រឿងសម្គាល់ទុក ជាកិច្ច

៣- **យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានា :** មានការចាំបានក្នុងរបស់ដែលសម្គាល់ទុក ជាផល

៤- **យថាឧបដ្ឋិតវិសយបទដ្ឋានា :** មានអារម្មណ៍ដែលប្រាកដ ជាហេតុជិត ។

- **លក្ខណាទិចតុក្កៈ របស់ ចេតនាចេតសិក** ដែលជាតួសង្ខារ បានដល់អង្គប្រកប ឬគុណសម្បត្តិផ្សេងៗ របស់ចិត្តមានចេតនា ជាតួដឹកនាំតាក់តែងចិត្តឱ្យល្អ អាក្រក់ ឬកណ្តាលតាមផ្លូវ កាយវាចា ប្រព្រឹត្តទៅផ្សេងៗ ជាទីមក របស់កម្ម ដូចជាសទ្ធា សតិ ហិរិ ឱត្តប្បៈ មេត្តា ករុណា មុទិតា ឧបេក្ខា បញ្ញា មោហៈ លោភៈ ទោសៈ មានះ ទិដ្ឋិ ឥស្សា មច្ឆរិយៈ ជាដើម ហៅថា គ្រឿងតាក់តែងចិត្ត គ្រឿងតាក់តែង របស់ការគិត

ឬគ្រឿង តាក់តែងរបស់កម្មដែលមានចេតសិក ៥០ ក្នុងព្រះអភិធម្ម ។

១- **ចេតនាភាវលក្ខណា** : មានការបបួល ជាលក្ខណៈ

២- **អាយូហនរសា** : មានការប្រមូល ឬខ្វល់ខ្វាយ ជាកិច្ច

៣- **សំវិធានបច្ចុប្បដ្ឋានា** : មានការចាត់ចែង ជាផល

៤- **សេសខន្ធត្តយបទដ្ឋានា:** មាននាមក្ខន្ធទាំង ៣ ដែលនៅសល់ គឺវេទនាខន្ធ សញ្ញាខន្ធ និង វិញ្ញាណក្ខន្ធ ជាហេតុជិត ។

- **លក្ខណាទិចតុក្ក របស់ វិញ្ញាណ** បានដឹងច្បាស់នូវអារម្មណ៍ តាមទ្វារទាំង ៥ និងផ្លូវចិត្ត គឺការឃើញ ការបានឮ ការហិតក្លិន ការដឹងរស ការដឹងសម្ផស្សផ្លូវកាយ និងការដឹង អារម្មណ៍តាម ផ្លូវចិត្ត ។

១- **វិជានលក្ខណំ** : មានការដឹងអារម្មណ៍ ជាលក្ខណៈ

២- **បុព្វង្គមរសំ** : ជាប្រធានដល់ចេតសិក និងរូប ជាកិច្ច

៣- **បដិសន្ធិបច្ចុប្បដ្ឋានំ:** មានការបន្តរវាងភពចាស់ និងភពថ្មី ជាផល ។

៤- **សង្ខារបទដ្ឋាន** : មានសង្ខារ ៣ ជាហេតុជិត

ឬវត្ថារម្មណ បទដ្ឋានំ ឬមានវត្ថុ (៦) តភ្ជាប់គ្នាជាមួយអារម្មណ៍ ៦ ជាហេតុជិត ។

ចំណែកអាយតនៈ ខាងក្នុង ៦ និងខាងក្រៅ ៦ រួមគ្នាបានជា ១២ ជាទីប្រជុំសម្រាប់កសាងបុណ្យនិងបាប ដែលមានអារម្មណ៍ មកប្រាកដតាមអាយតនៈ ឬសឡាយតនៈ ណាមួយក៏មាន **លក្ខណាទិចតុក្កៈ** ផ្សេងបួន១ ដូចគ្នា ។

១- **អាយតនលក្ខណំ** : មានការប៉ះខ្ទប់ ឬមានការធ្វើវដ្តសង្សារ ឱ្យយឺតយូរ ជាលក្ខណៈ

២- **ទស្សនរសំ** : មានការប៉ះខ្ទប់ ឬអូសទាញអារម្មណ៍ របស់ខ្លួន ឬមានការឃើញអារម្មណ៍ជាដើម ជាកិច្ច

៣- **វត្ថុភាវបច្ចុប្បដ្ឋានំ** : មានការប្រព្រឹត្តនូវវត្ថុនិងទ្វារជាផល

៤- **នាមរូបបទដ្ឋានំ** : មានចេតសិក និងកម្មជរូបជាហេតុជិត ។

ផស្សៈ ជាទីប្រជុំនូវធម៌ ៣ ដែលមានអាយតនៈ ៦ ខាងក្នុង អាយតនៈ ៦ ខាងក្រៅ និងវិញ្ញាណ កើតឡើងនាំឱ្យសម្រេចបានទៅជាសព្វចិត្តសាធារណចេតសិក ៧ យ៉ាង តិច

សម្រាប់ធ្វើកិច្ចផ្សេងៗ ជាមួយចិត្តក្នុងការដឹងអារម្មណ៍ ដែលមាន **លក្ខណាទិចតុក្កៈ** ដូចតទៅ ៖

១- **ផុសនលក្ខណោ៖** មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈ

២- **សង្ឃដ្ដនរសោ** ៖ មានការតភ្ជាប់អារម្មណ៍ ជាមួយវត្ថុរូប និងវិញ្ញាណ ជាកិច្ច

៣- **សន្និបាតបច្ចុបដ្ឋានោ** ៖ មានការប្រជុំព្រមគ្នា ជាផល

៤- **អាបាតគតវិសយបទដ្ឋានោ៖** មានអារម្មណ៍ចំពោះមុខយ៉ាងប្រាកដ ជាហេតុជិត ។

សេចក្ដីពិតក្នុងវិរតិសច្ចៈ

មកដោយពិត ទ្រង់លើកឡើងពីការវៀរនូវសិក្ខាបទរបស់ចេតនាសីល ។ ពាក្យថា វិរតិសច្ចៈសំដៅយកតួចេតនាខ្លះ ឬការវៀរដោយមិនទាន់បានសមាទាន ឬក៏សមាទានរួចហើយក្ដី ក៏ការប្រព្រឹត្តកន្លងនូវសិក្ខាបទទាំង ៥ មានបាណាតិបាតជាដើម ក៏មានន័យដូចគ្នា ។ ក្នុងអដ្ឋកថាបុត្រសូត្រលេខ ៤៥ ភាគ ៤/៤៥៥ ខុទ្ទកនិកាយឥតិវុត្តកៈ មានបទថា **ឧប្បដ្ឋិវិរតា**

មិនជាអ្នកវៀរចាក ព្រោះមិនទាន់មាន សមាទានវិរតិ និង សម្បត្តវិរតិ ។ បទថា **ទុស្សីលា** សេចក្តីថា បន្ទាប់ពីនេះទៅ ជាមនុស្សមិនមានសីល ព្រោះមិនមាន សូម្បីបញ្ចសីល ។ បទថា **បាបធម្មា** បានដល់ ធម៌លាមកគឺអាចារៈដែលជ្រាបហើយ ។ បទថា **បាណាតិបាតា បដិវិរតោ** ភាពជាអ្នកវៀរ គឺតាំងនៅឆ្ងាយពីបាណាតិបាត ព្រោះសមាទានសិក្ខាបទ សូម្បីក្នុងបទដែលនៅសល់ទាំងឡាយ ក៏ន័យនេះដូចគ្នា ។

ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ១ ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូលដ្ឋាន ១ ដោយកម្ម ១ ដោយការសមាទាន ១ ដោយការដាច់ស្រឡះ ១ ដោយផល ១ នៃវេរមណី ទាំងឡាយ មានបាណាតិបាតា វេរមណីជាដើមដូចតទៅនេះ ។

ពោលដោយអត្ថ បណ្តាអាការទាំង ៨ យ៉ាងនោះ ដោយសភាពវេរមណីទាំង ៥ ជាចេតនាខ្លះ ជាវិរតិខ្លះដែលបានសម្តែងមកហើយ ដោយអំណាចនៃវិរតិ ។ វិរតិរបស់អ្នកវៀរចាកបាណាតិបាត ប្រកបដោយកុសលចិត្ត ដែលបានពោលទុកមកហើយថា (ក្នុងសម័យវិរតិនោះ) ការវៀរចាក បាណាតិបាត មានប្រភេទ ៣ យ៉ាង គឺ សម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។ បណ្តាវិរតិទាំង ៣ យ៉ាងនោះ វិរតិដែល

កើតឡើងដល់អ្នកមិនទាន់បានសមាទានសិក្ខាបទ តែពិចារណាឃើញជាតិវ័យនិងភាពជាពហុស្សូត ជាដើម ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនូវវត្ថុដែលបានជួប ដោយគិតថា រឿងនេះមិនសមគួរដល់យើង ត្រូវប្រព្រឹត្ត ឈ្មោះថា **សម្បត្តវិរតិ** ។ ឯវិរតិដែលកើតឡើងដល់អ្នក ដែលបានសមាទានសិក្ខាបទទុកមុន សូម្បីនឹងត្រូវលះបង់ជីវិតរបស់ខ្លួន មានគុណតម្លៃក្រៃលែងជាងសិក្ខាបទនេះ ក៏មិនហ៊ានប្រព្រឹត្តបទល្មើសដែរ ព្រោះបានសមាទានសិក្ខាបទទុករួចហើយ ឈ្មោះថា **សមាទានវិរតិ** ។ ចំណែក វិរតិដែលសម្បយុត្តដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ចាប់ផ្ដើមតាំងតែពីកើតឡើង សូម្បីគិតថាយើងនឹងសម្លាប់សត្វ ក៏មិនកើតដល់ព្រះអរិយបុគ្គលទាំងឡាយ ។ ក្នុងបណ្ដា វិរតិទាំង ៣ នោះ លោកសង្គ្រោះ យក **សមាទានវិរតិ** តែម្យ៉ាង ។

➯ **ចោលដោយអារម្មណ៍** ចំពោះបាណាតិបាតជាដើម មានវិរតិជាកុសលកម្ម អាស្រ័យជីវិតិន្ទ្រិយជាអារម្មណ៍នោះឯង រមែងលះសេចក្ដីទ្រុស្ដសីលទាំងឡាយ ដូចអរិយមគ្គដែលមានព្រះនិព្វានជាអារម្មណ៍ រមែងលះកិលេសទាំងឡាយបានយ៉ាងដូច្នោះ ។

ពោលដោយវេទនា វិរតិទាំងអស់ ជាសុខវេទនា ។

ពោលដោយមូលដ្ឋាន ចំពោះកុសលធម៌របស់អ្នកដែលវៀរចាក ដោយញាណសម្បយុត្ត មានមូល ៣ ដោយអំណាច អលោភៈ អទោសៈ អមោហៈ និងជាញាណវិប្បយុត្តចិត្ត មានមូល ២ ដោយអំណាចអលោភៈ អទោសៈ ។

ពោលដោយកម្ម ការវៀរចាកមុសាវាទ ជាវចីកម្មមួយចំណែក នៅសល់ជាកាយកម្ម ។

ពោលដោយសមាទាន អ្នកដែលមិនបានទទួលការសមាទានក្នុងសំណាក់របស់អ្នកដទៃ ដែលជា **គរុដ្ឋានីយ** បុគ្គល អាចសមាទានសីល ៥ ដោយខ្លួនឯងជា ឯកជ្ឈសមាទាន ឬជា បច្ចេកសមាទានក៏បាន ។

ពោលដោយដាច់ខាត សម្រាប់គ្រហស្ថទាំងឡាយ សិក្ខាបទណាដែលកន្លងហួសទៅហើយ នឹងត្រូវដាច់ចំពោះតែសិក្ខាបទនោះប៉ុណ្ណោះ ដទៃទៀតក្រៅពីនេះមិនដាច់ ។ ព្រោះហេតុអ្វី? ព្រោះគ្រហស្ថទាំងឡាយមានសីលមិនជាប់គ្នា (ជាបច្ចេកសមាទាន) រក្សាចំពោះសិក្ខាបទដែលអាចរក្សាបាន

ប៉ុណ្ណោះ ។ ឯចំណែក សម្រាប់បព្វជិតវិញ កាលបើកន្លងល្មើស សិក្ខាបទណាមួយហើយ ត្រូវដាច់ទាំងអស់ ។

ពោលដោយផល បណ្ដាវេរមណីទាំងនោះ

➢ ***បាណាតិបាតា វេរមណី*** មានផល មានអត្ថ ២២ យ៉ាង

១- **អង្គបច្ចង្គសមន្នាគតា** : ភាពជាអ្នកសម្បូរដោយ អវយវៈតូចធំ

២- **អារោហបរិណាហសម្បត្តិ** : ដល់ព្រមដោយ ចំណែកខ្ពស់ នឹងទូលាយ

៣- **ជវនសម្បត្តិ** : ដល់ព្រមដោយការលឿនរហ័ស

៤- **សុបតិដ្ឋិតបាទតា** : មានជើង តាំងនៅសមរម្យ

៥- **ចារុតា** : មានភាពស្អាតល្អ

៦- **មុទុតា** : មានភាពទន់ភ្លន់

៧- **សុចិតា** : មានភាពស្អាតល្អ

៨- **សូរតា** : មានភាពក្លាហាន

៩- **មហាពលតា** : មានភាពជាអ្នកមានកម្លាំងច្រើន

១០- **វិសដ្ឋវចនតា** : មានវាចាសណ្ដាប់ធ្នាប់ល្អ

១១- **សត្តានំ បិយមនាបតា** : ភាពជាអ្នកគួរ ស្រលាញ់ពេញចិត្តរបស់សត្វទាំងឡាយ

១២- **អភិជ្ជបរិសតា** : ភាពជាអ្នកមានបរិស័ទមិនបែកគ្នា

១៣- **អឆម្ភិតា** : ភាពជាអ្នកមិនភ័យតក់ស្លុត

១៤- **ទុប្បធំសិយតា** : ពុំអាចមានអ្នកកម្ចាត់បាន

១៥- **បរូបក្កមេន អមរណតា** : ជាអ្នកមិនស្លាប់ដោយការធ្វើសេចក្ដីអន្តរាយពីអ្នកដទៃ

១៦- **មហាបរិវារតា** : ភាពជាអ្នកមានបរិវារច្រើន

១៧- **សុវណ្ណតា** : ភាពជាអ្នកមានពណ៌ សម្បុរដូចមាស

១៨- **សុសណ្ឋានតា** : ភាពជាអ្នកមានទ្រង់ទ្រាយល្អ

១៩- **អប្បាពាធតា** : ភាពជាអ្នកមានអាពាធតិច

២០- **អសោកតា** : ភាពជាអ្នកមិនសោយសោក

២១- **បីយមនាបេហិ អវិប្បយោគតា** : ភាពជាអ្នកមិនព្រាត់ប្រាសនូវរបស់ជាទីស្រឡាញ់ពេញចិត្ត

២២- **ទីឃាយុតា** : ភាពជាអ្នកមានអាយុយឺនយូរ ។

ចំពោះផលដែលមាននៅក្នុងវិរតិសិក្ខាបទដទៃទៀត ក៏មាន អធិប្បាយផ្សេងគ្នាយ៉ាងប្លែក១ ខុសគ្នាទៅតាមហេតុរៀង១ខ្លួន ។

➤ ***អទិន្នាទានា វេរមណី*** មានផលមានអត្ថ ៩ យ៉ាង

១- **មហាធនធញ្ញតា** : ជាអ្នកមានទ្រព្យសម្បត្តិច្រើន

២- **អនន្តភោគតា** : ជាអ្នកមានភោគអនេកអនន្ត

៣- **ថិរភោគតា** : ជាអ្នកមានភោគ តាំងនៅឋិតថេរ

៤- **ឥច្ឆិតានំ ភោគានំ ខិប្បបដិលាភោ** : ការបានភោគទ្រព្យតាមសេចក្តីត្រូវការភ្លាម ១

៥- **រាជាទីហិ អសាធារណភោគតា** : ការមានភោគៈមិនមែនជាទ្រព្យទូទៅសម្រាប់ព្រះរាជា

៦- **ឧឡារភោគតា** : ភាពជាអ្នកមានភោគយ៉ាងឧឡារិក

៧- **តត្ថ តត្ថ ជេដ្ឋកភាវោ**: ភាពជាប្រធាននាំមុខក្នុងទីនោះ១

៨- **នត្ថិ ភាវស្ស អជាននតា** : មិនដែលថាចេះក្រខ្សត់

៩- **សុខវិហារតា** : ភាពជាអ្នករស់នៅយ៉ាងសប្បាយ ។

➤ **អព្រហ្មចរិយា វេរមណី** មានផលមានអត្ថ ១៧ យ៉ាង

១- **វិគតបច្ចត្ថិកតា** : ភាពជាអ្នកប្រាសចាកសឹកសត្រូវ

២- **សព្វសត្តានំ បិយមនាបតា** : ជាទីស្រឡាញ់ពេញចិត្តសព្វសត្វ

៣- **អន្នបានវត្ថច្ឆាទនាទីនំ លាភិតា** : ជាអ្នកបាននូវរបស់ផ្សេង ៗ ដូចជា បាយ ទឹក សំពត់ និងវត្ថុជាគ្រឿងបិទបាំង

៤- **សុខសុបនតា** : ដំណេកលក់យ៉ាងស្រួល

៥- **សុខបដិពុជ្ឈនតា** : ភ្ញាក់ឡើងដោយស្រួល

៦- **អបាយភយវិមោក្ខោ** : មានការផុតចាកភ័យក្នុងអបាយ

៧- **ឥត្ថីភាវនបុំសកភាវានំ អភព្វតា** : គ្មានការកើតជាស្រី ឬខ្ទើយ

៨- **អកោធនតា** : ភាពជាអ្នកមិនក្រោធ

៩- **សច្ចការិតា** : ភាពជាអ្នកមានប្រក្រតី ធ្វើតែសេចក្តីពិត

១០- **អមង្កុភូតតា** : ភាពជាអ្នកមិនមានការខ្មាសអៀន
ក្នុងអំពើល្អ

១១- **អាភាធនសុខតា** : ភាពជាអ្នកមានសេចក្ដីសុខពីការ
ទទួលអញ្ជើញ

១២- **បរិបុណ្ណិន្ទ្រិយតា** : ភាពជាអ្នកមានឥន្ទ្រិយបរិបូរ

១៣- **និរាសង្កតា** : ជាអ្នកប្រាសចាកសេចក្ដីសង្ស័យ

១៤- **អប្បោស្សុក្កតា** : ជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច

១៥- **សុខវិហារតា** : ជាអ្នករស់នៅយ៉ាងសុខសប្បាយ

១៦- **អកុតោភយតា** : ជាអ្នកមិនមានភ័យពីទីណាៗ

១៧- **បិយវិប្បយោគាភាវោ** : ជាអ្នកមិនមានការព្រាត់
ប្រាស ចាករបស់ជាទីស្រឡាញ់ ។

➤ ***មុសាវាទា វេរមណី*** មានផលមានអត្ថ ១៤ យ៉ាង

១- **វិប្បសន្និន្ទ្រិយតា** : ភាពជាអ្នកមានឥន្ទ្រិយថ្លូរផង់

២- **វិសដ្ឋមធុភាណិតា** : ភាពជាអ្នកមានពាក្យសំដីទន់ផ្អែម
ល្ហែម

៣- **សមសិតសុទ្ធទន្តតា** : ភាពជាអ្នកមានធ្មេញរាបស្មើស្អាត

៤- **នាតិថូលតា** : ភាពជាអ្នកមិនធាត់ហួសពេក

៥- **នាតិកីសតា** : ភាពជាអ្នកមិនស្គមពេក

៦- **នាតិរស្សតា** : ភាពជាអ្នកមិនទាបពេក

៧- **នាតិទីឃតា** : ភាពជាអ្នកមិនខ្ពស់ពេក

៨- **សុខសម្ផស្សតា** : ភាពជាអ្នកមានសម្ផស្សជាសុខ

៩- **ឧប្បលគន្ធមុខតា:** ភាពជាអ្នកមានក្លិនមាត់ក្រអូបដូចក្លិនផ្កាឧប្បល

១០- **សុស្សូសកបរិសតា :** ភាពជាអ្នកមានបរិស័ទជឿស្តាប់តាំងនៅក្នុងឱវាទ

១១- **អាទេយ្យវចនតា :** ភាពជាអ្នកមានវាចា ជឿទុកចិត្តបាន

១២- **កមលទលសទិសមុខុលោហិតនយជិវ្ហាតា :** ភាពជាអ្នកមានអណ្តាតទន់ក្រហម ដូចជាត្របកផ្កាឧប្បល

១៣- **អលីនតា :** ជាអ្នកមានចិត្តមិនរួញរា

១៤- **អនុទ្ធតតា :** ជាអ្នកមិនរវើរវាយ ។

➢ *សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី* មានផល

មនអត្ថ ១៤ យ៉ាង

១- **អតីតានាគតបច្ចុប្បន្នេសុ កិច្ចករណីយេសុ អប្បមាទតា :**

ភាពជាអ្នកមិនប្រមាទក្នុងកិច្ចនិងករណីយកិច្ចជាអតីត អនាគត និងបច្ចុប្បន្ន

២- **ញាណវន្តតា :** ភាពជាអ្នកមានញាណ គឺប្រាជ្ញា

៣- **សទា ឧបដ្ឋិតសតិតា :** ភាពជាអ្នកមានសតិគ្រប់ពេល

៤- **ឧប្បន្នេសុ កិច្ចករណីយេសុ សព្វដ្ឋានុប្បត្តិកបដិភាណវន្តតា :**

ភាពជាអ្នកមានបដិភាណកើតឡើងគ្រប់កន្លែងក្នុងកាលមានកិច្ច និងករណីយកិច្ចកើតឡើង

៥- **អនលសតា** : ជាអ្នកមិនខ្ជិលច្រអូស

៦- **អជឡតា** : ភាពជាអ្នកមិនល្ងង់

៧- **អមូគតា** : ជាអ្នកមិនឆ្កួតវង្វេង

៨- **អច្ឆម្ភិតា** : ជាអ្នកមិនភ័យខ្លាច

៩- **អសារម្ភតា** : ជាអ្នកមិនមានការរឹងត្អឹង

១០- **អនិស្សុកិតា** : ជាអ្នកមិនមានភាពប្រច័ណ្ឌ

១១- **អមច្ឆរិតា** : ជាអ្នកមិនកំណាញ់

១២- **សច្ចវាទិតា** : ជាអ្នកមានប្រក្រតី ពោលពាក្យពិត

១៣- **អបិសុណ អផរុស អសម្ផប្បលាបវាទិតា :** ភាពជាអ្នក
មានប្រក្រតីមិននិយាយពាក្យសិកសៀក ពាក្យគ្រោត
គ្រាត និង ពោលពាក្យកុហក

១៤- **កតញ្ញុតា** : ភាពជាអ្នកមានកតញ្ញូ

១៥- **កតវេទិតា** : ភាពជាអ្នកមានកតវេទិ គឺ តបគុណ

១៦- **ភោគវន្តតា** : ភាពជាអ្នកមានភោគ

១៧- **សីលវន្តតា** : ភាពជាអ្នកមានសីល

១៨- **ឧជុគតា** : ភាពជាអ្នកជឿត្រង់

១៩- **អកោធនតា** : ជាអ្នកមិនក្រោធ

២០- **ហិរោត្តប្បសម្បន្នតា :** ជាអ្នកដល់ព្រមដោយហិរិ
និងឱត្តប្បៈ

២១- **ឧជុទិដ្ឋិតា** : ជាអ្នកមានសេចក្ដីឃើញត្រង់

២២- **មហត្តតា** : ជាអ្នកមានចិត្តធំ

២៣- **បណ្ឌិតតា** : ជាអ្នកឆ្លាត

២៤- **អត្ថានត្ថកុសលតា** : ជាអ្នកឆ្លាតក្នុងរបស់ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ។

ពោលដោយមូលដ្ឋានរបស់បាបធម៌ទាំងឡាយ ដោយកាយកម្ម និងវចីកម្ម ថា :

- **បាណាតិបាត** មានមូល ២ ដោយអំណាចនៃទោសៈ និងមោហៈ

- **អទិន្នាទាន និងមុសាវាទ** មានមូល ២ ដោយអំណាចនៃទោសៈ និងមោហៈ ឬដោយអំណាចនៃលោភៈ និងមោហៈ

- **មិច្ឆាចារ និង សុរាបាន** មានមូល ២ ដោយ អំណាចនៃលោភៈ និងមោហៈ ។

លក្ខណាទិចតុក្កៈ របស់ វិរតិចេតសិក

១- **វិរតីយោ ទុច្ចរិត អវិតិក្កមលក្ខណា** : មានការវៀរមិនឈានកន្លងហួស ទុច្ចរិតទាំងឡាយ ជាលក្ខណៈ

២- **តតោ សង្កោចន រសា** : មានការដកថយពីទុច្ចរិត ជាកិច្ច

៣- **អកិរិយ បច្ចុប្បដ្ឋានា** : មានការមិនធ្វើទុច្ចរិត ជាផល

៤- **សទ្ធាសតិហិរិឱត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា** : មានគុណគឺសទ្ធា សតិ ហិរិ ឱត្តប្បៈ និងអ្នកមានសេចក្តីប្រាថ្នាតិច ជាហេតុជិត ។

សេចក្តីពិតក្នុងញាណសច្ចៈ

ឫ

មកដោយពិត ជួយពង្រឹងគុណភាពជីវិត ឱ្យមានប្រាជ្ញាញាណសម្រាប់ទប់ទល់ តតាំងច្បាំងនិងកិលេសទាំងឡាយ ។

ពាក្យថា ញាណសច្ចៈ បានដល់ប្រាជ្ញាញាណ គឺតួបញ្ញាសុទ្ធ សម្រាប់ដឹងទូទៅ មានលក្ខណៈប្រាកដច្បាស់សម្រាប់អ្នកសន្សំបុណ្យបារមីទោះកុសលថ្នាក់កាមាវចរៈ ថ្នាក់មហគ្គតៈ ឬក៏រហូតដល់លោកកុត្តរៈផង ដែលនៅក្នុង វ/ន សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ បានសរសេរប្រាប់ថា សេចក្តីពិត, ប្រាជ្ញាញាណ, ទ្រង់ញាណ (ព្រះពុទ្ធ) ទ្រង់ជ្រាបច្បាស់នូវ

កិច្ចការអាចិកំបាំងជ្រាលជ្រៅផ្សេងៗ ដោយព្រះប្រាជ្ញា គេតែង ប្រើពាក្យទ្រង់ញាណនេះ ក្នុងការស្តីបន្ទោសថា គ្មាននរណា ទ្រង់ញាណដូចព្រះទេ, បើខ្លួនមិនប្រាប់ ធ្វើម្តេចឱ្យគេដឹងផងបាន? បើប្រើរៀងភ្ជាប់ពីខាងដើម សព្ទដទៃ អ.ថ.ញាណ ដូចជា ញាណ កោសល ឋានន្តរជាសមណសក្តិទីរាជាគណៈ សម្រាប់ **ចតា្វ** ក្នុង ប្រទេសកម្ពុជា ។ ញាណទស្សនៈ (បាលី ញាណទស្សន, សំស្ក្រឹត ជ្ញានទសិន), ប្រាជ្ញាដែលដឹង ដែលឃើញនូវសេចក្តីពិត ដូចឃើញ ច្បាស់នូវការមិនទៀងនៃរូបកាយជាដើម, បច្ចវេក្ខណញ្ញាណ គឺ ប្រាជ្ញាសម្រាប់ពិចារណានូវសង្ខារ ។ **ញាណប្បកាស** គឺពន្លឺនៃ សេចក្តីដឹងយល់ភ្លឺឆ្លុះព្រោងព្រាតមិនទើសគំនិត ។ **ញាណវង្ស** ឋានន្តរស័ក្តិ ទីរាជាគណៈថ្នាក់ត្រីក្នុងប្រទេសកម្ពុជា ។ ញាណ-វិប្បយុត្ត ដែលប្រាសចាកការដឹង គឺចិត្តដែលមានតែជំនឿ ឥតមានសេចក្តី ដឹងការខុសត្រូវឡើយ ; ធ្វើបុណ្យដោយ ញាណវិប្បយុត្ត គឺធ្វើបុណ្យកុសលណាមួយ ដោយជឿជាក់ ថាបានបុណ្យ ប៉ុន្តែឥតមាន សេចក្តីដឹងអ្វីប្លែក ដោយធ្វើតាមតែ គេបង្គាប់ ចំណែកញាណ សម្បយុត្ត គឺធ្វើអ្វីៗ ប្រកបដោយ បញ្ញាញាណសម្ភារ គឺការសន្សំ ប្រមូល ។ ញាណសាស្ត្រ គឺក្បួន សម្រាប់ទាយ ឬក្បួនព្យាករណ៍ ។ល។

នៅក្នុងវិសុទ្ធិមគ្គ ពាក្យថាញាណ បានដល់វិបស្សនាញាណ ដោយន័យថា ជាញាណដ៏មុតខ្លាំងក្លាយ៉ាងក្រៃលែង មានកម្លាំងដែលអ្វីៗ មិនអាចរារាំងបាន ដូច **វជិរាវុធ** របស់ព្រះឥន្ទ្រទ្រង់គ្រវែងចោលទៅហើយ មិនមានអ្វីមកទប់ទល់ទ្របាន រមែងកើតឡើងដល់ព្រះយោគីអ្នកមាន **ឧទ្ធយព្វយញ្ញាណ** ដែលពិចារណានូវរូបធម៌ និងអរូបធម៌ទាំងឡាយ ។

នៅក្នុងវិបស្សនាកម្មដ្ឋាន របស់អភិធម្មជោតិកៈ សម្ដែងពីវិបស្សនាញាណ ១៦ តាមលំដាប់ដូចខាងក្រោមនេះ ។

១- **នាមរូបបរិច្ឆេទញ្ញាណ** ៖ ជាញាណក្នុងមហាកុសលញាណសម្បយុត្តចិត្តកើតឡើង ប្រចក្សច្បាស់នូវលក្ខណៈនៃនាមធម៌ និងរូបធម៌ ដែលញែកដាច់ពីគ្នា ដល់អារម្មណ៍ណាមួយ លោកប្រាកដសភាពដែលសូន្យទទេចាកតួខ្លួន ខណៈនោះមិនមានអត្តសញ្ញា ដែលធ្លាប់ចាំនូវសភាវធម៌រួមគ្នាជាលោក ។

២- **បច្ចបរិគ្គហញ្ញាណ** ៖ កាលណាវិបស្សនាញាណរលត់អស់លោកក៏ប្រាកដរួមគ្នាដូចដើម ក៏បានដឹងដោយប្រាជ្ញាញាណកើតឡើងទៀតថា រូបធម៌នាមធម៌កើតឡើងនោះ អាស្រ័យ បច្ច័យកំណត់ដឹងបាន តាមសេចក្ដីពិតជា **ញាតបរិញ្ញា** ។

៣- សម្មសនញ្ញាណ ៖ បញ្ញាឃើញរូបនាមជាត្រៃលក្ខណ៍ កើតឡើងដល់បុគ្គល អ្នកប្រកបការព្យាយាម ចម្រើនវិបស្សនា ដូចមានវចនត្ថៈសម្ដែងទុកថា **ខន្ធាទីនំ កលាបតោ សម្មសនវសប្បវត្តំ ញាណំ សម្មសន ញាណំ** ។ ប្រែថា ៖ ញាណដែលប្រព្រឹត្តទៅដោយអំណាច ការពិចារណាធម៌មានខន្ធជាដើម ដោយសេចក្ដីថា កលាប ឈ្មោះថា សម្មសនញ្ញាណ អង្គធម៌បានដល់ បញ្ញាចេតសិកនៅក្នុង មហាកុសលញ្ញាណសម្បយុត្តចិត្ត ។ វិបស្សនាញ្ញាណទាំងបីនេះ ជា តរុណវិបស្សនា ហៅថា **វិបស្សនាទន់ខ្ចី** នៅដើមដំបូង ព្រោះ ជាវិបស្សនា នៅមានការត្រិះរិះដល់នាមធម៌និងរូបធម៌កំពុង ប្រាកដច្បាស់ ដោយអាការសូន្យទទេចាកលោក ដែលធ្លាប់រួមគ្នា ។

៤- **ឧទយព្វយញ្ញាណ** ៖ ចែកបទជាបី គឺ ឧទយៈ + វយៈ + ញាណ (ផ្លាស់វជាព្វ), ឧទយៈ ការកើតឡើង, វយៈ ការអស់ទៅ បានសេចក្ដីថា បញ្ញាឃើញការកើតឡើង និងប្រែប្រួលអស់ទៅ របស់រូបនាមដូចមានវចនត្ថៈថា **ឧប្បាទភង្គានុបស្សនាវសប្បវត្តំ ញាណំ ឧទយព្វយញ្ញាណំ** ប្រែថា ញាណដែលប្រព្រឹត្តទៅ ដោយអំណាចការពិចារណានូវការកើតឡើងនិងការរលត់ នៃ

សង្ខារទាំងឡាយ អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណសម្បយុត្តចិត្ត ។

៥- **ភង្គញ្ញាណ** :បញ្ញាពិចារណា ឃើញការរលត់បែកធ្លាយនូវរូបនាម ដោយចំណែកតែមួយដូចមានវចនត្ថៈ សម្តែងថា **ឧទយំ មុញ្ចិត្វា វយេ បវត្តំ ញាណំ ភង្គញាណំ** ប្រែថា ញាណ អនុលោមដល់ការកើតហើយនិងវិនាសទៅវិញ អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណ សម្បយុត្តចិត្ត ។

៦- **ភយញ្ញាណ** : ជាញាណដែលកំណត់រូបនាម ដោយភាពជារបស់គួរខ្លាចដូចមានវចនត្ថៈថា : **សង្ខារានំ ភយតោ អនុបស្សនាវសេន បវត្តំ ញាណំ ភយញាណំ** ប្រែថា ញាណ ដែលប្រព្រឹត្តទៅដោយអំណាចការពិចារណារឿយៗ ដល់សង្ខតធម៌ទាំងឡាយ ដោយភាពគួរខ្លាច អង្គធម៌បានដល់ បញ្ញាចេតសិក ។

៧- **អាទីនវញ្ញាណ** : ជាញាណដែលឃើញសង្ខាររូបនាម ជាទោស ដូចមានវចនត្ថៈថា **ទិដ្ឋសង្ខារានំ អាទីនវតោ បេក្ខានវសេន បវត្តំ ញាណំ អាទីនវញាណំ** ។ ប្រែថា ញាណដែលប្រព្រឹត្តទៅ ដោយអំណាចការសម្លឹងពិនិត្យដល់

សង្ខារថាជារបស់ គួរខ្លាចដែលខ្លួនបានឃើញ ហើយដោយភាពជាទោស ។ អង្គធម៌ បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណសម្បយុត្តចិត្ត ។

៨- **និព្វិទាញាណ** : ជាបញ្ញាដែលពិចារណា ឃើញនាមរូបដោយអាការគួរនឿយណាយ ។ ចែកបទ និព្វិទា + ញាណ ; និព្វិទា (ការនឿយណាយ), ញាណ គឺបញ្ញាការដឹង ។ និព្វិទាញាណជាបញ្ញាពិចារណាឃើញនាមរូប ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជារបស់គួរខ្លាចពេញដោយទុក្ខទោសច្រើនប្រការ ហើយក៏កើតការនឿយណាយមិនប្រាថ្នាចង់បាននាមរូប មិនប្រាថ្នាត្រឡប់មកកើតទៀត ប្រាថ្នាឱ្យបានដល់ព្រះនិព្វានយ៉ាងរហ័ស នេះហៅថាភាវនាមយបញ្ញា គឺ បញ្ញាដែលកើតដល់អ្នកចម្រើនវិបស្សនាកម្មដ្ឋានប៉ុណ្ណោះ មិនមែនសុតាមយបញ្ញា និង ចិន្តាមយបញ្ញាឡើយ ។

៩- **មុញ្ចិតុកម្យតាញាណ** : ជាញាណមានការប្រាថ្នាផុតចាកនាមរូប ដោយពិចារណាឃើញនាមរូប ជារបស់គួរខ្លាចមានទុក្ខ មានទោស ជានុយធ្វើឱ្យវង្វេងនៅក្នុងសង្សារវដ្ដ ជាសង្ខារប្រជុំតាក់តែងឱ្យបានទទួលនូវសេចក្ដីក្ដៅក្រហាយ និងមានការប្រែប្រួលជានិច្ច ចិត្តក៏កើតសេចក្ដីនឿយណាយ ប្រាថ្នារក

ឧបាយគេចចេញផុតពីសង្ខារធម៌ ប្រាថ្នាឱ្យផុតចាកសង្សារវដ្ត ចិត្តក៏បង្អោនទៅរកព្រះនិព្វាន ។

១០- **បដិសង្ខាញ្ញាណ** : ជាញ្ញាណពិចារណាឃើញនាមរូបដោយសង្ខាតឱបាតចាកមុញ្ចិតុកម្យតាញ្ញាណ ។ បដិសង្ខាញ្ញាណចែកបទមាន ៣ គឺ បដិ + សង្ខា + ញ្ញាណ ; បដិៈ សេចក្តីថាចំពោះ តប ត្រឡប់ ទៀត ; សង្ខាៈការពិចារណា ; ញ្ញាណជាតួបញ្ញា បានដល់ ការដឹងជុំវិញក្នុងកងសង្ខារតាមសេចក្តីពិត ។ បដិសង្ខាញ្ញាណ គឺបញ្ញាត្រឡប់ទៅពិចារណាសង្ខារ លើកឡើងចំពោះត្រៃលក្ខណ៍ធម៌ ដោយអាការ ៤០ គឺ អនិច្ចំ ១០ យ៉ាង ទុក្ខដោយអាការៈ ២៥ យ៉ាង និងអនត្តាដោយអាការ ៥ យ៉ាង ។

១១- **សង្ខារុបេក្ខាញ្ញាណ** : ជាញ្ញាណពិចារណាឃើញរូបនាមដោយអាការព្រងើយក្នុងសង្ខារនិមិត្តអារម្មណ៍ ដែលចែកបទសង្ខារ + ឧបេក្ខា + ញ្ញាណ ; សង្ខារ គឺសភាវធម៌មានបច្ច័យប្រជុំតាក់តែង បានដល់ ខន្ធ ៥ ឬរូប និងនាម. ឧបេក្ខាៈ ភាពព្រងើយជាកណ្តាលៗ ដែលចិត្តមិនភ្លើតភ្លើន ; ញ្ញាណ គឺបញ្ញា ។ ដូច្នោះសង្ខារុបេក្ខាញ្ញាណ ជាបញ្ញាពិចារណាឃើញនាមរូបមិនទៀងចាកសត្វបុគ្គល បង្គាប់បញ្ញាមិនបានដែលមានសតិកំណត់បានថាជាទុក្ខ ជាអនត្តា ។

១២- **អនុលោមញាណ** : ញាណអនុលោមដែលពិចារណានូវលក្ខណៈ ទាំងបី (មិនទៀងជាទុក្ខជាអនត្តា) ទៅតាមលំដាប់ឱ្យសម្រេចកិច្ចនៃវិបស្សនាញាណ ៨ ដោយមានរូបនាមជាអារម្មណ៍ ឬអនុលោមទៅតាមពោធិបក្ខិយធម៌ ៣៧ ឬសច្ចានុលោមិកញាណ ចែកបទជាសច្ចៈ + អនុលោមិក + ញាណ ។

សច្ចៈប្រែថា សេចក្តីពិត, អនុលោមិកៈ ប្រែថាការប្រព្រឹត្តទៅតាមលំដាប់ ចាប់ពីញាណទាបរហូតដល់ខ្ពស់ ។

១៣- **គោត្រភូញាណ** : បញ្ញាបំផ្លាញគោត្ររបស់បុថុជ្ជនចូលទៅគោត្ររបស់ព្រះអរិយជាម្ចាស់ ។

១៤- **មគ្គញ្ញាណ** : ជាញាណកាត់ផ្តាច់នូវកិលេសជាសមុច្ឆេទដោយអរិយមគ្គមានព្រះនិព្វានជាអារម្មណ៍ តាមលំដាប់មគ្គមានសោតាបត្តិមគ្គញាណ សកទាគាមិមគ្គញាណ អនាគាមិមគ្គញាណ និងអរហត្តមគ្គញាណ ។

១៥- **ផលញ្ញាណ** : បន្ទាប់ពីសោតាបត្តិមគ្គរលត់ទៅ ផល ចិត្តដែលជាវិបាករបស់មគ្គចិត្តកើតឡើង ២ ឬ៣ ខណៈ មគ្គចិត្ត ជាអនន្តរិកសមាធិ គឺមគ្គសមាធិ នាំឱ្យអរិយផលកើតភ្លាម ព្រោះជាលោកុត្តរកុសលទាំងឡាយ មានវិបាកកើតជានិច្ច ដែលជា

ផលពិតតាមលំដាប់ ដូចមគ្គញ្ញាណគឺ សោតាបត្តិផលញ្ញាណ សកទាគាមិផលញ្ញាណ អនាគាមិផលញ្ញាណ និងអរហត្តផលញ្ញាណ ។

១៦-**បច្ចវេក្ខណញ្ញាណ** ៖ ជាញាណដែលពិចារណាឃើញមគ្គ ១ ផល ១ និព្វាន ១ កិលេសដែលនៅសល់ ១ និងកិលេសដែលលះហើយ ១ ដោយអំណាចមគ្គទាំង ៤ ចំណែកព្រះអរហន្ត មានត្រឹម ៤ ព្រោះពុំមានកិលេសដែលនៅសល់សម្រាប់ពិចារណាតទៅទៀត ទាំងអស់មាន ១៩ ឬ ហៅថា វិមុត្តិញ្ញាណទស្សនៈក៏បាន ។ ចំពោះវិបស្សនាញាណ ៣ គឺ មុញ្ចិតុកម្យតាញាណ ១ បដិសង្ខាញាណ ១ និងសង្ខារុបេក្ខាញាណ ១ មានន័យតែមួយ ផ្សេងគ្នា ដោយព្យញ្ជនៈ ។

ព្រះយោគាវចរ បុគ្គលអ្នកបានសម្រេចដល់ នាមរូបបច្ចយបរិគ្គហញ្ញាណ រមែងបាន **ធូរស្រាលចិត្ត** ក្នុងព្រះពុទ្ធសាសនា ឈ្មោះថា **ចូឡសោតាប័ន** មានគតិទៀង ក្នុងជាតិទី ២ ខាងមុខ បន្ទាប់អំពីស្លាប់ក្នុងជាតិនេះ នឹងបិទអបាយភូមិ ទៅកើតក្នុងសុគតិភូមិទេវលោក ប្រសិនបើញាណ នេះមិនត្រូវវិនាស ។ ប៉ុន្តែជាតិទី ៣ តទៅ មិនប្រាកដថាបិទអបាយភូមិទៀតទេ លុះត្រាតែមាន សេចក្ដីព្យាយាមអប់រំ ចម្រើនវិបស្សនាថែមទៀត រហូតបានសម្រេចអរិយមគ្គអរិយផល ទើបបិទអបាយភូមិបាន ។

➢ លក្ខណាទិចតុក្កៈ របស់ បញ្ញា ចេតសិក

១- **ធម្មសភាវបដិវេធលក្ខណា :** មានការដឹងពិតនូវសភាវធម៌ ជាលក្ខណៈ

២- **មោហន្ធការវិទ្ធំសនរសា :** មានការកម្ចាត់បង់នូវសេចក្តីងងឹត ឬមានការឆ្លុះបំភ្លឺនូវសភាវធម៌ទាំងឡាយ ជាកិច្ច

៣- **អសម្មោហបច្ចុប្បដ្ឋានា :** មានការមិនវង្វេង ជាផល

៤- **សមាធិបទដ្ឋានា :** មានសមាធិ ជាហេតុជិត

ឬ ឥន្ទ្រិយបរិបាកតាបទដ្ឋានា : មានវិន័យដែលបរិបូណ៌ដោយបញ្ញា ជាហេតុជិត ឬ **កិលេសសទូរិភាវបទដ្ឋានាៈ** មានការឆ្ងាយពីកិលេសទាំងឡាយ ជាបទដ្ឋាន ឬ **តិហេតុកបដិសន្ធិកតាបទដ្ឋានា :** មានបដិសន្ធិចិត្តជាត្រៃហេតុ ជាហេតុជិត ។

សេចក្ដីពិតក្នុងអរិយសច្ចៈ និងនិព្វានសច្ចៈ

មកដោយពិត សម្ដែងប្រាប់ពីទីបំផុតនៃលោកមាន អរិយសច្ចៈ និងនិព្វានសច្ចៈ ជា **គោលដៅ** ។

ពាក្យថា អរិយសច្ចៈ ជាសច្ចរបស់ព្រះអរិយៈមានព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលព្រះអង្គបានរួចផុតចេញពីលោក បង្ហាញប្រាប់ឱ្យដឹងនូវអ្វីៗក្នុងលោក តែងមានការប្រែប្រួលវិនាសទៅវិញ ព្រោះអស់ហេតុប្បច្ច័យក្នុងសភាវៈនីមួយៗរបស់ធម្មជាតិ ។

អរិយសច្ចៈមាន ៤ បានដល់ អ្វីខ្លះ ?

១- ធម្មជាតិជាទុក្ខសច្ចៈ មានការប្រែប្រួលនៃសង្ខារធម៌ បានដល់ខន្ធ ៥ សំដៅទៅលើមនុស្សសត្វគ្រប់គ្នា កាលបើមានជាតិមកហើយ ត្រូវតែមាន ជរា ព្យាធិ មរណៈ ហៅថា សភាវទុក្ខ ។ ក្នុងរយៈពេលកំពុងរស់នៅតែងជួបនូវ សេចក្ដី សោក បរិទេវ ទុក្ខ ទោមនស្ស ឧបាយាស អប្បិយេហិសម្បយោគទុក្ខ បិយេហិវិប្បយោគទុក្ខ យម្បិច្ឆំនលភតិតម្បិទុក្ខ ជាបកិណ្ណកទុក្ខ របស់ផលវិបាកដែលសាងសន្សំដោយខ្លួនឯង ។ សេចក្ដីទុក្ខជាធម៌

ប្រចាំសង្ខារលោក កាលណាបើ យើងខ្វះការសិក្សាពីព្រះពុទ្ធវចនះ ក៏ពុំបានដឹងនូវការពិតរបស់ទុក្ខ នៅក្នុងជីវិតខ្លួនម្នាក់ៗ ហើយក៏ចេះ តែទៅស្វែងរកអ្វីៗ ពីខាងក្រៅ យកមកជួយសម្រួលនូវសេចក្ដីទុក្ខ សោកនោះ ។

អង្គធម៌ បរមត្ថ ដែលជាទុក្ខសច្ចៈ បានដល់លោកិយចិត្ត ៨១ ដួង និងចេតសិក ៥១ (វៀរលោភចេតសិកជាទុក្ខសមុទិយសច្ចៈ) ព្រមទាំងរូប ២៨ ផង ។

ចែកជាតិកមាតិកាក្នុងអភិធម្មសង្គណី **គឺទុក្ខសច្ចៈជាកុសល** បានដល់ លោកិយកុសលចិត្ត១៧ ដួង (៨+៥+៤) ចេតសិក ៣៨ (១៣+២៥) ។ **ទុក្ខសច្ចៈជាអកុសល** បានដល់ អកុសលចិត្ត ១២ ដួង (៨+២+២) ចេតសិកសម្បយុត្ត ២៦ (១៣+១៣ វៀរលោភ) ។ **ទុក្ខសច្ចៈ ជាអព្យាក្រិត** បានដល់ លោកិយវិបាកចិត្ត ៣២ ដួង (២៣+៩) កិរិយាចិត្ត ២០ (១១+៩) ចេតសិក ៣៥ (១៣+២២ វៀរវិរតិ ៣) រូប ២៨ ។

សារៈសំខាន់នៃការសិក្សាអរិយសច្ចៈទី ១ គឺព្រមទទួលការពិតដែលទាក់ទងនឹងទុក្ខ តាមដែលទុក្ខនោះប្រព្រឹត្តទៅរួចហើយ ដោយសម្លឹងមើលជីវិតប្រព្រឹត្តទៅតាមសេចក្ដីពិត ។

(ដកស្រង់ពីក្នុងជំនួយសតិភាគ ១៣ របស់លោកគ្រូអគ្គបណ្ឌិត ជាម្ចាស់) ។

ទុក្ខទាំងអស់ដោយបំព្រួញនៅត្រឹមទុក្ខរបស់ **ឧបាទានក្ខន្ធ ៥ សង្ខិត្តេន បញ្ចុបាទានក្ខន្ធាទុក្ខា** ដែលអ្វីៗ កើតឡើង សុទ្ធតែជាទុក្ខទាំងអស់ ឯទុក្ខនោះត្រូវតែរលត់ទៅវិញជាធម្មតា **យំ ទុក្ខំ តំ និរុជ្ឈន្តិ** ។

លក្ខណាទិចតុក្កៈ របស់ ទុក្ខ

១- **កាយបីឡនលក្ខណំ** : មានការបៀតបៀនរាងកាយ ជាលក្ខណៈ

២- **ទុប្បលញ្ញានំ ទោមនស្សករណរសំ** : មានការធ្វើឱ្យក្រោធខឹង ភ័យខ្លាច ខូចចិត្តកើតឡើងដល់បុគ្គលដែលមានបញ្ញាទន់ខ្សោយ ជាកិច្ច

៣- **កាយិកាពាធបច្ចុប្បដ្ឋានំ** : មានអាពាធផ្លូវកាយ ជាផល

៤- **កាយបសាទបទដ្ឋានំ** : មានកាយបសាទ ជាហេតុជិត ។

អត្ថ របស់ ទុក្ខអរិយសច្ចៈ

១- **បីឡនត្ថោ** : មានការបៀតបៀនជានិច្ច

២- **សង្ខតត្ថោ** : មានការប្រជុំតាក់តែងរឿយៗ

៣- **សន្តាបត្ថោ** : មានសភាពក្តៅរោលរាលក្រហល់ក្រហាយ មិន ស្រាកស្រាន្ត

៤- **វិបរិណាមត្ថោ** : មានសភាពមិនឋិតថេរប្រែប្រួលជានិច្ច ។

សភាវទុក្ខ កើតឡើងមានហេតុប្បច្ច័យគ្រប់គ្រាន់ ដោយតណ្ហាជាសមុទយទុក្ខ ដូចជា សម្ភារគ្រប់ប្រភេទ ដែលជាតួសភាវៈកើតឡើងយ៉ាងដូច្នោះ ។ របស់ណាកើតឡើងរបស់នោះជាទុក្ខ ដែលថាមិនមែនទុក្ខ ព្រោះរំលត់តណ្ហាដោយនិរោធអរិយសច្ចៈ មានអដ្ឋង្គិកមគ្គអង្គ ៨ បានដល់ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ របស់ធម្មប្រាសាទ ។

ចំពោះព្រះនិព្វាន ជ្រៅល្អិតជាងចិត្តមានការលំបាកនឹងយល់ ព្រោះត្រូវលះបង់ ការប្រកាន់ដល់សង្ខារទាំងឡាយទាំងពួងដែលជាទុក្ខសច្ចៈ ដោយបញ្ញា គឺការរំលត់តណ្ហាជាសមុទយទុក្ខក៏ជាការស្រេចដូច មាន **លក្ខណាទិចតុក្កៈ** ទ្រង់ត្រាស់ទុក ។

១- **សន្តិលក្ខណា** : មានសេចក្តីសុខស្ងប់ឃ្លាតចាកពីទុក្ខទាំងពួង ជាលក្ខណៈ

២- **អច្ចុតរសា** : មានការមិនបែកធ្លាយ ឬមិនស្លាប់ជាកិច្ច

៣- **អនិមិត្តបច្ចុប្បដ្ឋានា** : មានការមិនមាននិមិត្តគ្រឿងសម្គាល់ ជាអាការប្រាកដ ឬ **និស្សរណបច្ចុប្បដ្ឋានា** : មានការរលាស់ចេញឃ្លាតចាកភព ជាផល

៤- **បទដ្ឋានំន លព្ភតិ** : មិនមានហេតុជិតឱ្យកើត ព្រោះព្រះនិព្វានជាធម៌ផុតចាកហេតុ ផុតចាកបច្ច័យទាំងពួង ប្រជុំតាក់តែងពុំមានលក្ខណៈកំណត់សម្គាល់អ្វីឡើយ ។

កាលណារំលត់តណ្ហាអស់មិនមានសេសសល់ ហៅថា **សឧបាទិសេសនិព្វាន** គឺព្រះនិព្វាននៅសល់បញ្ចក្ខន្ធ លុះតែរលត់បញ្ចក្ខន្ធទៀតទើប ហៅថា **អនុបាទិសេសនិព្វាន** និងព្រះសារីរិកធាតុ ហៅថា **និព្វានធាតុ** ។ ដូច្នេះសព្វថ្ងៃនេះនៅមានព្រះពុទ្ធសាសនានូវឡើយ គួរខិតខំសិក្សាតាមព្រះពុទ្ធវចនៈ កុំបោះបង់ចោល ទៅចាប់បដិសន្ធិយកអ្វីៗដទៃផ្សេងពីខាងក្រៅ ដែលមិនមែនជា ការពិតរួចផុតចាកទុក្ខ ។ កាលបើដល់

ពេលកំណត់គ្រប់ ៥០០០ ព្រះវស្សា ព្រះបរមសារីរិកធាតុទាំងឡាយ ទោះធំឬតូចល្អិត ឋិតនៅទីស្ថានណា ក៏ត្រូវប្រមូលមកប្រជុំគ្នានៅកន្លែងព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងក្រោមដើមព្រះមហាពោធិព្រឹក្ស មានព្រះវរកាយ គង់ជាសមាធិប្រកបដោយពន្លឺរស្មី ៦ ពណ៌ ដែលព្រះពុទ្ធអង្គទ្រង់បានអធិដ្ឋានទុកធ្វើឱ្យពួកទេវតាបានឃើញយ៉ាងច្រើន ចក្កវាឡ ហើយក៏ជាការឃើញចុងក្រោយបង្អស់របស់ព្រះដ៏មានព្រះភាគ តែពុំមានសម្ដែងធម៌អ្វីទេ ។ បន្ទាប់ពីនោះភ្លាម ទើបតេជោធាតុឆេះព្រះបរមសារីរិកធាតុដែលមានពន្លឺ បាញ់ស្រួចឡើងទៅលើរហូតដល់ព្រហ្មលោក គឺជាការផុតរលត់អស់ព្រះពុទ្ធសាសនា ហៅថានិព្វានធាតុ ឬបរិនិព្វានរបស់សាសនាព្រះសមណគោតមត្រឹមប៉ុណ្ណោះ សេចក្ដីនេះមាននៅក្នុងព្រះអដ្ឋកថា ។

សតិប្បដ្ឋាន (ជំហានទី ៦)

មកដោយពិត នាំយកធម្មប្រាសាទ ដែលជាទីតាំងនៃគ្រឹះបញ្ញាមានសតិប្បដ្ឋាន ៤ រលឹកដឹងនូវសភាវធម៌កំពុងប្រាកដតាមទ្វារ ៦ ណាមួយ បានដល់ រូបធម៌នាមធម៌ ដោយញាតបរិញ្ញាយ៉ាងជាក់ច្បាស់មិនស្រពេចស្រពិល ព្រោះរូបធម៌ នាមធម៌កើតឡើងតាមចក្ខុទ្វារជាដើម ឃើញត្រឹមតែវណ្ណរូប ជានិមិត្តរបស់មហាភូតរូប ៤ បូកសរុបថា មាន ២៨ តាមដែលបានសិក្សារួចមកហើយ ។

សតិប្បដ្ឋានមានអនុបស្សនា ៧ ជួយជ្រោមជ្រែងទំនុកបម្រុង និងជាឫសគល់ ។

១- **អនិច្ចានុបស្សនា** : បញ្ញា លះនូវនិច្ចសញ្ញា

២- **ទុក្ខានុបស្សនា** : បញ្ញា លះនូវសុខសញ្ញា

៣- **អនត្តានុបស្សនា** : បញ្ញា លះនូវអត្តសញ្ញា

៤- **និព្វិទានុបស្សនា** : បញ្ញា លះនូវនន្ទិ (សេចក្តីភ្លើតភ្លើន)

៥- **វិរាគានុបស្សនា** : បញ្ញា លះនូវរាគធម៌

៦- **និរោធានុបស្សនា** : បញ្ញា លះនូវសមុទយទុក្ខ

៧- **បដិនិស្សគ្គានុបស្សនា:** បញ្ញា លះនូវអាទាន (សេចក្ដីប្រកាន់) ។

កាលបើបានកំណត់ដឹងនូវសង្ខារធម៌គឺរូបធម៌នាមធម៌ជាក់ច្បាស់ហើយ អង្គមគ្គ ៥ ជាលោកិយមាន សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ កើតឡើងភ្លាម ដើរតួជាបញ្ញាចេតសិក កម្ចាត់បង់កិលេសជាខណៈៗមិនទាន់សមុច្ឆេទ ព្រោះមិនទាន់ចូលដល់មគ្គសមង្គី គ្រប់អង្គ ៨ ដែលជាលោកុត្តរៈ ។

ការរលឹកដឹងនូវរូបធម៌នាមធម៌តាមទ្វារ ៦ ធ្វើឱ្យយើងធ្លាប់យល់ច្រឡំថា :

តាម ចក្ខុទ្វារ យើងជាអ្នកឃើញរូប

តាម សោតទ្វារ យើងជាអ្នក ឮសំឡេង

តាម ឃានទ្វារ យើងជាអ្នកដឹងក្លិន

តាម ជិវ្ហាទ្វារ យើងជាអ្នកដឹងរស

តាម កាយទ្វារ យើងជាអ្នកដឹងផោដ្ឋព្វៈ

តាម មនោទ្វារ យើងជាអ្នកដឹងធម្មារម្មណ៍ ។

ចំណែកការពិតវិញ

តាមទ្វារភ្នែក បានដល់ ពណ៌ (រូប) មានលក្ខណៈជារបស់ដែលប្រាកដផ្លូវភ្នែក ។ **ការឃើញ** (នាម) មានលក្ខណៈត្រឹមតែ ជាសភាវដឹងតាមផ្លូវភ្នែក ។

តាមផ្លូវត្រចៀក បានដល់ សំឡេង (រូប) មានលក្ខណៈជារបស់ដែលប្រាកដផ្លូវត្រចៀក ។ **ការឮ** (នាម) មានលក្ខណៈត្រឹមតែ ជាសភាវដឹងតាមផ្លូវត្រចៀក ។

តាមផ្លូវច្រមុះ បានដល់ ក្លិន (រូប) មានលក្ខណៈជារបស់ដែលប្រាកដផ្លូវច្រមុះ ។ **ការដឹងក្លិន** (នាម) មានលក្ខណៈត្រឹមតែ ជាសភាវដឹងតាមផ្លូវច្រមុះ ។

តាមផ្លូវអណ្តាត បានដល់ រស (រូប) មានលក្ខណៈជារបស់ ដែលប្រាកដតាមផ្លូវអណ្តាត ។ **ការដឹងរស** (នាម) មានលក្ខណៈ ត្រឹមតែ ជាសភាវដឹងតាមផ្លូវអណ្តាត ។

តាមផ្លូវកាយ បានដល់ ផោដ្ឋព្វៈ (រូប) មានលក្ខណៈត្រឹមតែ ជារបស់ដែលប្រាកដផ្លូវកាយ ។ **ការដឹងផោដ្ឋព្វៈ**

(នាម) មាន លក្ខណៈត្រឹមតែ ជាសភាវដឹងតាមផ្លូវកាយ ដែលមាន គ្រឿងសម្គាល់តពីពាក្យដើមថា មិនមែនសត្វ បុគ្គល ដែលទ្វារ ភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទាំង ៥ នេះ ជាបរមត្ថ (រូបនាម) កើតហើយត្រូវរលត់ទៅវិញភ្លាម ដូចជា សំឡេង (រូប) ជាមួយការបានឮ (នាម) ខណៈនេះ កើតហើយ ត្រូវរលត់យ៉ាងរហ័ស និងហាមឃាត់មិនបាន = មិនមែនតួខ្លួន (អនត្តា) ។

ពាក្យថា **ផោដ្ឋព្វៈ** (របស់ដែលប៉ះខ្ទប់សម្ផស្សកាយ) បានដល់ អាការរបស់ធាតុដី ធាតុភ្លើង ធាតុខ្យល់ ដែលដឹងបានតាមទ្វារកាយ គឺ កាយវិញ្ញាណចិត្តចូលទៅដឹង ឯចំណែកធាតុទឹកដែលជាសុខុមរូប និងអាចដឹងបានតាមផ្លូវចិត្ត ។ រូបតាមផ្លូវកាយបានដល់ រឹងទន់ ក្តៅត្រជាក់ ញ៉ូរតឹង ឯនាមតាមផ្លូវកាយបានដល់ ដឹងរឹងទន់ ដឹងក្តៅត្រជាក់ ដឹងញ៉ូរតឹង (ស្រង់ចាកពីក្នុង អដ្ឋសាលិនី អដ្ឋកថា ផោដ្ឋព្វាយតននិទ្ទេស រូបកណ្ឌ ធម្មសង្គណី ព្រះអភិធម្មបិដក) ។

តាមផ្លូវចិត្ត : ចិត្តទទួលអារម្មណ៍ ដែលរលត់ទៅហើយបន្តពីបញ្ចទ្វារ កើតរលត់តទៅទៀតច្រើនវារៈ កន្លែងនេះព្រះដ៏មានព្រះភាគទ្រង់សម្តែងធមិជាអនេកបរិយាយដល់អ្នកស្តាប់

មិនហួសពីភូមិវិបស្សនា មិនក្រៅអ្វីពីខន្ធ ៥ អាយតន ១២ ធាតុ ១៨ អរិយសច្ច ៤ ឥន្ទ្រិយ៍ ២២ បដិច្ចសមុប្បាទ ១២ ដែលប្រជុំចុះនៅក្នុងរូបធម៌នាមធម៌ សម្រាប់ការអប់រំចម្រើនសតិប្បដ្ឋាន គឺការពិចារណាខន្ធ ៥ ឬភូមិវិបស្សនាដូចពោលមកនោះឯង ។ ទ្រង់ត្រាស់ទូន្មាន ព្រះបុណ្ណៈ ព្រះរាហុល ព្រះពាហិយៈ បានសម្រេចធម៌ជាព្រះអរហន្ត ក៏នៅក្នុងរឿងអាយតនៈ ១២ នេះឯង ។ ដូច្នោះការអប់រំបញ្ញា គឺការអប់រំចម្រើនសតិប្បដ្ឋាន មានពោធិបក្ខិយធម៌ (អង្គធម៌ គឺបញ្ញា) បានដល់ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងអរិយមគ្គមាន អង្គ ៨ តើត្រូវចម្រើនយ៉ាងណា ?

ជាដំបូងត្រូវឱ្យយល់សតិប្បដ្ឋានជាមុន ដែលមិនមែនសតិប្រព្រឹត្តទៅក្នុង **ទាន** ក្នុង **សីល** ឬថាក្នុង **សេចក្តីស្ងប់របស់ចិត្ត** ។ សតិកើតជាមួយកុសលគ្រប់ប្រភេទ ព្រោះហេតុដូច្នោះក៏ត្រូវដឹង សេចក្តីផ្សេងគ្នារវាងសតិដែលកើតក្នុងខណៈធ្វើទាន សតិប្រព្រឹត្ត ទៅក្នុងវិរតិទុច្ចរិត ដែលខណៈនោះក៏មិនអាចដឹងសេចក្តីពិត របស់សភាវធម៌បាន ឬសូម្បីខណៈដែលចិត្តសន្តានស្ងប់ចាក អកុសលខណៈនោះ ក៏មិនអាចនឹងដឹងថា មិនមែនយើង

អ្នកស្ងប់ ព្រោះដូច្នោះសេចក្ដីផ្សេងគ្នា រវាងសតិប្រព្រឹត្តទៅក្នុងកុសល ប្រភេទដទៃជាមួយសតិប្បដ្ឋាន ក៏គឺអ្នកដែលមានសតិប្បដ្ឋាន ត្រូវជាអ្នកមានការស្ដាប់ព្រះធម៌រឿយៗ ដើម្បីឱ្យបានយល់ ពីរឿងសភាវធម៌ក្នុងខណៈនេះថា មិនមែនយើង មិនមែនមាន តួខ្លួន ។ សភាវធម៌ក្នុងខណៈនេះមានពិតជាអ្វី បានដល់ ពោធិបក្ខិយធម៌ ដែលជាចំណែកខាងការត្រាស់ដឹងនូវសភាវធម៌ តាមសេចក្ដីពិត គឺអរិយសច្ចធម៌ ។ ឯសតិក្នុងខណៈដែលកំពុង ឱ្យទាន ឬវិរតិទុច្ចរិត ប្រព្រឹត្តទៅក្នុងសីល មិនមែនសតិន្ទ្រិយ មិនមែនពោធិបក្ខិយធម៌ ប៉ុន្តែខណៈណាមានសតិកើតឡើងរលឹក ដឹងលក្ខណៈរបស់សភាវធម៌ សតិខណៈនោះត្រូវកើតរួមជាមួយ សម្មាទិដ្ឋិ ទើបសម្មាសតិ ខណៈនោះជាសតិន្ទ្រិយ ។ ឧទាហរណ៍ : ដូចជាពេលបានទទួលបាច់ផ្កា ឬភួងមាល័យក៏ធ្វើឱ្យចិត្តអ្នកឱ្យ និងអ្នកទទួលកើតកុសល តែមិនមែនសតិន្ទ្រិយ ប្រសិនបើសតិ មិនរលឹកដឹងលក្ខណៈ របស់សភាវធម៌ថា ជានាមធម៌ ឬរូបធម៌ ។

សូមលើកឡើងពីឥន្ទ្រិយនិងសតិប្បដ្ឋានជាមុន ព្រោះនឹងធ្វើឱ្យយល់នូវចំណែកខ្លះៗ របស់ពោធិបក្ខិយធម៌ ។ សភាវធម៌ដែលជាឥន្ទ្រិយ គឺសភាវធម៌ជាធំបានដល់ សទ្ធា វីរិយៈ សតិ

សមាធិនិងបញ្ញាក្នុងខណៈដែលកុសលចិត្តកើត តែថាមិនទាន់ប្រកបដោយបញ្ញា ក៏មានសទ្ធា មានវិរិយៈ មានសតិនិងមានសមាធិកើតរួមផង តែខណៈណាមានសតិប្បដ្ឋានកើត ខណៈនោះសទ្ធាក៏ជាសតិន្ទ្រិយ ឯវិរិយៈក៏ជាវិរិយិន្ទ្រិយ សតិក៏ជាសតិន្ទ្រិយ សមាធិ ក៏ជាសមាធិន្ទ្រិយ បញ្ញាក៏ជាបញ្ញិន្ទ្រិយផង ព្រោះហេតុដូច្នោះសតិប្បដ្ឋានកម្រកើត តែមិនមែនហួសវិស័យនឹងកើត ដោយត្រូវមានការដឹងយល់ឱ្យត្រូវត្រង់ ។ ការអប់រំចម្រើនបញ្ញារបស់សតិប្បដ្ឋានក្នុងមគ្គមានអង្គ ៨ នឹងកើតបានត្រូវតែមានសភាវធម៌ ក្នុងខណៈដែលជានាមធម៌រូបធម៌កំពុងប្រាកដ ទោះក្នុងខណៈមុនក៏មាន ក្នុងខណៈតទៅក៏មាន ព្រោះហេតុដូច្នោះ អ្នកនឹងដឹងដោយខ្លួនឯងថា ខណៈណាសតិដ្ឋានកើត ឬខណៈណា សតិប្បដ្ឋានមិនកើត ព្រោះដូច្នោះ ពេលណាមានការយល់យ៉ាងមាំពិតៗ ក្នុងរឿងរបស់នាមធម៌រូបធម៌និងសតិប្បដ្ឋានខណៈនោះ ក៏រមែងមានបច្ច័យ ដែលសតិប្បដ្ឋាននឹងកើតបានជាប្រក្រតីធម្មតាយ៉ាងនេះឯង មិនខុសប្រក្រតីឡើយ ប្រសិនបើខុសប្រក្រតី ខណៈនោះមិនមែនជាសតិប្បដ្ឋាន ។

ព្រោះហេតុនោះពេលជាបញ្ញាពិតៗ ក៏រមែងអាចនឹងអប់រំចម្រើន រហូតដឹងសេចក្ដីពិតរបស់សភាវធម៌ដែលមានពិតៗ

ក្នុងខណៈនេះ មិនមែនដឹងរបស់ដែលមិនមែនប្រាកដ ដូច្នោះ ការអប់រំចម្រើនសតិប្បដ្ឋាន ជាការអប់រំចម្រើនបញ្ញា មិនមែនមានយើងនឹងតាំងចិត្តធ្វើនូវរបស់ណាមួយ ។ កាលណាចិត្តត្រូវពិចារណារបស់ណាមួយ ក្នុងខណៈនឹងតាំងចិត្តប្រព្រឹត្ត ខណៈនោះមិនមែនសតិរលឹកលក្ខណៈរបស់សភាវធម៌ដែលមានបច្ច័យត្រូវកើតប្រាកដ ក្នុងខណៈនេះតាមប្រក្រតី ។ អ្នកមិនយល់រឿងសតិប្បដ្ឋាន ពេលកំពុងឃើញតាមប្រក្រតីយ៉ាងនេះ ក៏នឹងអាចសួរថាធ្វើយ៉ាងណា ។ ប្រសិនបើមានអ្នកប្រាប់ឱ្យធ្វើអ្វីមួយ ខណៈនោះខុស ព្រោះមិនមានអ្នកណា អាចនឹងធ្វើសភាវធម៌ណាមួយ ឱ្យកើតឡើងបានឡើយ តែអាចនឹងស្តាប់ត្រិះរិះពិចារណា យល់រហូតទាំងដឹងថា សភាវធម៌ក្នុងខណៈនេះជាធម៌មានពិតម្យ៉ាងហើយប្រាកដតាមផ្លូវម្យ៉ាង ព្រោះហេតុដូច្នោះក៏ ត្រូវយល់ ក្នុងរឿងរបស់សភាវធម៌ដែលប្រាកដតាមទ្វារណាមួយឱ្យច្រើនឡើង ដូចជាក្នុងខណៈតាមផ្លូវភ្នែក មានរបស់កំពុងប្រាកដឱ្យឃើញ តែប្រសិនបើមិនមានចិត្ត ក៏មិនមានសភាពដឹង ឮ ធាតុដឹង គឺលក្ខណៈរបស់សភាពដែលកំពុងឃើញរបស់ដែលប្រាកដ ក៏ប្រាកដមិនបាន ប្រសិនបើក្នុងខណៈកំពុងឃើញប្រក្រតីយ៉ាងនេះហើយ មិនអាចដឹងលក្ខណៈរបស់ដែលប្រាកដ

ជាមួយសភាវធម៌ដែលឃើញ ខណៈនោះក៏មិនមែនជាការអប់រំចម្រើន វិបស្សនា ព្រោះដូច្នោះនឹងត្រូវទៅធ្វើអ្វីបាន ដែលនឹងឱ្យដឹងឱ្យយល់ត្រូវ ថាខណៈដែលឃើញនេះ ក៏ត្រឹមតែជាសភាវធម៌ក្រៅចាកខណៈ ដែលកំពុងស្តាប់យ៉ាងនេះឯង ត្រូវស្តាប់ហើយពិចារណាឱ្យរឿយៗ ទើបបានយល់ថា ជាសភាវធម៌ពិតៗ មិនមែនយើង ព្រោះជារបស់ដែលមានពិតបង្គាប់បញ្ជាមិនបាន កើតឡើងតាមប្រក្រតី តាមហេតុ តាមបច្ច័យ ។

ខណៈស្តាប់មានសតិកើតហើយ តែថាមិនមែនជាសតិប្បដ្ឋាន គឺជាសតិថ្នាក់កំពុងស្តាប់ ហើយពិចារណាយល់រឿយៗឡើង ។ គ្រប់មនុស្សដែលធ្លាប់ជ្រាបហើយថា សតិជាសង្ខារក្ខន្ធមិនមែនយើង សតិមិនមែនរូបក្ខន្ធ សតិមិនមែនវេទនាខន្ធ សតិមិនមែនសញ្ញាខន្ធ តែសតិជាសង្ខារក្ខន្ធ ដែលជាសភាវធម៌ប្រជុំតាក់តែងមិនមែនមានយើងទៅធ្វើ តែខណៈស្តាប់គឺ **កំពុងប្រជុំតាក់តែងការយល់ឱ្យកើតឡើង** ខណៈស្តាប់យល់រឿងនាមធម៌និងរូបធម៌ក្នុងខណៈកំពុងឃើញ ក៏ជាសង្ខារក្ខន្ធដែលប្រជុំតាក់តែងឱ្យកើតការយល់ក្នុងខណៈកំពុងឃើញ ។ ខណៈណាកំពុងយល់លក្ខណៈរបស់សភាវធម៌គឺមិនត្រឹមតែយល់រឿង ឬយល់ឈ្មោះរបស់សភាវធម៌ តែពេលសភាវធម៌ណាប្រាកដហើយ ក៏កំពុងយល់

រឿយៗត្រង់លក្ខណៈនោះ ថាលក្ខណៈដែលឃើញ ក៏ជាសភាពដឹងត្រឹមតែជាធាតុ ឬសភាវធម៌ម្យ៉ាង ដែលអាចនឹងកើតឡើងឃើញរបស់កំពុងប្រាកដ ។ ខណៈជាសតិប្បដ្ឋាន មិនចាំបាច់ថាត្រូវប្រើឈ្មោះ ព្រោះថាដោយច្រើនអ្នកដឹងនូវឈ្មោះ ក៏សង្ស័យថាសតិប្បដ្ឋានជាអ្វី ពេលណានឹងកើត តែប្រសិនបើមិនមានឈ្មោះមិនត្រូវប្រើឈ្មោះ ខណៈនេះមានសភាវធម៌កំពុងប្រាកដ ហើយក៏យល់រឿយៗនូវលក្ខណៈរបស់សភាវធម៌ ខណៈនោះជាសតិប្បដ្ឋាន ។

ក្នុងខណៈសភាវធម៌កំពុងប្រាកដ ដែលសតិកើតរឿយៗយល់លក្ខណៈរបស់សភាវធម៌នោះ អ្នកដទៃ នឹងប្រាប់ថាមិនមែនសតិប្បដ្ឋាន អ្នកនោះនិយាយខុសឬត្រូវ ព្រោះដូច្នោះការដែលនឹងដឹងតួពិតរបស់សភាវធម៌នោះនឹងដឹងពិតៗ ពេលសតិកើតរលឹកដឹងលក្ខណៈរបស់សភាវធម៌នោះ នៅពេលមានការយល់ផ្ដើមឡើង ឈ្មោះទាំងអស់ក្នុងព្រះត្រៃបិដក ក៏នឹងភ្លឺស្វាងតាមបញ្ញារបស់អ្នកអប់រំ និងកើតសេចក្ដីយល់ត្រូវក្នុងសភាវធម៌នោះៗ បើមិនដូច្នោះក៏មិនមានផ្លូវយល់ពីតួពិតរបស់សភាវធម៌ដោយ លក្ខណៈ ជាធាតុ ជាអាយតនៈ ជាឈ្មោះផ្សេងៗ ក្នុងព្រះត្រៃបិដកបាន ព្រោះហេតុដូច្នោះព្រះធម៌ដែលទ្រង់សម្ដែង

ទាំងអស់ចាកការត្រាស់ដឹងសេចក្ដីពិតរបស់សភាវធម៌នោះ ឬយ៉ាងណា អ្នកសិក្សានឹងដឹងតួពិតរបស់សភាវធម៌ដែលប្រាកដ ទើបអាចនឹងយល់ដល់ធម៌ទាំងអស់ ដែលទ្រង់សម្ដែងទុកតាមកម្លាំងបញ្ញាធ្លាប់បានសិក្សា ។

សូម្បីព្យញ្ជនៈដែលថា "**មិនមាន ហើយមាន ហើយរកមិនមាន**" ពេលមិនមានសំឡេង ហើយមានសំឡេង ហើយសំឡេងក៏អស់ទៅ "មិនមាន ហើយមាន ហើយរកមានមិនបាន" សភាវធម៌កើតហើយត្រូវរលត់ទៅយ៉ាងរហ័ស ព្រោះដូច្នោះពេលរបស់ណាមួយកើតឡើង ការចាំរឿងរ៉ាវពីរបស់នោះ ក៏បិទបាំងមិនឱ្យឃើញ ការកើតឡើងត្រូវរលត់ទៅវិញ នូវសភាវៈទាំងអស់តាមសេចក្ដីពិត ញ៉ាំងដល់ការចងចាំថា របស់មួយណាដែលទៀង ឯការស្ដាប់ធម៌ត្រូវត្រិះរិះពិចារណា ឱ្យជ្រៅតទៅទៀត ដោយមិនមែនស្ដាប់រឿងណាមួយ ឱ្យកន្លងហួសទៅឡើយ ។ ប៉ុន្តែគ្រប់ពាក្យដែលស្ដាប់យល់ ត្រូវប្រមូលសន្សំទុក សម្រាប់ពិចារណាឱ្យយល់ស្របចូលគ្នារបស់ ខ. សេចក្ដីតទៅទៀត សូម្បីសំឡេងដែលយើងពោលក្នុងពេលនេះ "**មិនមាន ហើយមាន ហើយរកមិនមាន**" ក៏ជារបស់ដែលគួរអស្ចារ្យយ៉ាងក្រៃលែង ដោយគិតដល់ក្នុងខណៈដែលជាភវង្គចិត្តមិនមានអ្វីប្រាកដ តែបើ

មិននិយាយតាមក្បួនតម្រា គឺមិនប្រើភាសាបាលី ប៉ុន្តែប្រើពាក្យដែលយើងអាចនឹងយល់បានគឺ **ពេលមិនមាន ហើយហេតុអ្វីទើបមាន របស់ដែលប្រាកដបាន** នេះជាការគួរអស្ចារ្យរបស់ធាតុ ដែលមិនមែនយើង ធាតុរឹងមាន ធាតុសំឡេងមាន ធាតុក្លិនមាន ធាតុក្តៅមាន ធាតុត្រជាក់មាន ធាតុក្រោធមាន ធាតុលោភៈមាន ធាតុឫស្យាមាន គ្រប់យ៉ាងជាធាតុទាំងអស់ ។ **ព្រោះពាក្យថាធម៌ជាមួយធាតុនោះ មានលក្ខណៈសម្គាល់តែមួយ** ព្រោះមិនមានម្ចាស់ មិនជារបស់អ្នកណា និងមិនមែន តួខ្លួន មិនមែនសត្វ មិនមែនបុគ្គល លក្ខណៈនីមួយៗរបស់ធាតុផ្សេងៗក៏ជា សភាវលក្ខណៈនោះៗ ឯង ដូចជា ធាតុឃើញក៏មិនមែនធាតុបាន ឮ ធាតុរឹងក៏មិនមែនជាធាតុក្លិន ពេលណាដឹងសេចក្តីពិតថា អ្វីៗគ្រប់យ៉ាងសុទ្ធតែជាធាតុប៉ុណ្ណោះ ពុំមានមនុស្ស សត្វ បុគ្គល អ្នកណាឡើយ ពេលនោះកើតបញ្ញាបានដឹងសេចក្តីពិត របស់សភាវធម៌ (ដោយសុចិន្ត) ។ ដូច្នោះដើម្បីងាយស្រួលក្នុងការសិក្សាឱ្យបានយល់ជាក់ច្បាស់នូវការអប់រំចម្រើនបញ្ញា សូមលើកយក **លក្ខណាទិចតុក្កៈ របស់សតិ** មកជម្រាបជូនឱ្យកាន់តែច្បាស់ប្រាកដថែមទៀត ។

១- **អបិលាបនលក្ខណា :** សតិមានការរលឹកនូវអារម្មណ៍

រឿយៗ គឺមានសេចក្តីមិនប្រមាទ ជាលក្ខណៈ

២- អសម្មោហរសា : សតិមានការមិនវង្វេង ជាកិច្ច

៣- អារក្ខបច្ចុប្បដ្ឋានា : សតិមានការរក្សាអារម្មណ៍យ៉ាងមាំ ជាផល

៤- ថិរសញ្ញាបទដ្ឋានា : សតិមានការចាំយ៉ាងស្ទាត់ជំនាញ ជាហេតុជិត ។

ចំណែកសតិប្បដ្ឋានមានត្រឹម ៤ គឺ ពួកកាយ ពួកវេទនា ពួកចិត្ត ពួកធម៌នៅក្នុងខ្លួនយើងជាតួសភាវៈ មាន សតិរលឹកដឹងនូវសភាវធម៌នីមួយៗ ដូចបានជម្រាបជូនជ្រាបពីការសម្តែងរបស់ម៉ែ សុចិន្ត ដែលខ្ញុំបានលើកឡើងនូវចំណែកខ្លះនៃធម្មកាយ ជាពួកធម៌ត្រាស់ដឹងមាន ៣៧ ប្រការ រួចមកហើយ គ្រាន់តែថា ពោធិបក្ខិយធម៌មានជាលោកិយនិងលោកុត្តរៈ ។ តទៅនេះនឹងលើកយកនូវចំណុចមួយទៀតមកជម្រាបជូន ។

ពាក្យថា មិនមានយើងដោយសេចក្តីដូចម្តេច ?

សតិប្បដ្ឋាន រលឹកដឹងនូវសភាវធម៌កំពុងប្រាកដ ដែលមានសម្មាទិដ្ឋិជាអង្គនៃអរិយមគ្គ ៨ កើតរួមជាមួយ ក៏មិន

បានរើសអារម្មណ៍ ទោះជាកុសលក្តី អកុសលក្តី ។ ប្រសិនបើកុសលធម៌ មិនកើតនឹងមានយើងមកពីណា ព្រោះហេតុដូច្នោះកុសលធម៌ ជាយើង ឬមិនមែនយើង អកុសលធម៌ជាយើងឬមិនមែនយើង តែកុសលធម៌ ជាកុសលធម៌ អកុសលធម៌ជាអកុសលធម៌ អ្នកណាមួយអាច នឹងដឹងបានថា កុសលធម៌ជាកុសលធម៌ អកុសលធម៌ ថាជា អកុសលធម៌ ហើយក៏មិនបានឃើញខុស ក៏មិនបានប្រកាន់នូវសភាវធម៌មិន ថាកុសលឬអកុសលថាជាយើង តែមានហេតុប្បច្ច័យឱ្យសភាវធម៌ដទៃៗកើតឡើង ព្រោះថា ព្រះសោតាបន្នបុគ្គល មិនឃើញខុសឡើយតែក៏នៅមាន អកុសលធម៌កើត ពេលមានហេតុប្បច្ច័យ នាំឱ្យអកុសលធម៌នោះៗកើត ក៏ត្រូវអប់រំចម្រើនបញ្ញាឱ្យដល់ព្រះសកទាគាមិបុគ្គល ព្រះអនាគាមិបុគ្គល រហូតដល់ព្រះអរហន្តទើបរលត់បច្ច័យ ដែលធ្វើឱ្យសភាវធម៌កើតរលត់អស់មិនមានសេសសល់ ។ ពេលព្រះអរហន្តរំលត់ ខន្ធបរិនិញ្វន ក៏មិនមានបច្ច័យ ធ្វើឱ្យសភាវធម៌ ដទៃណាៗកើតទៀតឡើយ ដែលជាផលរបស់ការអប់រំ ឃើញត្រូវ យល់ត្រូវក្រៃលែងឡើងៗ ព្រោះកាលពីមុនគ្រប់គ្នាឆ្លើយថា អកុសលធម៌មិនមែនយើង និង

កុសលធម៌ ក៏មិនមែនយើងដែរ ទាំងអស់នេះ នឹងត្រូវអប់រំបញ្ញារហូតដឹង យ៉ាងពិត១ ។

ការឃើញខុសមានពិត ឯអ្នកស្ដាប់ធម៌ត្រូវជាអ្នកត្រង់ទើបដឹងថាខុសបាន ក្រៅពីបញ្ញាហើយក៏មិនមានសភាវធម៌ ដទៃណា អាចនឹងរំលត់កិលេស ដែលលោភៈមានពិត ទោសៈមានពិត មោហៈមានពិត អកុសលទាំងឡាយមានពិត កាលបើអកុសលធម៌រលត់ ក៏មិនមែនដោយការមិនដឹងឡើយ ។ ដោយហេតុនេះ ទើបយើងឃើញថា ធម៌ទាំងឡាយកើតពីហេតុប្បច្ច័យ ពុំមានយើងជាអ្នកឧបត្ថម្ភចាត់ចែងធ្វើឱ្យអ្វី១កើតឡើង ដូចដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងទុកពីអនត្តាធម៌ សម្រាប់ប្រោសដល់វេនេយ្យសត្វ ដែលកំពុងសិក្សាឱ្យបានរួចផុត ឆ្លងដល់ត្រើយនៃកិលេស ហៅថា អមតធម៌ ។ ក្នុងសម័យពុទ្ធកាលនៅ **និគមកម្មាសធម្មៈដែនកុរុ** មានអ្នកអប់រំភាវនាមិនរាប់ថាពួកទាសករ គេនិយាយគ្នាតែពីរឿងសតិប្បដ្ឋាន ទោះបីកំពុងធ្វើការងារអ្វី ឬជួបគ្នាទៅដងទឹកនៅឯកំពុងក្ដី បានសេចក្ដីថាសតិប្បដ្ឋានមិនរើសអារម្មណ៍ និងមិនរើសទីកន្លែង ឬពេលវេលាឱ្យតែសតិកើតឡើងក៏អាចបដិបត្តិបានទាំងអស់ ។

មេរៀនជីវិត

¤ បើចង់ចេះ ខំប្រឹងស្តាប់ ដោយគោរព
នៅក្រោមម្លប់ ធម្មទេសនា ទ្រង់សម្តែង
បើកបញ្ញា ដោយសទ្ធា ជួយចាត់ចែង
ស្រូបយកផ្សែង ពន្លឺពិត ចិត្តស្មោះត្រង់ ។

¤ បើចង់ចេះ ស្វែងតម្រិះ ដោយព្យាយាម
កុំរវាម ជាប់ក្លិនផ្កាប ពិបាកទ្រាំ
មិនប្រកាន់ ជ្រះស្រឡះ ទើបរឹងមាំ
តាមលំនាំ ច្បាប់ធម្មជាតិ រួចផុតទុក្ខ ។

¤ បើចង់ចេះ កុំប្រហែស ខំសិក្សា
ចិត្តប្រាថ្នា រកប្រយោជន៍ ឱ្យបានសុខ
សន្សំបុណ្យ កុំសន្សំ មាសប្រាក់ទុក
ទៅខាងមុខ មានតែធម៌ ទើបយកបាន ។

¤ អ្នកមានទ្រព្យ គេទម្លាប់ ចាយខ្ជះខ្ជាយ
ចិត្តរាយមាយ តាមចំណង់ ដើរកម្សាន្ត
ក្បែរមាត់ស្ទឹង ធ្វើដំណើរ ជិះក្នុងឡាន
មានកល្យាណ ស្រីអូនបង សើចសប្បាយ ។

¤ សប្បាយណាស់ សប្បាយណាស់ ក្លាយជាទុក្ខ
នៅមិនសុខ ព្រោះតណ្ហា មិននឿយណាយ
ឃើញអ្វីៗ សុទ្ធតែល្អ ដូចដុំបាយ
ហ៊ានចំណាយ ឱ្យតែព្រម ល្មមក្នុងចិត្ត ។

¤ មកដោយពិត ចុះពិនិត្យ មើលសព្វគ្រប់
នៅក្រោមម្លប់ ឈើត្រជាក់ ត្រិះរិះគិត
ឃើញលោកនេះ មិនទៀងទាត់ គួរអាណិត
បាបតាមកិត ជាប់ពីក្រោយ គ្មានដឹងខ្លួន ។

¤ មកដោយពិត គួរធ្វើល្អ ក្រមិនយូរ
ជាគំរូ ដល់អ្នកក្រោយ ទុកជាក្បួន
គេចូលចិត្ត ឱ្យតែឃើញ មិនគុំកួន
ជួបគាប់ជួន រត់មករក ពិភាក្សា ។

⌑ មកដោយពិត ប្រាប់អ្វីៗ សុទ្ធតែធាតុ
មិនរវាត ឃ្លាតពីធម៌ ក្នុងតម្រា
មិនមានសត្វ មានបុគ្គល មិនមុសា
តាមអក្ខរា សរសេរប្រាប់ ក្នុងបិដក ។

⌑ បើថាសត្វ ថាបុគ្គល ត្រូវ ឬខុស
កូនស្រីប្រុស ចាំឱ្យជាក់ មិនអាក្រក់
សត្វមានមែន ថាយើងគេ ដូចទឹកល្អក់
ប្រៀបដូចសក់ គេសន្មតិ ហៅក្នុងលោក ។

⌑ មកដោយពិត សម្គាល់ធាតុ ដោយសារអ្វី
ពោលពាក្យស្តី ហៅលក្ខណៈ ថាប្រយោគ
ដូចវេទនា សោយអារម្មណ៍ កើតជារោគ
តាមលេខបូក ក្នុងលក្ខណៈ ថាមាន ៤ ។

⌑ មកដោយពិត សម្អាតចិត្ត ឱ្យផូរផង់
ចិត្តទៀងត្រង់ មិនចេះលាក់ រត់គេចពួន
មានរបស់ ប្រាប់ឱ្យគេ ដឹងចំនួន
មិនមានខ្លួន ធ្វើអំពើ ប្រើអំណាច ។

មកដោយពិត ចូលទៅដល់ សច្ចធម៌
អាក្រក់ល្អ សុទ្ធតែទុក្ខ គួរព្រឺខ្លាច
បញ្ចក្ខន្ធ អ្នកដើរតួ ស្លូត ឬកាច
ចិត្តអង់អាច លះកាត់ផ្តាច់ សង្សារវដ្ត ។

មកដោយពិត ចេះអាសូរ ដល់ពួកសត្វ
រស់ស្ងៀមស្ងាត់ ខ្វះអាហារ យ៉ាងកម្សត់
ខំដើររើស ដុំបាយចោល ជ្រុះពីមាត់
ហើយកំណត់ ថាបានមាស ប៉ុនដូងទុំ ។

ពោលថាឃ្លាន គ្មានអ្វីប្រៀប ប្រដូចបាន
ទាំងតិរច្ឆាន ព្រមទាំងមនុស្ស មកជួបជុំ
រកអាហារ ឱ្យតែបាន តាមផ្លូវលំ
អង្គុយសុំ គ្មានខ្មាសអៀន មុខស្រងូត ។

មកដោយពិត គួរចៀសវាង ពីបាបកម្ម
តាមបណ្តាំ ព្រះទ្រង់ញាណ កុំរបូត
ឃ្លាតពីធម៌ រក្សាសីល រៀងរហូត
កុំខំស្រូត ចង់បានពេក យកទៅណា ។

⌑ មកដោយពិត ចេះរកសុខ ដោយខន្តី
ទោះក្រក្តី ស៊ូអត់ទ្រាំ ចិត្តជ្រះថ្លា
សាងកុសល យកកម្លាំង ច្បាំងតណ្ហា
សូមមេត្តា គិតប្រយោជន៍ ដល់ពួកសត្វ ។

សំយោគមតិ

មកដោយពិត ទទួលស្គាល់នូវការអប់រំចម្រើនបញ្ញាដឹងសេចក្តីពិតថា ជាការកម្រមួយយ៉ាងក្រៃលែងក្នុងព្រះពុទ្ធសាសនា ដោយទ្រង់ត្រាស់សម្តែងនូវអ្វីៗដែលមិនធ្លាប់ដឹង ធ្វើឱ្យបានឃើញបានដឹង ដែលអ្វីៗទាំងអស់នោះសុទ្ធតែត្រូវកម្លាំង អវិជ្ជា តណ្ហា ឧបាទាន បិទបាំងគ្របសង្កត់ប្រកាន់ស្អិតងងឹត ជាប់ជិតនៅក្នុងស្រោមរបស់ នីវរណធម៌ ស្ទះរារាំងធ្វើមិនឱ្យឃើញនូវសច្ចធម៌ដែលជាការពិតក្នុងធម្មៈ ជាធម៌ត្រាស់ដឹងដោយព្រះអង្គឯង ពុំមានគ្រូអាចារ្យ ណាប្រៀនប្រដៅឡើយ ។

ព្រះធម៌វិសេសទេសនា បើកបង្ហាញពីការពិតដោយពុទ្ធៈរបស់ធម្មជាតិទាំងឡាយ ធ្វើឱ្យមានបញ្ញាកម្ទេចខ្មាំងសត្រូវពោល គឺកិលេស ឱ្យជ្រុះបន្តិចម្តងៗពីក្នុងចិត្តសន្តានជារឿយៗនេះ បញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានព្រះទ័យទុកដាក់ ដល់សត្វ ដោយមហាករុណាទិគុណ ដែលជាការប្រាប់ផ្លូវសម្រាប់ ឆ្លងចាកលោក ឈានទៅរកការពិតដោយអនុសាសនីក្រៃលែងជាងអ្វីៗក្នុងលោកមិនធ្លាប់មាន ព្រោះអ្វីៗក្នុងលោកមិនមែនជាការពិត ត្រឹមជាសម្មតិសច្ចៈ គ្រាន់តែជាវោហារទេសនា ធ្វើឱ្យសត្វលោកងាយយល់ស្រួលបដិបត្តិ ដើម្បីឃើញសច្ចធម៌ ប៉ុណ្ណោះ ។ ពាក្យណា ដែលព្រះពុទ្ធអង្គទ្រង់លើកយកមកសម្តែង ដូចទ្រង់បញ្ញត្តព្រះវិន័យ ទ្រង់សម្តែងរឿងរបស់បុគ្គលប្បញ្ញត្តិក្នុងព្រះសូត្រនិងបរមត្ថធម៌ក្នុងព្រះអភិធម្ម ក៏សុទ្ធតែជាពាក្យពិត ពាក្យពីរោះ ពាក្យមានប្រយោជន៍ ដោយមានមេត្តា ករុណា អាណិត អាសូរដល់សព្វសត្វ ធ្វើឱ្យសត្វលោកបានសុខសាន្ត ព្រោះសេចក្តីពិត ។ សេចក្តីពិតនេះ សត្វលោកទូទៅខំស្វះស្វែងសិក្សាស្រាវជ្រាវ តាមរូបមន្តលក្ខណៈវិទ្យាសាស្ត្រទំនើបយកមកកសាងសម្ភារៈ ធ្វើសមិទ្ធផលនានាក្នុងស្រុកនិគមទូទៅលើសាកលលោក ក៏ដើម្បីសេចក្តីសុខរួចក៏ប្រកាន់ថា

របស់ទាំងអស់នេះធ្វើឱ្យបានសុខដោយពុំដឹងនូវការពិត សូម្បីជួប នូវសេចក្ដីទុក្ខក៏សម្គាល់ថាជាសុខ ជួបនូវសេចក្ដីសុខបន្តិចបន្តួច ក៏សម្គាល់ថាជាសុខពិតប្រាកដ ទោះបីខ្លួនឯងកំពុងរស់នៅក្នុង សេចក្ដីទុក្ខក៏គ្មានដឹងដែរ ព្រោះពុំបានសិក្សាពីព្រះពុទ្ធវចនៈ ក៏ បែរទៅជាខំប្រព្រឹត្តនូវអ្វី១ផ្សេងប្រាសចាកការពិត ពុំសមហេតុ ផល ក៏ត្រូវឃ្លាងរំលងចោលទទេនូវព្រះធម៌មានតម្លៃក្នុងជីវិត ប្រចាំថ្ងៃ បោះបង់ការពិតនោះចោលទុកឱ្យអកុសលធម៌ ផ្សេង១ មានឱកាសជ្រៀតចូលមកបំពេញជំនួស ។ សេចក្ដីពិត មិនឋិត នៅក្រៅពីព្រះពុទ្ធសាសនា ព្រោះសាសនាដទៃ ឬអ្នកប្រាជ្ញ ក្នុងលោក មិនដែលបង្ហាញប្រាប់ ដល់មនុស្សជាតិនូវការពិត គឺ សច្ចៈទាំង ៤ ឬ សម្ដែងពីសមណៈ ៤ ពួក ឬបង្ហាញឱ្យដឹង នូវបរមត្ថសច្ចៈមាន រូបបរមត្ថ ចិត្តបរមត្ថ ចេតសិកបរមត្ថ និង និព្វានបរមត្ថ ព្រោះគេកំពុងរស់នៅក្នុងស្រោមអវិជ្ជា បានដល់ ពួកកិលេសតណ្ហា ជាប់ក្នុងឧបាទានក្ខន្ធ មានលោភៈ ទោសៈ មោហៈជាដើម ម្ល៉ោះហើយមិនអាចស្វែងរកការពិតដូចព្រះសព្វញ្ញុពុទ្ធ ព្រះអង្គឆ្ងាយចាកសឹកសត្រូវនៃកិលេសតណ្ហាជាមេឃាតករផ្ដាច់ មុខ ធ្វើឱ្យសត្វលោកកើតស្លាប់ជានិច្ចកាល រៀងរហូតរបស់ មច្ចុមារ ។ ការពិតក្នុងធម្មជាតិ ធ្វើឱ្យបញ្ញាភ្លឺស្វាងយ៉ាងត្រចះ

ត្រចង់ ដូចព្រះអាទិត្យរះបំភ្លឺលោកពេលថ្ងៃ និងព្រះច័ន្ទបំភ្លឺពេលយប់ ។ បុគ្គលណាជ្រាបដឹងពីការពិត នឹងទទួលបាននូវរង្វាន់ជាទីគាប់ចិត្ត គឺសេចក្ដីសុខស្ងប់រាល់ពេលរហូតចេញរួចពីលោកដោយពុទ្ធៈ ។

សេចក្ដីពិតនៃជីវិតរបស់សត្វលោកម្នាក់ៗ ក្នុងដំណើរផ្លូវស្វែងរកការស្ងប់ពិត បានដល់សម្មាសម្ពោធិញាណ ជាបញ្ញាចេញរួចពីទុក្ខ ដោយសត្វលោកទាំងអស់កំពុងមានទុក្ខប្រចាំក្នុងខ្លួន ដែលក្នុងព្រះពុទ្ធសាសនា ទ្រង់សម្ដែងតែពីសេចក្ដីទុក្ខនិងការរំលត់ទុក្ខរបស់អរិយសច្ចៈ ទាំង ៤ ជាសង្ខារធម៌តាក់តែងពីហេតុប្បច្ច័យរបស់សភាវធម៌ ។

អ្វីទៅហៅថាជីវិតពិត ?

ជីវិតពិត នៅត្រង់ការឃើញការដឹងនូវរបស់ពិត ក្នុងជីវិតប្រចាំថ្ងៃតាមរយៈរូប សំឡេង ក្លិន រស ផ្សោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលមិនមានការច្រេសប្រហែសឡើយ ព្រោះបើមិន ដូច្នោះ ទិដ្ឋិទាំងឡាយនឹងចាប់យកមកធ្វើជាចំណើរបស់ខ្លួន ដែលឃ្លាតឆ្ងាយពីសេចក្ដីពិតនាំឱ្យសង្សារវដ្ដ ឬខ្លួនប្រាណនៃយើងម្នាក់ៗ ចេះតែអន្ទោលទៅវែងឆ្ងាយ មិនដឹងនឹងត្រូវផុតត្រឹមណា ។

ការពិតនៃជីវិត សំដៅទៅលើការឃើញត្រូវត្រង់ តាមផ្លូវអរិយមគ្គអង្គ ៨ មាន សតិប្បដ្ឋាន ៤ ជាប្រធានក្នុងការរលឹកព្រមជាមួយសម្មាទិដ្ឋិនិងយោនិសោមនសិការ ជាពន្លឺបំភ្លឺ ផ្លូវឆ្ពោះទៅរកទិសដៅ គឺ ត្រើយ នាយ ។ កាលបើអ្នកទាំងឡាយខ្វះការឃើញនូវសេចក្ដីពិត អ្នកទាំងឡាយនឹងវង្វេងវិលវល់ ត្រឡប់ចុះត្រឡប់ឡើង ក្នុងបវត្តិកាល គិតតែពីនាំគ្នាសន្សំនូវរបស់ឥតខ្លឹមសារ ប្រកួតប្រជែងគ្នា កសាងសម្ភារប្រើប្រាស់យ៉ាងទំនើប១ ដែលធ្វើឱ្យជីវិតប្រាសចាកការពិត គិតតែពីលោភលន់ចង់បានមិនចេះឆ្អែតឆ្អន់ ដណ្ដើមគ្នារស់ ដោយប្រើមធ្យោបាយផ្សេង១រៀងខ្លួន គឺ សិក្សារៀនសូត្រមុខវិជ្ជាផ្លូវលោក តម្រង់មុខព្រួញធ្វើឱ្យជីវិតទាញទៅរកគ្រោះមហន្តរាយដល់អាយុជីវិតសព្វសត្វ ដោយកម្លាំងបបញ្ចធមិ ជំរុញអូសទាញចិត្តសន្ដានដែលហៅថាការចម្រើនខាងផ្នែកវិទ្យាសាស្ត្រទំនើប ។

ការឃើញពិតក្នុងជីវិត មិនមែនហាមឃាត់រារាំងដល់មនុស្សលោកថា មិនឱ្យស្វែងរកនូវរបស់ប្រើប្រាស់សម្រាប់បច្ច័យ ៤ នោះទេ គ្រាន់តែព្រះដ៏មានព្រះភាគទ្រង់ទូន្មានថា ត្រូវ **សន្ដោស** កុំចេះតែចង់បានតាមចិត្តប្រាថ្នា (តណ្ហា) ដែលនាំឱ្យដើរខុសផ្លូវល្អ ហាក់ដូចជាហុចដៃឱ្យខ្លាំងទិដ្ឋិចាប់យក ។

ព្រះសម្មាសម្ពុទ្ធទ្រង់គិតពី ប្រយោជន៍របស់សត្វខ្លាំងណាស់ ព្រះអង្គទ្រង់សំដែងប្រាប់នូវ ប្រយោជន៍ទាំង ៣ មាន ទិដ្ឋធម្មិកត្ថប្រយោជន៍ ហៅថា ប្រយោជន៍ ក្នុងបច្ចុប្បន្នឱ្យខំស្វែងរក ទ្រព្យសម្បត្តិយកមកផ្គត់ផ្គង់ចិញ្ចឹមជីវិត និងគ្រួសារ ព្រមទាំង សមណព្រាហ្មណ៍ជាដើម ។ សេចក្តីនេះ ចង់បង្ហាញប្រាប់ឱ្យបានជ្រាបថា ទ្រព្យសម្បត្តិ គឺ បច្ច័យ ៤ ដែលយើងរវល់ខ្វល់ខ្វាយ រកពេលទំនេរសម្រាកគ្មាន មិនមែនជាធម៌សម្រាប់នាំមកនូវសុខសន្តិភាពទេ ព្រោះជា បដិច្ចសមុប្បាទរបស់ទុក្ខសច្ចៈ ទោះបីបាន អ្វីៗ ល្អប្រណីត ឬរបស់មានតម្លៃយ៉ាងណាក៏ **មិនគួរត្រេកអរសោះ** ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងជាគាថាធម្មបទទុក ។

រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ

រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ។

ប្រែថា : សេចក្តីសោកកើតពីសេចក្តីត្រេកអររីករាយ ភ័យកើតពីសេចក្តីត្រេកត្រអាល កាលបើមិនមានសេចក្តីត្រេកអរទេ សេចក្តីសោក និងភ័យ ក៏នឹងមានមកពីណា ។

ទ្រព្យសម្បត្តិទាំងឡាយកើតចេញពីអារម្មណ៍ តាមទ្វារ ៦ ជា **ទុក្ខសច្ចៈ** ការរីករាយចង់បាន និងការត្រេកអរពេញចិត្តក្នុងការប្រើប្រាស់នូវរបស់ទាំងនោះ ជា **សមុទយទុក្ខ** ឯសេចក្តីមិនត្រេកត្រអាលក្នុងការប្រើប្រាស់ចាយវាយនូវសម្បត្តិទាំងឡាយទាំងពួងជា **និរោធសច្ចៈ** ផ្លូវទៅកាន់ទីរំលត់ទុក្ខដោយសតិប្បដ្ឋាន ៤ បានដល់ **អរិយមគ្គអង្គ ៨** មានសម្មាទិដ្ឋិកម្ចាត់ សេចក្តីប្រកាន់ គឺ សក្កាយទិដ្ឋិ ។

សេចក្តីត្រូវការប្រាថ្នានូវរបស់អ្វីៗ បន្តិចបន្តួច សូម្បីប្រាក់មួយកាក់មួយសេន ឬបាយមួយស្លាបព្រា ក៏ជាសមុទយទុក្ខ ព្រោះមានវត្ថុនោះជាអារម្មណ៍ និងជាផលកើតឡើងពីហេតុប្បច្ច័យនៅក្នុងសង្ខតធាតុ ។ បុថុជ្ជនអ្នកមានកិលេសមិនងាយនឹង បានជួបនូវសេចក្តីសុខ ព្រោះតាំងពីកើតមក នាំយកទុក្ខមក ជាមួយដែលជាទុក្ខសច្ចៈ ។ ដោយសារទុក្ខសច្ចៈនេះបណ្តាលឱ្យមាន ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោក ដើម្បីជួយរំដោះ សេចក្តីទុក្ខរបស់សត្វឱ្យមានឥស្សរភាពលើលោក ព្រោះបានចាក់ធ្លុះ ឃើញនូវ អរិយសច្ចធម៌ទាំង ៤ ដែលជាការពិតរបស់ជីវិត ។ យើងត្រូវដឹងត្រូវស្គាល់ឱ្យបានជាក់ច្បាស់សម្រាប់ធ្វើជាស្ពាន ឆ្លងនូវ អន្លង់កាម អន្លង់ភព អន្លង់ទិដ្ឋិ

និងអន្លង់អវិជ្ជា មានតណ្ហា ជាខ្សែចងរូបរឹតចិត្តដល់សត្វលោក តាមបណ្តោយសមុទ្ទតណ្ហា មិនដឹងខាងដើមពីត្រឹមណារបស់ខ្សែជីវិតគ្រប់ៗគ្នា ។

ការដឹងពិត គឺការបានយល់ជាក់ច្បាស់ដោយបញ្ញាថា សេចក្តីពិតនៃទុក្ខកើតពីតណ្ហាពុំមានសត្វបុគ្គល អ្នកប្រព្រឹត្តអ្វីៗ មានត្រឹមតែសង្ខារធម៌កើតឡើងពីហេតុប្បច្ច័យ ហើយត្រូវរលត់ទៅវិញជាធម្មតា ។

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ប្រែថា : កាលណាបុគ្គលយល់ឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះក្នុងកាលណោះ រមែងនឿយណាយនូវសេចក្តីទុក្ខ នេះជាផ្លូវ នៃសេចក្តីបរិសុទ្ធចិត្ត ។

សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ប្រែថា : កាលណាបុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមកនូវសេចក្តីទុក្ខដូច្នេះ ក្នុងកាលណោះរមែងនឿយណា នូវសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធចិត្ត ។

សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ប្រែថា : កាលណាបុគ្គលឃើញដោយប្រាជ្ញាថា ធម៌ទាំងឡាយ មិនមែនជារបស់ខ្លួន ដូច្នេះក្នុងកាលនោះ រមែងនឿយណាយ នូវសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធចិត្ត ។

ការដឹងពិត គឺដឹងទៅលើសភាវធម៌កើតឡើងហើយមិនទៀង របស់ខន្ធ អាយតនៈ ធាតុដែលព្រះពុទ្ធអង្គបានត្រាស់ដឹងដោយព្រះប្រាជ្ញាញាណ ឃើញសុទ្ធតែធាតុរួចទ្រង់ ព្រះបរិវិតក្កៈចំពោះសត្វលោកដែលកំពុងហែលលេងសប្បាយតាមបណ្តោយសមុទ្ទសង្សារទុក្ខ (តណ្ហា) បន្ទាប់មកទ្រង់មានការខ្វល់ខ្វាយតិចដែលមានព្រហ្មយាងចុះមកអារាធនា ដូចបានជំម្រាបជូនពីខាងដើម នេះជាធម្មនិយាម ។

ការដឹងពិត ដោយប្រាជ្ញាញាណ ដើម្បីកម្ចាត់កិលេសចេញពីខន្ធសន្តាន ដែលមានពួកកិលេសយ៉ាងល្អិតដេកត្រាំនៅក្នុងចិត្ត ហើយក៏គ្មានមធ្យោបាយណា ធ្វើឱ្យជ្រុះជ្រះស្អាតដូចសំពត់សក្រៅពីការបដិបត្តិត្រឹមត្រូវតាមព្រះបិតាវិវដ្តៈ គ្របសង្កត់លើភពផែនដី ព្រមទាំងទេវលោក សុទ្ធតែជាអ្នកល្ងិតល្ងង់ដោយអវិជ្ជាគ្របសង្កត់ ចូលចិត្តសន្សំទុកដាក់ តែពីសេចក្តីត្រេកអរ

រីករាយនូវ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ពុំមានសារៈ ដែលសុទ្ធតែជាទុក្ខសច្ចៈគ្របដណ្ដប់ពេញលោក ធ្វើឱ្យសាកលលោកឈ្លោះគ្នាព្រោះយល់ថាមានខ្លួនជាអ្នកធ្វើកម្ម ក៏ត្រូវជាប់ជំពាក់លោក មានការចេះដឹងត្រឹមតែសេចក្ដីប្រកាន់ហួងហែងថា អ្វីៗសុទ្ធតែជារបស់ខ្លួន ។

ការដឹងពិតនេះ ធ្វើឱ្យជីវិតបានសុខស្ងប់លែងកង្វល់ចង់ទាមទារអ្វីៗទាំងពួង គិតត្រឹមតែធ្វើយ៉ាងណាឱ្យតែបានរស់មួយគ្រាសិន ដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ មានសីល សមាធិ បញ្ញាក្នុងជីវិតប្រចាំថ្ងៃប៉ុណ្ណោះ ។

ការដឹងពិត ធ្វើឱ្យមនុស្សមានស្មារតីឆ្លាតវាងវៃ មានចិត្តល្អផូរផង់ជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា មិនជ្រះថ្លាក្នុងទក្ខិណេយ្យបុគ្គលដទៃក្រៅព្រះពុទ្ធសាសនា មានសទ្ធា **ជឿកម្ម ជឿវិបាក** ទាំង **ជឿកម្មស្សកតា** និង **តថាគតពោធិសទ្ធា** ប្រកបដោយមេត្តាករុណា អាណិតអាសូរដល់សត្វទូទៅ ជាអ្នកមានសីល វៀរចាក **បាណាតិបាត** ជាដើម ។ ជាបន្តទៅទៀតសូមលើកយក រឿងព្រះជាតកមួយរបស់វដ្តកបោតកចរិយាទី ៩ មកសម្ដែងជូនជ្រាបដែលមាននៅក្នុងខុទ្ទកនិកាយចរិយាបិដកភាគ ៧៧/២៩៧ ។

កាលដែលតថាគតកើតជាកូនសត្វក្រួច ក្នុងអរញ្ញប្រទេសមួយ ទៀបដែនមគធៈ ជាសត្វតូចដូចជាដុំសាច់មិនទាន់ដុះស្លាបនៅក្នុងសំបុក ។ កាលនោះមាតា (របស់តថាគត) នាំយកចំណីដោយចំពុះមកចិញ្ចឹមតថាគត ពេលនោះតថាគតរស់នៅ ដោយសារសម្ផស្សរបស់មាតា ដែលតថាគតមិនទាន់មានកម្លាំងកាយនៅឡើយ ។

វេលានោះមានភ្លើងឆេះព្រៃក្នុងគិម្ហសម័យរាល់ៗឆ្នាំ ដែលមានអណ្ដាតឆាបឆេះរាលចូលមកជិតលំនៅនៃតថាគត។ អណ្ដាតភ្លើងដ៏ធំ កាលធ្វើសំឡេងជាផ្ទុំផ្ទុំយ៉ាងនេះ ភ្លើងនោះឆេះរាលចូលមករកតថាគតជាលំដាប់ ។ មាតាបិតាតថាគត ភ័យតក់ស្លុតព្រោះខ្លាចសន្ទុះភ្លើង ក៏លះបង់ចោលតថាគតក្នុងសំបុកហើយដោះខ្លួនចេញទៅ ។ តថាគត លះបង់នូវជើងនឹងស្លាបតថាគត មិនមានកម្លាំងកាយ តថាគត ជាសត្វមិនមានដំណើរទៅក្នុងទីនោះ កាលណោះក៏ គិតយ៉ាងនេះថា អញភ័យតក់ស្លុតញាប់ញ័រស្ទុះទៅរកមាតាបិតាណា បើមាតាបិតាទាំងនោះ លះបង់អញចេញទៅហើយ តើក្នុងថ្ងៃនេះ អញត្រូវធ្វើដូចម្ដេច ។ ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយ សីលគុណ **សច្ចៈ សោចេយ្យៈ**

(សេចក្ដីស្អាត) និងសេចក្ដីអាណិតសិងមានក្នុងលោក (បើដូច្នោះ) អញនឹងធ្វើនូវ **សច្ចកិរិយា** ដ៏ឧត្ដមដោយសច្ចៈនោះ ។

តថាគតពិចារណាកម្លាំងធម៌ ហើយរលឹកដល់ព្រះជិនស្រីក្នុងកាលមុន ធ្វើ **សច្ចកិរិយា** ព្រោះអាស្រ័យកម្លាំងសច្ចធម៌ (នោះ) ថា ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនរួច ជើងទាំងឡាយរបស់ខ្ញុំមាន តែដើរមិនបាន មាតាបិតារបស់ខ្ញុំហើរចេញទៅបាត់ហើយ ម្នាលភ្លើងព្រៃ អ្នកចូរចៀសចេញទៅ ។ ព្រោះសច្ចកិរិយាដែលតថាគត បានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីសៈ (ហើយរលត់ក្នុងទីនោះ) ដូចជាគប់ភ្លើងដែលបុគ្គលជ្រលក់ទៅក្នុងទឹក កុសលធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគតពុំមានឡើយ នេះជា **សច្ចបារមី** របស់តថាគត ។

បទពិចារណា

មកដោយពិត ជាឧទានមួយរបស់ព្រះដ៏មានព្រះភាគនូវព្រះគាថា **សច្ចៈ ខន្តី ភតញ្ញូ** ជាត្រៃកូដធម៌ និងជាតបធម៌ដ៏ឧត្ដម សម្រាប់លាងជម្រះនៅគ្រឿងសៅហ្មងចិត្តធ្វើឱ្យបាន សម្រេចដល់ព្រះនិព្វានពិតប្រាកដ ដូច្នោះសត្វលោក

គួររួតរះ រហ័សកុំដំអក់នៅក្នុងអំពើបាបយូរពេក ត្រូវប្រញាប់ក្រោកឡើង បដិបត្តិតាមធម៌ ៣ ប្រការនេះ ទាន់ព្រះពុទ្ធសាសនានៅមាន ។ បុគ្គលណាគោរពមាតាបិតា មានសេចក្តីព្យាយាម សាងសន្សំបុណ្យ គឺកុសលធម៌ឱ្យបានច្រើន បុណ្យនឹងតាមជួយអ្នកវិញដូច ស្រមោលអន្ទោលតាមប្រាណយ៉ាងណាការពិត គឺ សច្ចធម៌ ក៏មានកម្លាំង អំណាចខ្លាំងក្លាជាទីបំផុតអាចរារាំងទប់ស្កាត់នូវ អ្វីៗ គ្រប់យ៉ាង ដែលប៉ុនប៉ងមកព្យាបាទដើម្បីធ្វើឱ្យវិនាសដោយ ប្រការណានីមួយ ដូចយ៉ាងកូនសត្វក្រួចព្រះពោធិសត្វនេះឯង ។

ពាក្យថា : **សច្ចធម៌ដោយពាក្យពិតនេះ ជាតួព្រះពុទ្ធសាសនាទាំងមូល** ព្រោះព្រះគាថាណាក៏ដោយឱ្យតែព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង សុទ្ធតែជាពាក្យពិតទាំងអស់ ទោះបីកុសល អកុសល អព្យាកតៈ ដែលជាធម៌មានក្នុងជីវិតរាល់ថ្ងៃ ជាធម្មជាតិ ហៅថា ធម្មោ របស់ព្រះសទ្ធម្ម គឺ មគ្គ៤ ផល៤ និព្វាន ដែលព្រះអង្គបានចាក់ធ្លុះឃើញធម្មជាតិនេះហើយ ទ្រង់ប្រកាសនូវបឋមទេសនានាព្រៃឥសិបតនមិគទាយវ័ន ប្រោសបញ្ចវគ្គិយ នៅថ្ងៃ ១៥ កើត ខែ អាសាឍ ធ្វើឱ្យមានព្រះសង្ឃសាវ័ក ជាថ្ងៃដែលព្រះសម្មាសម្ពុទ្ធយាងចុះចាប់បដិសន្ធិ ក្នុងផ្ទៃនៃព្រះវរ

មាតាពីឋានតុសិត ជាថ្ងៃដែលព្រះអង្គទ្រង់យាងចេញសាងព្រះផ្នួស ជាថ្ងៃដែលព្រះអង្គទ្រង់សម្តែងយមកប្បាដិហារ្យ ទាំង ៥ ចំណុចនេះ ហៅថា ថ្ងៃដែលព្រះអង្គទ្រង់ស្ថាបនាត្រ័ះ ពុទ្ធចក្រ **ធ្វើឱ្យមានសុខសន្តិភាពលើមនុស្សជាតិក្នុងសាកលលោក ព្រម ទាំងទេវលោក** ដែលកំពុងមានទុក្ខបៀតបៀនរាល់ថ្ងៃ ។ ការដោះស្រាយបញ្ហាចង្អៀតចង្អល់របស់លោក គួរនាំគ្នារត់រកទីពឹងដល់ព្រះត្រៃសរណគមន៍ គឺ យកធម៌មកជួយដោះស្រាយ កុំយកអំណាចមានះមកធ្វើការកៀបសង្កត់ឈ្លានពានលួចបន្លំ សូម្បីបន្តិចបន្តួចក៏មិនរួចពីសេចក្តីវិនាសខ្លួនឯកវិញដែរ ព្រោះបានសន្សំពូជអាក្រក់ ចោកទាបទុកក្នុងខ្លួនរួចហើយ ។ **ការដោះស្រាយដោយសន្តិវិធី គ្មានអ្វីក្រៅពីចូលដល់ការពិត ក្នុងធម្មជាតិរបស់អ្នកត្រាស់ដឹង** មានទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និងមគ្គសច្ចៈ ដែលជាវិធីល្អប្រសើរបំផុតសម្រាប់មហាជន លើសាកលលោកក្នុងបច្ចុប្បន្នកាល និងក្នុងអនាគតកាល ទើបគេចចៀសវាងផុតពីគ្រោះថ្នាក់ផ្សេងៗ ដូចរឿងព្រះជាតកខាងលើនេះស្រាប់ ។

សូមមនុស្ស ទេវតា មារព្រហ្ម យកធម៌ជាទីពឹងធ្វើជាមរតក កុំយកអាមីសជាមរតក កាលបើអ្នកទាំងឡាយយក

ធម៌ជាទីពឹង យកធម៌ ជាមរតក ព្រះតថាគតទ្រង់សរសើរជាងអ្វីទាំងអស់ **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** ប្រែថា កាលបើអ្នកស្រឡាញ់ធម៌ ព្រះធម៌នឹងជួយថែរក្សាអ្នកវិញ ជាក់ជាមិនខាន ។ នេះជាពាក្យពិតក្នុងសច្ចទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រោះព្រះអង្គយាងមកដូចយ៉ាងនោះគឺ នាំយកចំណែកធម៌មកសំដែងដល់សត្វលោក ព្រះអង្គទៅដូចយ៉ាងនោះគឺ ទ្រង់ប្រកាសនូវ សច្ចធម៌ព្រមទាំងចរិយា សុទ្ធតែជាការពិត ទុកឱ្យសត្វបដិបត្តិ ព្រោះព្រះអង្គប្រសូតចេញពីត្រកូលពូជពង្សវង្សព្រះអាទិត្យ ឬអទិច្ចពន្ធុ ជាគោតមគោត្តប្រព្រឹត្តអ្វីៗ ត្រឹមត្រូវតាមសេចក្តីពិតទាំងអស់ ។

ក្នុងសម័យបច្ចុប្បន្ន ជាកាលដែលត្រូវច្របូកច្របល់ វឹកវរប្រទូសរ៉ាយគ្នាទូទាំងសាកលលោក ប៉ុន្តែដោយអានុភាពនៃ **ព្រះពុទ្ធសាសនា** អាចនៅមានធម៌ខ្លះៗ ឋិតនៅក្នុងខ្លួនរបស់ពួកសត្តនិករ ដែលកូននៅមានការគោរពមាតាបិតាខ្លះៗ មានការគោរពគ្នា រវាងស្វាមីភរិយាខ្លះៗ ញាតិមិត្តខ្លះៗ ឬថាចេះជួយអនុគ្រោះគ្នាខ្លះៗ ដោយទឹកចិត្តមេត្តា ករុណាដែលខ្ញុំបានសរសេរចងក្រង ក្នុងសៀវភៅមួយមានចំណងជើងថាៈ **ពុទ្ធព្យាករណ៍** រួចមកហើយ លុះបន្តទៅខាងមុខ ធម៌ទាំងអស់ ត្រូវវិនាសសាប

សូន្យបន្តិចម្តងៗ ព្រោះអស់ឥទ្ធិពលព្រះពុទ្ធសាសនា ។ ចំពោះសម័យមុនៗ ព្រះសម្មាសម្ពុទ្ធមានព្រះជន្មាយុរាប់ម៉ឺនឆ្នាំ តែដោយឡែក ព្រះសមណគោតមក្នុងភទ្ទកប្បនេះ ព្រោះបារមីនៃគតិមិនទាន់គ្រប់គ្រាន់ ចំណែកមនុស្សអាយុក្រោម ១០០ ឆ្នាំ របស់អន្តរកប្ប ពុំមាន ព្រះសម្មាសម្ពុទ្ធត្រាស់ ដឹងឡើយ ។

អំពីលក្ខណានិចត្ថ្កៈ

មកដោយពិត ចាប់ច្បូតច្របាច់ដល់ឫសគល់នៃធម្មជាតិទាំងឡាយ **និស្សត្តោ** មិនមែនសត្វ **និជ្ជីវោ** មិនមែនព្រលឹងអត្តាតួខ្លួន **សុញ្ញោ** សូន្យចាកអត្តាតួខ្លួនឱ្យឃើញត្រឹមតែធាតុដែលពុំមានអ្វីមកកំណត់សម្គាល់ដឹងបាន ព្រោះហេតុនេះទើបព្រះដ៏មានព្រះភាគទ្រង់សម្តែង ពីវិសេសលក្ខណៈរបស់សភាវធមិ នីមួយៗ ទុកជាការសិក្សាពីបរមត្ថឱ្យបានងាយយល់សម្រាប់ការ បដិបត្តិរួចផុតចាកទុក្ខ ។

បរមត្ថធមិមានលក្ខណៈ ២ ប្រការ ហៅឈ្មោះតាមភាសាបាលីថា សាមញ្ញលក្ខណៈ ឬត្រៃលក្ខណ៍ ១ និងវិសេសលក្ខណៈ ១ ។

១- **សាមញ្ញលក្ខណៈ** ជាលក្ខណៈសាមញ្ញទូទៅ តាមធម្មតា តាមធម្មជាតិ តាមប្រក្រតី ដែលបរមត្ថធម៌ទាំងឡាយ (វៀរនិព្វាន) និងត្រូវមានដូចៗគ្នា ៣ ប្រការ គឺអនិច្ចំ ទុក្ខំ និងអនត្តា ។

- **អនិច្ចំ** មានលក្ខណៈមិនទៀង មិនឋិតថេរនៅយឺនយូរបាន គ្រប់កាល មានការកើតឡើងហើយ ក៏ប្រែប្រួលរលត់អស់ទៅវិញ ជារបស់បណ្ដោះអាសន្នផ្ទុយគ្នា និងសេចក្ដីទៀង ។

- **ទុក្ខំ** មានលក្ខណៈទ្រាំនៅមិនបាន ចាំបាច់ត្រូវតែវិនាសបែកធ្លាយសាបសូន្យទៅវិញ ដោយមានការបៀតបៀន អត់ទ្រាំបានដោយលំបាក ជាទីតាំងនៃសេចក្ដីទុក្ខផ្ទុយពីសេចក្ដីសុខ ។

- **អនត្តា** មានលក្ខណៈសូន្យចាកតួខ្លួន មិនអាចបង្គាប់បញ្ជា និងឱ្យប្រព្រឹត្តទៅតាមចិត្តប្រាថ្នា ជារបស់សូន្យ (ទទេ) មិនមានម្ចាស់ មិនឋិតថេរនៅក្នុងអំណាចនៃខ្លួនផ្ទុយពី អត្តា ។

២- **វិសេសលក្ខណៈ** ជាលក្ខណៈពិសេសប្រចាំតួខ្លួន និងពិសេសចំពោះបរមត្ថធម៌នីមួយៗ ខុសផ្សេងពីគ្នា ។ វិសេសលក្ខណៈនេះមាន ៤ ប្រការ គឺ លក្ខណៈ ១ រសៈ ១ បច្ចុប្បដ្ឋាន ១ បទដ្ឋាន ១ ។

- **លក្ខណៈ** គឺគុណភាព ឬគ្រឿងសម្គាល់ ឬសភាពដោយចំពោះ ដែលមានប្រចាំសម្រាប់សភាវៈនីមួយៗ

- **រស** : គឺមុខនាទី ឬកិច្ចការងារ តាមលក្ខណៈភារកិច្ចរៀងខ្លួន

- **បច្ចុប្បដ្ឋានៈ** ផលរបស់រសៈ ឬអាការប្រាកដ កើតអំពីធម៌នោះ ដែលបានធ្វើកិច្ចការងារតាមមុខនាទីរបស់ខ្លួន

- **បទដ្ឋាន** គឺហេតុជិត ដែលធ្វើឱ្យធម៌កើតឡើងជាបន្ទាន់ ។

ចិត្ត ចេតសិក រូប មានវិសេសលក្ខណៈ ឬលក្ខណាទិចតុក្កៈគ្រប់បរិបូរណ៍ទាំង ៤ ប្រការ ចំណែកព្រះនិព្វានមានវិសេសលក្ខណៈត្រឹមតែ ៣ ប្រការ គឺ លក្ខណៈ រស និងបច្ចុប្បដ្ឋាន មិនមានបទដ្ឋានជាហេតុជិតនាំឱ្យកើតសង្ខារធម៌ ព្រោះព្រះនិព្វានជាអសង្ខតធាតុ ពុំមានហេតុ មិនមានបច្ច័យមកប្រជុំតាក់តែងឱ្យកើតទៀត ។

ជាបន្តទៅ និងសិក្សាពីលក្ខណាទិចតុក្កៈរបស់សភាវធម៌ខ្លះទៀត ដើម្បីឱ្យបានយល់ច្បាស់នូវ លក្ខណៈ កិច្ច ផល បទដ្ឋានងាយស្រួលក្នុងការសិក្សាអប់រំចិត្ត ។

⌑ លក្ខណាទិចតុក្កៈ របស់ សទ្ធាចេតសិក

១- **សទ្ទហនលក្ខណា** : មានការជឿដល់អារម្មណ៍ ជាលក្ខណៈ

២- **បសាទន រសា** : មានសេចក្ដីជ្រះថ្លា ជាកិច្ច

៣- **អកាឡុស្សិយបច្ចុប្បដ្ឋានា:** មានការមិនល្អក់ស្អាប់ ជាផល

៤- **សទ្ធេយ្យវត្ថុបទដ្ឋានា** : មានវត្ថុជាទីតាំងនៃការជឿ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ហិរិចេតសិក

១- **បាបតោជិគុច្ឆនលក្ខណា** : មានការស្អប់ខ្ពើមអំពើបាប ជាលក្ខណៈ

២- **បាបានំ អករណរសា** : មានការមិនធ្វើនូវអំពើបាបជាកិច្ច

៣- **បាបតោ សង្កោចន បច្ចុប្បដ្ឋានា** : មានការខ្មាសដល់អំពើបាប ជាផល

៤- **អត្តគារវបទដ្ឋានា** : មានការគោរពខ្លួនឯង ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ អកុសលចិត្ត

១- **សាវជ្ជវិបាកលក្ខណំ** : ជាធមិមានទោស ឱ្យផលជាសេចក្ដីទុក្ខ ជាលក្ខណៈ

២- **កុសលបដិបក្ខរសំ** : មានការបដិបក្សដល់កុសលធមិជាកិច្ច

៣- **កាឡុសិយបច្ចុប្បដ្ឋានំ** : មានការល្អក់ខ្វល់ ជាផល

៤- **អយោនិសោមនសិការបទដ្ឋានំ** :មានការមិនយកចិត្តទុកដាក់ល្អដល់អារម្មណ៍ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ហសិតុប្បាទចិត្ត

១- **សព្វារម្មណវិជាននលក្ខណា :** មានការដឹងអារម្មណ៍ទាំង ៦ ជាលក្ខណៈ

២- **អរហតំ អនុឡោរេសុ វត្ថុសុ រសា :** ព្រះអរហន្តទាំងឡាយញញឹមក្នុងពួកវត្ថុល្អរកមិនមាន ជាកិច្ច

៣- **តថាភាវបច្ចុប្បដ្ឋានា :** មានការប្រព្រឹត្តិទៅក្នុង
អារម្មណ៍ ៦ ដោយអាការម្យ៉ាងជាមួយគ្នា ជាផល

៤- **ឯកន្តតោ ហទយវត្ថុ បទដ្ឋានា :** មានហទយវត្ថុយ៉ាងពិត ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ឱត្តប្បចេតសិក

១- **ឧត្តាសនលក្ខណំ :** មានការភ័យខ្លាចបាប ជាលក្ខណៈ

២- **បាបានំ អករណរសំ :** មានការមិនធ្វើអំពើបាប ជាកិច្ច

៣- **បាបតោ សង្កោចន បច្ចុប្បដ្ឋានំ :** មានការខ្មាសអៀនចំពោះអំពើបាប ជាផល

៤- **បរគារវបទដ្ឋានំ :** មានការគោរពអ្នកដទៃ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អលោភចេតសិក

១- **អលគ្គភាវលក្ខណោ** : មានការមិនជាប់ជំពាក់ចិត្ត នៅក្នុងអារម្មណ៍ ជាលក្ខណៈ

២- **អបរិគ្គហរសោ** : មានការមិនហួងហែង ជាកិច្ច

៣- **អនល្លីនភាវបច្ចុប្បដ្ឋានោ** : មានការមិនប្រកាន់ ជាផល

៤- **យោនិសោមនសិការបទដ្ឋានោ** : មានការយចិត្តទុកដាក់ត្រូវទំនងចំពោះអារម្មណ៍ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អទោសចេតសិក

១- **អចណ្ឌិកលក្ខណោ** : មានការមិនកាចសាហាវ ជាលក្ខណៈ

២- **អាឃាតវិនយរសោ** : មានការបំផ្លាញឬកម្ចាត់នូវការគំនុំគុំកួន ជាកិច្ច

៣- **សោមភាវបច្ចុប្បដ្ឋានោ** : មានសភាពជាម្លប់ត្រជាក់ ជាផល

៤- **យោនិសោមនសិការបទដ្ឋានោ** : មានការយកចិត្តទុកដាក់ត្រូវទំនងចំពោះអារម្មណ៍ ជាបទដ្ឋាន ។

⌑ លក្ខណាទិចតុក្កៈ របស់ បញ្ញាចេតសិក (ទី២)

១- **យថាភូតប្បដិវេធលក្ខណា:** មានការដឹងពិត ចាក់ធ្លុះក្នុងសភាវធម៌តាមសេចក្ដីពិត ឬមានការចាក់ធ្លុះនូវធម៌ទាំងឡាយ ដែលកើតឡើង ជាលក្ខណៈ

២- **វិសយោភាសនរសា :** មានការបំភ្លឺនូវអារម្មណ៍យ៉ាងជាក់ស្តែង ជាកិច្ច ឬ **មោហន្ធការវិទ្ធំសនរសោ:** មានការកម្ចាត់បង់នូវភាពងងឹត ជាកិច្ច

៣- **អសម្មោហបច្ចុប្បដ្ឋានា :** មានការមិនវង្វេងក្នុងអារម្មណ៍ ជាអាការប្រាកដ

៤- **យោនិសោមនសិការបទដ្ឋានា :** មានការយកចិត្តទុកដាក់ត្រូវទំនងក្នុងអារម្មណ៍ ជាបទដ្ឋាន

⌑ លក្ខណាទិចតុក្កៈ របស់ បថវី

១- **កក្ខឡលក្ខណា :** មានការរឹង ជាលក្ខណៈ

ឬ **អថទ្ធ លក្ខណា :** មានការទន់ ជាលក្ខណៈ

២- **បតិដ្ឋានរសា :** មានការទ្រទ្រង់នៅ ជាកិច្ច

៣- **សម្បដិច្ឆន្នបច្ចុប្បដ្ឋានា :** មានការទទួលទុក ជាផល

៤- **អវសេសធាតុត្តយបទដ្ឋានា :** មានធាតុទាំង៣ដែលនៅសល់ (គឺ អាបោ តេជោ វាយោ) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អាបោ

១- **អាពន្ធនលក្ខណោ :** មានការតោងក្តោបទុក

សហជាតរូប ជាលក្ខណៈ

ឬ **បគ្ឃរណលក្ខណោ** : មានការហូរជ្រាបជាលក្ខណៈ

២- **ព្យូហនរសោ :** មានការរីកចម្រើនលូតលាស់ ជាកិច្ច

៣- **សង្គហបច្ចុប្បដ្ឋានោ :** មានការរួបរួម ជាផល

៤- **អវសេស ធាតុត្តយបទដ្ឋានោ :** មានធាតុទាំង៣ដែលនៅ

សល់ (គឺ បឋវី តេជោ វាយោ) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ តេជោ

១- **ឧណ្ហត្តលក្ខណោ :** មានការក្តៅ ជាលក្ខណៈ

២- **បរិបាចនរសោ :** មានការដុតកម្តៅ ជាកិច្ច

៣- **មទ្ទវានុប្បាទនបច្ចុប្បដ្ឋានោ :** មានការជួយធ្វើបន្ថែម

ឱ្យទន់ ជាផល

៤- **អវសេសធាតុត្តយបទដ្ឋានោ:** មានធាតុទាំង៣ដែលនៅ

សល់ (គឺ បឋវី តេជោ វាយោ) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ វាយោ

១- **វិត្ថម្ភនលក្ខណោ:** មានសភាពតឹងកម្រើក ជាលក្ខណៈ

២- **សមុទីរណរសោ** : មានការញ៉ែរ ជាកិច្ច

៣- **អភីនិហារបច្ចុប្បដ្ឋានោ** : មានការបង្អោនទៅជាផល

៤- **អវសេសធាតុត្តយបទដ្ឋានោ** : មានធាតុទាំង៣ ដែលនៅសល់ (គឺ បឋវី អាបោ តេជោ) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ចក្ខុប្បសាទរូប

១- **រូបាភិឃាតារហភូតប្បសាទលក្ខណំ :** មានសភាពថ្លានៃមហាភូតរូបដែលគួរដល់ការប៉ះខ្ទប់នូវរូបារម្មណ៍ ជាលក្ខណៈ

២- **រូបេសុ អាវិញ្ឆនរសំ:** មានការទាញយកនូវរូបារម្មណ៍ ជាកិច្ច

៣- **ចក្ខុវិញ្ញាណស្ស អធារភាវបច្ចុប្បដ្ឋានំ :** មានការទ្រទ្រង់ទុកនូវចក្ខុវិញ្ញាណ ជាផល

៤- **ទិដ្ឋុកាមតានិទានកម្មជភូតបទដ្ឋានំ :** មានមហាភូតរូបដែលកើតអំពីកម្ម (រូបតណ្ហា) ជាហេតុជិត ។

¤ លក្ខណាទិចតុក្កៈ របស់ សោតប្បសាទរូប

១- **សទ្ទាភិឃាតារហភូតប្បសាទលក្ខណំ** : មានសភាពថ្លានៃមហាភូតរូបដែលគួរដល់ការប៉ះខ្ទប់នូវសទ្ទារម្មណ៍ជាលក្ខណៈ

២- **សទ្ទេសុ អាវិញ្ឆនរសំ** : មានការទាញយកនូវសទ្ទារម្មណ៍ ជាកិច្ច

៣- **សោតវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** : មានការទ្រទ្រង់ទុកនូវសោតវិញ្ញាណ ជាផល

៤- **សោតកាមតានិទានកម្មជភូតបទដ្ឋានំ** : មានមហាភូតរូបដែលកើតអំពីកម្ម (សទ្ទតណ្ហា) ជាហេតុជិត ។

¤ លក្ខណាទិចតុក្កៈ របស់ ឃានបសាទរូប

១- **គន្ធាភិឃាតារហភូតប្បសាទលក្ខណំ** : មានសភាពថ្លានៃមហាភូតរូបដែលគួរដល់ការប៉ះខ្ទប់នូវគន្ធារម្មណ៍ជាលក្ខណៈ

២- **គន្ធេសុ អាវិញ្ឆនរសំ**: មានការទាញយកនូវគន្ធារម្មណ៍ ជាកិច្ច

៣- **ឃានវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** : មានការទ្រទ្រង់ទុកនូវឃានវិញ្ញាណ ជាផល

៤- **ឃាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ** : មានមហាភូតរូបដែលកើតអំពីកម្ម (គន្ធតណ្ហា) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ជិវ្ហាបសាទ

១- **រសាភិឃាតារហភូតប្បសាទលក្ខណំ** : មានសភាព ថ្លានៃមហាភូតរូបដែលប៉ះខ្ទប់ជាមួយរសារម្មណ៏ ជាលក្ខណៈ

២- **រសេសុ អាវិញ្ឆនរសំ:** មានការទាញយកនូវ រសារម្មណ៏ ជាកិច្ច

៣- **ជិវ្ហាវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** : មានការ ទ្រទ្រង់ទុកនូវជិវ្ហាវិញ្ញាណ ជាផល

៤- **សាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ** : មានមហា ភូតរូបកើតអំពីកម្ម (រសតណ្ហា) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ កាយបសាទរូប

១- **ផោដ្ឋព្វាភិឃាតារហភូតប្បសាទលក្ខណំ** : មានសភាព ថ្លានៃមហាភូតរូបដែលប៉ះខ្ទប់ជាមួយនឹង ផោដ្ឋព្វារម្មណ៏ ជាលក្ខណៈ

២- **ផោដ្ឋព្វេសុ អាវិញ្ឆនរសំ** :មានការទាញយកនូវ ផោដ្ឋព្វារម្មណ៏ ជាកិច្ច

៣- **កាយវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** : មានការ ទ្រទ្រង់ទុកនូវកាយវិញ្ញាណ ជាផល

៤- **ផុសិតុកាមតានិទានកម្មជភូតបទដ្ឋានំ** : មានមហាភូតរូប ដែលកើតពីកម្ម (ផោដ្ឋព្វាតណ្ហា) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ រូបារម្មណ៍

១- **ចក្ខុបដិហននលក្ខណំ** : មានការប៉ះខ្ទប់ចក្ខុបសាទ ជាលក្ខណៈ

២- **ចក្ខុវិញ្ញាណស្ស វិសយភាវរសំ** : មានការទទួលអារម្មណ៏ ឱ្យចក្ខុវិញ្ញាណ ជាកិច្ច

៣- **តស្សេវ គោចរបច្ចុប្បដ្ឋានំ** : មានការប្រព្រឹត្តធ្វើជា អារម្មណ៏របស់ចក្ខុវិញ្ញាណ ជាផល

៤- **ចតុមហាភូតបទដ្ឋានំ** : មានមហាភូតរូបទាំង ៤ គឺ (បថវី អាបោ តេជោ វាយោ) ជាហេតុជិត ។

⌑ អត្ថ របស់ ទុក្ខសមុទយអរិយសច្ចៈ

១- **អាយុហនត្ថោ** : មានសភាព ធ្វើទុក្ខឱ្យកើតឡើង

២- **និទានត្ថោ** : មានសភាពជាដែនកើតនៃទុក្ខ

៣- **សំយោគត្ថោ** : មានសភាពប្រកបទុកនូវសេចក្ដី ទុក្ខ មិនឱ្យផុតទុក្ខ

៤- **បលិពោធត្ថោ** : មានសភាពកង្វល់នៅតែក្នុងកងទុក្ខ ។

⌑ អត្ថ របស់ ទុក្ខនិរោធអរិយសច្ចៈ

១- **និស្សរណដ្ឋោ** : មានសភាពរលាស់ចេញចាកទុក្ខទាំងពួង

២- **អបលិពោធដ្ឋោ** : មានសភាពមិនកង្វល់ដោយកងទុក្ខ

៣- **អសង្ខតដ្ឋោ** : មានសភាពមិនមានការប្រជុំតាក់តែង

៤- **អមតដ្ឋោ** : មិនមានការស្លាប់ ការកើតបន្តទៅទៀតឡើយ ។

⌑ អត្ថ របស់ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ

១- **និយ្យានដ្ឋោ** : មានសភាពជាធម៌ដែលនាំចេញចាកទុក្ខ

២- **ហេតុដ្ឋោ** : មានសភាពជាហេតុរំលត់នូវកងទុក្ខ

៣- **ទស្សនដ្ឋោ** : មានសភាពជាគ្រឿងនាំឱ្យឃើញព្រះនិព្វាន

៤- **អធិបតិយដ្ឋោ** : មានសភាពជាធំក្នុងការសម្រេចកិច្ចឃើញពិត និងប្រត្យក្សនូវសច្ចៈទាំង ៤ ។

☐ លក្ខណាទិចតុក្កៈ របស់ សទ្ទារម្មណ៍

១- **សោតបដិហននលក្ខណំ** : មានការប៉ះខ្ទប់សោតប្បសាទ ជាលក្ខណៈ

២- **សោតវិញ្ញាណស្ស វិសយភាវរសំ** : មានការទទួលអារម្មណ៍ឱ្យដល់សោតវិញ្ញាណ ជាកិច្ច

៣- **តស្សេវ គោចរបច្ចុប្បដ្ឋានំ** : មានការប្រព្រឹត្តធ្វើជាអារម្មណ៍របស់សោតវិញ្ញាណ ជាផល

៤- **ចតុមហាភូតបទដ្ឋានំ** : មានមហាភូតរូបទាំង ៤ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ រសារម្មណ៍

១- **ជិវ្ហាបដិហននលក្ខណំ** : មានការប៉ះខ្ទប់ជិវ្ហាបសាទជាលក្ខណៈ

២- **ជិវ្ហាវិញ្ញាណស្ស វិសយភាវរសំ** : មានការទទួលអារម្មណ៍ឱ្យដល់ជិវ្ហាវិញ្ញាណ ជាកិច្ច

៣- **តស្សេវ គោចរបច្ចុប្បដ្ឋានំ** : មានការប្រព្រឹត្តជាជាអារម្មណ៍របស់ជិវ្ហាវិញ្ញាណ ជាផល

៤- **ចតុមហាភូតបទដ្ឋានំ** : មានមហាភូតរូបទាំង ៤ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ផោដ្ឋព្វារម្មណ៍

អង្គធម៌ បានដល់

បឋវី ហៅថា បឋវី ផោដ្ឋព្វារម្មណ៍

តេជោ ហៅថា តេជោ ផោដ្ឋព្វារម្មណ៍

វាយោ ហៅថា វាយោ ផោដ្ឋព្វារម្មណ៍

ចំពោះលក្ខណាទិចតុក្កៈរបស់ធាតុទាំង ៣ នេះ មានន័យតែមួយដូចគ្នា នឹងរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ ដែលបានសរសេររួចមកហើយនៅខាងដើមនោះ ។

⌑ លក្ខណាទិចតុក្កៈ របស់ សុខវេទនា

១- **ឥដ្ឋផោដ្ឋព្វានុភវនលក្ខណា** : មានការសម្ផស្សត្រូវត្រង់ជាមួយអារម្មណ៍ល្អ ជាលក្ខណៈ

២- **សម្បយុត្តានំ ព្យូហនរសា** : មានការធ្វើឱ្យសម្បយុត្តធម៌ចម្រើន ជាកិច្ច

៣- **កាយិក អស្សាទបច្ចុប្បដ្ឋានា** : មានការស្ងើចសរសើរត្រេកអរផ្លូវកាយ ជាផល

៤- **កាយិន្ទ្រិយបទដ្ឋានា** : មានកាយបសាទ ជា ហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ សោមនស្សវេទនា

១- **ឥដ្ឋារម្មណានុភវនលក្ខណា** : មានការសោយអារម្មណ៍ល្អ ជាលក្ខណៈ

២- **ឥដ្ឋាការសម្ភោគរសា** : មានការសោយរសរបស់អារម្មណ៍ល្អ ជាកិច្ច

៣- **ចេតសិកអស្សាទបច្ចុប្បដ្ឋានា** : មានការស្ញើចសរសើរត្រេកអរផ្លូវចិត្ត ជាផល

៤- **បស្សទ្ធិបទដ្ឋានា** : មានការស្ងប់កាយ ស្ងប់ចិត្ត ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ទោមនស្សវេទនា

១- **អនិដ្ឋារម្មណានុភវនលក្ខណា** : មានការសោយអារម្មណ៍មិនល្អ ជាលក្ខណៈ

២- **អនិដ្ឋាការសម្ភោគរសា** : មានការសោយរសរបស់អារម្មណ៍មិនល្អ ជាកិច្ច

៣- **ចេតសិកាពាធបច្ចុប្បដ្ឋានា** : មានអាពាធផ្លូវចិត្ត ជាផល

៤- **ហទយវត្ថុបទដ្ឋានា** : មានហទយវត្ថុ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ឧបេក្ខាវេទនា

១- **មជ្ឈត្តវេទយិតលក្ខណា** : មានការសោយអារម្មណ៍ជាកណ្តាល ជាលក្ខណៈ

២- **សម្បយុត្តានំ នាតិឧបព្យូហនមិលាបនរសា** : មានការរក្សាសម្បយុត្តធម៌ មិនឱ្យសៅហ្មង ជាកិច្ច

៣- **សន្តភាវបច្ចុប្បដ្ឋានា** : មានការស្ងប់ ជាផល

៤- **និប្បីតិកចិត្តបទដ្ឋានា** : មានចិត្តមិនត្រេកអរនឹងបីតិ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ករុណាចេតសិក

១- **ទុក្ខាបនយនាការបវត្តិលក្ខណា** : មានការបានឃើញអ្នកដទៃជាទុក្ខ (រមែងមានការអាណិតអាសូរ) ជាលក្ខណៈ

២- **បរទុក្ខាសហនរសា** : មានការមិនចង់ ឬមិនចូលចិត្តឃើញទុក្ខរបស់អ្នកដទៃ ជាកិច្ច

៣- **អវិហឹសាបច្ចុប្បដ្ឋានា** : មានការមិនបៀតបៀន ជាផល

៤- **ទុក្ខាភិភូតានំ អនាថភាវទស្សនបទដ្ឋានា** : មានការបានឃើញសត្វទាំងឡាយ អ្នកត្រូវទុក្ខគ្របសង្កត់ ហើយគ្មានទីពឹង ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ មុទិតាចេតសិក

១- **បមោទនលក្ខណា** : មានសេចក្តីត្រេកអរក្នុងសេចក្តីសុខរបស់អ្នកដទៃ ជាលក្ខណៈ

២- **អនិស្សាយនរសា** : មានការមិនមានឥស្សា ឬ ឫស្យា ជាកិច្ច

៣- **អរតិវិឃាតបច្ចុប្បដ្ឋានា** : មានសេចក្តីប្រាថ្នាឱ្យអ្នកដទៃចម្រើន ជាផល

៤- **សត្តានំ សម្បត្តិទស្សនបទដ្ឋានា** : មានការបានឃើញសម្បត្តិរបស់សត្វទាំងឡាយ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ហទយរូប

១- **មនោធាតុមនោវិញ្ញាណធាតូនំ និស្សយលក្ខណំ** : មានការឱ្យមនោធាតុ និងមនោវិញ្ញាណធាតុបានជាទីអាស្រ័យ ជាលក្ខណៈ

២- **តាសញ្ញេវ ធាតូនំ អាធារណរសំ** : មានការទ្រទ្រង់ទុកនូវធាតុដែលបានពោលហើយ ជាកិច្ច

៣- **តទុព្វាហនបច្ចុប្បដ្ឋានំ** : មានការរក្សាទុកនូវធាតុដែលបានពោលហើយ ជាផល

៤- **ចតុមហាភូតបទដ្ឋានំ** : មានមហាភូតរូបទាំង ៤ ជាបទដ្ឋាន ។

⌑ លក្ខណាទិចតុក្កៈ របស់ ជីវិតរូប

១- **សហជាតរូបានុបាលលក្ខណំ** : មានការរក្សាអនុបាល សហជាតរូប ជាលក្ខណៈ

២- **តេសំ បវត្តនរសំ** : មានការថែរក្សាទុក ឬឱ្យប្រព្រឹត្តទៅនូវរូបទាំងនោះ ជាកិច្ច

៣- **តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ** : មានការប្រកបទុកនូវរូបយ៉ាងមាំល្អ ជាផល

៤- **យាបយិតព្វបទដ្ឋានំ** : មានមហាភូតរូបដែលមានចំណែកស្មើគ្នាជានិច្ចកាល ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អាហាររូប

១- **ឱជាលក្ខណំ** : មានការធ្វើឱ្យរូបចម្រើន ជាលក្ខណៈ

២- **រូបាហរណរសំ** : មានការថែរក្សាទុកនូវរូប ជាកិច្ច

៣- **កាយុបត្ថម្ភនបច្ចុប្បដ្ឋានំ** : មានការជួយឧបត្ថម្ភទុកនូវរូបកាយ ជាផល

៤- **អជ្ឈោហរិតព្វបទដ្ឋានំ** : មានអាហារដែលគួរដល់ការបរិភោគ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ កាយវិញ្ញត្តិរូប

១- **វិញ្ញាបនលក្ខណំ** : មានការសម្តែងបញ្ជាក់ឱ្យដឹងសេចក្តីសម្គាល់ ជាលក្ខណៈ

២- អធិប្បាយបកាសនរសំ : មានការសម្តែងបញ្ជាក់សេចក្តីសម្គាល់ ជាកិច្ច

៣- **កាយវិប្ផន្ទនហេតុភាវបច្ចុប្បដ្ឋានំ** : មានការកម្រើកកាយ ជាផល

៤- **ចិត្តសមុដ្ឋានវាយោធាតុបទដ្ឋានំ** : មានវាយោរបស់ចិត្តសមុដ្ឋាន ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ វចីវិញ្ញត្តិរូប

១- **វិញ្ញាបនលក្ខណំ** : មានការសំដែងបញ្ជាក់ឱ្យដឹងសេចក្តីសំគាល់ ជាលក្ខណៈ

២- អធិប្បាយបកាសនរសំ : មានការសំដែងបញ្ជាក់សេចក្តីសំគាល់ ជាកិច្ច

៣- វចីឃោសហេតុភាវបច្ចុប្បដ្ឋានំ : មានការពោលវាចាជាផល

៤- **ចិត្តសមុដ្ឋានបឋវីធាតុបទដ្ឋានំ** : មានបឋវីធាតុរបស់ចិត្តសមុដ្ឋាន ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ លហុតារូប

១- **អទន្ធតាលក្ខណា** : មានការស្រាល ជាលក្ខណៈ

២- **រូបានំ គរុភាវវិនោទនរសា** : មានការកម្ចាត់ការធ្ងន់របស់រូប ជាកិច្ច

៣- **លហុបរិវត្តិតាបច្ចុប្បដ្ឋានា** : មានការធ្វើឱ្យរហ័សរហួនរាងរៃ ជាផល

៤- **លហុរូបបទដ្ឋានា** : មានរូបស្រាលជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ មុទុតារូប

១- **អថទ្ធតា លក្ខណា** : មានការទន់មិនរឹង ជាលក្ខណៈ

២- **រូបានំ ថទ្ធភាវវិនោទនរសា** : មានការកម្ចាត់នូវភាពរឹងត្អឹងរបស់រូប ជាកិច្ច

៣- **សព្វក្រិយាសុ អវិរោធិតាបច្ចុប្បដ្ឋានា** : មានការមិនជំទាស់ដណ្ដើមក្នុងអំពើទាំងពួង ជាផល

៤- **មុទុរូបបទដ្ឋានា** : មានរូបទន់ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ កម្មញ្ញតារូប

១- **កម្មញ្ញភាវលក្ខណា** : មានភាពគួរដល់ការងារ ជាលក្ខណៈ

២- **អកម្មញ្ញតាវិនោទនរសា** : មានការកម្ចាត់នូវភាពមិនគួរដល់ការងារ ជាកិច្ច

៣- **អទុព្វលភាវបច្ចុប្បដ្ឋានា** : មានរូបមិនទុព្វល ឬមិនអន់ថយ ជាផល

៤- **កម្មញ្ញរូបបទដ្ឋានា** : មានរូបគួរដល់ការងារ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ ឧបចយរូប

១- **អាចយលក្ខណោ** : មានការផ្តើមកើតឡើង (សន្សំ) ជាដំបូង ជាលក្ខណៈ

២- **រូបានំ ឧម្មុជ្ជាបនរសោ** : មានការធ្វើឱ្យរូបបានកើតឡើង ជាកិច្ច

៣- **បរិបុណ្ណភាវបច្ចុប្បដ្ឋានោ** : មានសភាពចម្រើនបរិបូណ៌របស់រូប ជាផល

៤- **ឧបចិតរូបបទដ្ឋានោ** : មានរូបដែលកំពុងនឹងកើតក្នុងឧប្បាទខណៈ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ សន្តតិរូប

១- **បវត្តិលក្ខណា** : មានការចម្រើនឋិតនៅ ជាលក្ខណៈ

២- **អនុប្បពន្ធនរសា** : មានការបន្តគ្នាតាមលំដាប់ ជាកិច្ច

៣- **អនុប្បច្ឆេទបច្ចុប្បដ្ឋានា** : មានការមិនកាត់ផ្តាច់ចេញពីគ្នាឬឃ្លាតចាកគ្នា ជាផល

៤- **អនុប្បពន្ធករូបបទដ្ឋានា** : មានរូបឱ្យកើតបន្តគ្នាជាលំដាប់យ៉ាងជិត ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ជរតារូប

១- **រូបបរិបាកលក្ខណា** : មានការចាស់គ្រាំគ្រានៃរូបជាលក្ខណៈ

២- **ឧបនយនរសា** : មានការនាំទៅរកការចាស់គ្រាំគ្រាជាកិច្ច

៣- **នវភាវាបគមនបច្ចុប្បដ្ឋានា** : មានការមិនចូលទៅរកការកើតថ្មី ជាផល

៤- **បរិបច្ចមានរូបបទដ្ឋានា** : មានរូបដែលចាស់គ្រាំគ្រាជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អនិច្ចតារូប

១- **បរិភេទលក្ខណា** : មានការចាស់គ្រាំគ្រា ជាលក្ខណៈ

២- **សំសីទនរសា** : មានការសំយុងលិចចុះ ជាកិច្ច

៣- **ខយវយបច្ចុប្បដ្ឋានា** : មានការអស់ទៅសូន្យទៅ ជាផល

៤- **បរិភិជ្ជមានរូបបទដ្ឋានា** : មានរូបដែលបែកធ្លាយ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ សង្ខារ

១- **អភិសង្ខរណលក្ខណា** : មានការប្រជុំតាក់តែង ជាលក្ខណៈ

២- អាយូហនរសា : មានការព្យាយាមឱ្យបដិសន្ធិវិញ្ញាណ ឬព្យាយាមឱ្យផល គឺរូបនិងនាម កើតឡើង ជាកិច្ច

៣- **ចេតនាបច្ចុប្បដ្ឋានា** : ជាធម្មជាតិដែលនាំឱ្យកើតឡើង ជាផល

៤- **អវិជ្ជាបទដ្ឋានា** : មានអវិជ្ជា ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ បដិច្ចសមុប្បាទធម៌

១- **ជរាមរណាទីនំ ធម្មានំ បច្ចយលក្ខណោ** : ជាឧបការៈ ដល់បច្ចយុប្បន្នធមិទាំងឡាយមានជរា មរណៈ ជាដើម ជាលក្ខណៈ

២- **ទុក្ខានុពន្ធនរសោ** : មានការធ្វើឱ្យសត្វទាំងឡាយកើត ក្នុងវដ្តសង្សាររឿយៗ ជាកិច្ច ឬមានការចងភ្ជាប់សត្វទាំងឡាយទុកក្នុងសង្សារវដ្តជាទុក្ខ ជាកិច្ច

៣- **កុម្មគ្គបច្ចុប្បដ្ឋានោ** : ជាផ្លូវហែលវិលវល់ក្នុងវដ្តសង្សារ ដែលគួរឱ្យខ្លាចជាផល ឬជាផ្លូវដែលដើរមិនត្រូវត្រង់ ឆ្លងរំលងផ្លូវឆ្ពោះទៅព្រះនិព្វាន ជាផល

៤- **អាសវបទដ្ឋានោ** : មានអាសវៈ ជាហេតុជិត ។

☐ លក្ខណាទិចតុក្កៈ របស់ សឡាយតនៈ

១- **អាយតនលក្ខណំ** : មានការប៉ះខ្ទប់ ឬធ្វើវដ្តសង្សារឱ្យ យឺតយូរ ជាលក្ខណៈ

២- **ទស្សនរសំ** : មានការប៉ះខ្ទប់ ឬរឹបទាញអារម្មណ៍របស់ ខ្លួន ឬមានការឃើញអារម្មណ៍ជាដើម ជាកិច្ច

៣- **វត្ថុភាវបច្ចុប្បដ្ឋានំ** : មានការធ្វើវត្ថុជាមួយនឹងទ្វារ ជាផល

៤- **នាមរូបបទដ្ឋានំ** : មានចេតសិក និងកម្មជរូប ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ សោកៈ

១- **អន្តោនិជ្ឈានលក្ខណោ** : មានការដុតរោលខាងក្នុងឱ្យស្ងប់ស្ងួតចិត្ត ឬក្ដៅក្រហាយចិត្ត ជាលក្ខណៈ

២- **ចេតោបរិនិជ្ឈាយនរសោ** : មានការធ្វើឱ្យចិត្តពេញទៅដោយសេចក្ដីក្ដៅក្រហាយ ជាកិច្ច

៣- **អនុសោចនបច្ចុប្បដ្ឋានោ** : មានសេចក្ដីសោកសៅរឿយៗ ពីសេចក្ដីវិនាស ដែលជួបប្រសប់ ជាផល

៤- **ទោសចិត្តុប្បាទបទដ្ឋានោ** : មានទោសចិត្តុប្បាទជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ បរិទេវៈ"សទ្ទរូប"

១- **លាលប្បនលក្ខណោ** : មានការយំសោកពោលរៀបរាប់ជាលក្ខណៈ

២- **គុណទោសបរិកិត្តនរសោ** : មានការពោលថ្លែងរៀបរាប់នូវគុណ គឺអំពើល្អនិងទោស ជាកិច្ច

៣- **សម្ភមបច្ចុប្បដ្ឋានោ** : មានចិត្តញាប់ញ័រ មិនតាំងមាំជាផល

៤- **ទោសចិត្តជមហាភូតបទដ្ឋានោ** : មានមហាភូតរូបដែលកើតពីទោសចិត្ត ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ទោមនស្ស

១- **ចិត្តបីឡនលក្ខណំ** : មានការបៀតបៀនចិត្ត ជាលក្ខណៈ

២- **មនោវិឃាតនរសំ** : មានការធ្វើទុក្ខបុកម្នេញចិត្ត ជាកិច្ច

៣- **មានសញ្ញាធិបច្ចុប្បដ្ឋានំ** : មានការមិនសប្បាយចិត្ត ជាផល

៤- **ហទយវត្ថុបទដ្ឋានំ** : មានហទយវត្ថុ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ឧបាយាសៈ

១- **ចិត្តបរិទហនលក្ខណោ** : មានការដុតកម្តៅនូវចិត្តដ៏ខ្លាំងក្លា ជាលក្ខណៈ

២- **និត្ថុននរសោ** : មានការរួញរាដកចិត្តចេញ (អស់អាល័យសេចក្តីស្លាប់) ជាកិច្ច

៣- **វិសាទបច្ចុប្បដ្ឋានោ** : មានកាយ និងចិត្តបាក់កម្លាំង ជាផល

៤- **ហទយវត្ថុបទដ្ឋានោ** : មានហទយវត្ថុ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ មោហចេតសិក

១- **អញ្ញាណលក្ខណោ** : មានការមិនដឹង ជាលក្ខណៈ

២- **អារម្មណសភាវច្ឆាទនរសោ** : មានការបិទបាំងទុកនូវសភាវនៃអារម្មណ៍ ជាកិច្ច

៣- **អន្ធការបច្ចុប្បដ្ឋានោ** : មានសេចក្តីងងឹត ជាផល

៤- **អយោនិសោមនសិការបទដ្ឋានោ** : មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះអារម្មណ៍ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អហិរិកចេតសិក

១- **កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ** : មានការមិនស្អប់ខ្ពើមចំពោះកាយទុច្ចរិតជាដើម ជាលក្ខណៈ

២- **បាបានំ ករណរសំ** : មានការធ្វើបាប ជាកិច្ច

៣- **អសង្កោចនបច្ចុប្បដ្ឋានំ** : មានការមិនស្អប់ខ្ពើមចំពោះបាបធម៌ ជាផល

៤- **អត្តអគារវបទដ្ឋានំ** : មានការមិនគោរពខ្លួនឯង ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ អនោត្តប្បចេតសិក

១- **អនុត្តាសលក្ខណំ** : មានការមិនភ័យភ្ញាក់ខ្លាច ចំពោះបាប ជាលក្ខណៈ

២- **បាបានំ ការណរសំ** : មានការធ្វើបាប ជាកិច្ច

៣- **អសង្កោចនបច្ចុប្បដ្ឋានំ** : មានការមិនស្អប់ខ្ពើមបាបធម៌ ជាកិច្ច

៤- **បរអគារវបទដ្ឋានំ** : មានការមិនគោរពអ្នកដទៃ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ឧទ្ធច្ចចេតសិក

១- **អវូបសមលក្ខណំ** : មានការមិនស្ងប់ ជាលក្ខណៈ

២- **អនវត្ថានរសំ** : មានការមិនតាំងមាំក្នុងអារម្មណ៍ ជាផល

៣- **ភន្តត្តបច្ចុប្បដ្ឋានំ** : មានការរសាប់រសល់ក្រវល់ក្រវាយរាយមាយ ជាផល

៤- **អយោនិសោមសិការបទដ្ឋានំ** : មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះអារម្មណ៍ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ លោភចេតសិក

១- **អារម្មណគ្គហណលក្ខណោ** : មានការប្រកាន់មាំនូវអារម្មណ៍ ជាលក្ខណៈ

២- **អភិសង្គរសោ** : មានការជាប់ស្អិតក្នុងអារម្មណ៍ ជាកិច្ច

៣- **អបរិច្ចាគបច្ចុប្បដ្ឋានោ** : មានការមិនបរិច្ចាគ ជាផល

៤- **សំយោជនិយធម្មេសុ អស្សាទទស្សនបទដ្ឋានោ** : មានការឃើញដោយសេចក្តីត្រេកអរក្នុងសំយោជនធម៌ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ទិដ្ឋិចេតសិក

១- **អយោនិសោអភិនិវេសលក្ខណា** : មានការប្រកាន់ព្រោះអយោនិសោ ជាលក្ខណៈ

២- **បរាមាសរសា** : មានការប្រកាន់ខុសពីសភាវៈជាកិច្ច

៣- **មិច្ឆាភិនិវេសបច្ចុប្បដ្ឋានា** : មានការប្រកាន់នូវការយល់ខុស ជាផល

៤- **អរិយានំ អទស្សនកាមតាទិបទដ្ឋានា** : មានការមិនត្រូវការឃើញព្រះអរិយជាដើម ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ មានះចេតសិក

១- **ឧន្នតិលក្ខណោ** ៖ មានការប្រកាន់ខ្លួន ជាលក្ខណៈ

២- **សម្បគ្គហរសោ** ៖ មានការស្ញើចសរសើរ ជាកិច្ច

៣- **កេតុកម្យតាបច្ចុប្បដ្ឋានោ** ៖ មានការប្រាថ្នាខ្ពស់ ជាផល

៤- **ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ** ៖មានលោភទិដ្ឋិគតវិប្បយុត្ត ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ទោសចេតសិក

១- **ចណ្ឌិកលក្ខណោ** ៖ មានការកាចសាហាវ ជាលក្ខណៈ

២- **និស្សយទហនរសោ** ៖ មានការធ្វើឱ្យចិត្តខ្លួនឯង និងអ្នកដទៃ ឆេះស្រពោន ជាកិច្ច

៣- **ទុស្សនបច្ចុប្បដ្ឋានោ** ៖ មានការប្រទូសរ៉ាយ និងបំផ្លាញ ជាផល

៤- **អាឃាតវត្ថុបទដ្ឋានោ** ៖ មានអាឃាតវត្ថុ (១០) ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ឥស្សាចេតសិក

១- **បរសម្បត្តីនំ ឧសូយនលក្ខណា** ៖ មានការចង់បានសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ

២- **តត្ថេវ អនភិរតិរសា** ៖ មានការមិនចូលចិត្តនឹងការមានបាន របស់អ្នកដទៃ ជាកិច្ច

៣- **តតោវមុខភាវបច្ចុប្បដ្ឋានា** ៖ មានការងាកមុខចេញពីសម្បត្តិអ្នកដទៃ ជាផល

៤- **បរសម្បត្តិបទដ្ឋានា** ៖ មានសម្បត្តិអ្នកដទៃ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ មច្ឆរិយចេតសិក

១- **អត្តនោ សម្បត្តីនំ និគូហនលក្ខណំ** ៖ មានការលាក់ទុកសម្បត្តិរបស់ខ្លួន ជាលក្ខណៈ

២- **តាសំយេវ បរេហិសាធារណភាវអក្ខមនរសំ** ៖ មានការមិនចូលចិត្តឱ្យសម្បត្តិរបស់ខ្លួនទុកជាសាធារណដល់អ្នកដទៃ ជាកិច្ច

៣- **សង្កោចនបច្ចុប្បដ្ឋានំ** ៖ មានការរួញរា ស្អុតចិត្ត ហួងហែងមិនអើពើ ជាផល

៤- **អត្តសម្បត្តិបទដ្ឋានំ** ៖ មានសម្បត្តិរបស់ខ្លួនជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ កុក្កុច្ចចេតសិក

១- បច្ឆានុតាបនលក្ខណំ ៖ មានការក្តៅក្រហាយស្តាយក្រោយរឿយៗ ជាលក្ខណៈ

២- កតាកតានុសោចនរសំ ៖ មានការក្តៅក្រហាយស្តាយក្រោយរឿយៗដល់បាបដែលខ្លួន បានធ្វើរួចហើយ និងបុណ្យដែលមិនទាន់បានធ្វើ ជាកិច្ច

៣- វិប្បដិសារបច្ចុប្បដ្ឋានំ ៖ មានការស្តាយក្រោយ ជាផល

៤- កតាកតបទដ្ឋានំ ៖ មានការធ្វើអំពើបាប មិនបានធ្វើអំពើបុណ្យ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ ថីនចេតសិក

១- អនុស្សាហនលក្ខណំ ៖ មានការមិនឧស្សាហ៍ ជាលក្ខណៈ

២- វិរិយវិនោទនរសំ ៖ មានការកម្ចាត់សេចក្តីព្យាយាម ជាកិច្ច

៣- សំសីទនបច្ចុប្បដ្ឋានំ ៖ មានការទម្រន់អន់ថយ ជាផល

៤- អយោនិសោមនសិការបទដ្ឋានំ ៖ មានការមិនយកចិត្តទុកដាក់ ដោយឧបាយត្រូវទំនងចំពោះអារម្មណ៍ ជាបទដ្ឋាន ។

⌑ លក្ខណាទិចតុក្កៈ របស់ មិទ្ធចេតសិក

១- អកម្មញ្ញតាលក្ខណំ : មិនមានភាពគួរដល់ការងារ ជាលក្ខណៈ

២- **ឱនហនរសំ** : មានការលោក់កំបាំងកុសល ជាកិច្ច

៣- **លីនតាបច្ចុប្បដ្ឋានំ** : មានការរួញរាថយក្រោយ ជាផល

៤- **អយោនិសោមនសិការបទដ្ឋានំ** : មានការមិនយកចិត្តទុកដាក់ត្រូវទំនងចំពោះអារម្មណ៍ ជាហេតុជិត ។

⌑ លក្ខណាទិចតុក្កៈ របស់ វិចិកិច្ឆាចេតសិក

១- **សំសយលក្ខណា** : មានសេចក្តីសង្ស័យ ជាលក្ខណៈ

២- កម្បនរសា : មានការស្ទាក់ស្ទើរញញើតញញើមច្របូកច្របល់ក្នុងអារម្មណ៍ ជាកិច្ច

៣- អនិច្ឆយបច្ចុប្បដ្ឋានា : មានការមិនអាចសម្រេចចិត្តបាន ជាផល

៤- **អយោនិសោមនសិការបទដ្ឋានា** : មានការមិនយកចិត្តទុកដាក់ត្រូវទំនងចំពោះអារម្មណ៍ ជាហេតុជិត ។

ចប់

សរុបសៀវភៅ

សៀវភៅ ដែលបានសរសេររៀបរៀងចងក្រងរួចបាន ៧ រឿង គឺ **សន្ធាយនា ពុទ្ធព្យាករណ៍ សភាវៈ ធម្មដ្ឋិតិ ក្រសែជីវិត លោកទស្សនៈ មកដោយពិត** នឹងកំពុងបន្តការងារ ធម្ម សប្បាយនេះរៀងរហូត ។ ចំពោះវិភាគទានក្នុងការជួយ ឧបត្ថម្ភបោះពុម្ព កើតចេញពីសន្ដានចិត្តជ្រះថ្លារបស់ពុទ្ធបរិស័ទ ទាំងអស់គ្នា ។

អាស្រ័យហេតុនេះ លោកអ្នកមានបំណង ចង់ជួយចូលរួមបំពេញនូវមហាកុសលក្នុងដំណើរការធម្មទាន ដ៏កម្រ និងបច្ច័យ ៤ សូមមេត្តាទំនាក់ទំនងតាមទូរសព្ទលេខ **០១១ ៦៧៣ ៤០៦** ឬអាចផ្ញើតាមរយៈអ្នកដទៃណាក៏បាន ។

សូមអរព្រះគុណ ។

ពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅធម៌

- **មហាឧបាសិកា ប៊ុន ស៊ាងលី និងលោកជំទាវ ព្រមទាំងកូនចៅ 200$**
- ឧបាសិកា **គីម ឡុម** និងកូនចៅ 100$
- ឧបាសិកា **ចាន់ ឈាង**(ហៅពៅ) និងស្វាមី ព្រមទាំងបុត្រ 100$
- ឧបាសិកា **ភាំង ហ្គេចណៃ** និងស្វាមី ព្រមទាំងបុត្រ 50$
- លោក **ញិប ម៉េងហាក់** និងភរិយា ព្រមទាំងបុត្រ } 50$
- លោក **ថាប ឆេង** និងភរិយា ព្រមទាំងបុត្រ }
- ឧបាសក **ស៊ុម ទាសនា** ព្រមទាំងមាតាបិតា 50$
- លោក **មេង ហ៊ុនសុជាតិដាវិដ** និងភរិយា ព្រមទាំងបុត្រ 20$
- ឧបាសិកា **ឆ វី** ព្រមទាំងកូនចៅ 20$
- អ្នកស្រី **ចំន្ទ វ៉ា** និងស្វាមី ព្រមទាំងបុត្រ 20$
- អ្នកស្រី **ហ៊ុយ សោភ័ណ្ឌ** ព្រមទាំងបុត្រ 20$
- ឧបាសិកា **ស៊ុន ដា** ព្រមទាំងបុត្រ 10$
- ឯកឧត្តម **សុខ សុរិយា** និងលោកជំទាវ **ឆូ ទេជ្ជសារ** ព្រមទាំងបុត្រ 10$
- ឧបាសិកា **តែ គីមមួយ** ព្រមទាំងកូនចៅ 10$
- ឧបាសិកា **សឹម បុញ្ញ** 10$
- ឧបាសិកា **តាំង លីគាង** និងស្វាមី ព្រមទាំងកូនចៅ 10$
- ឧបាសក **ឌីន ដេត** និងភរិយា ព្រមទាំងកូនចៅ 10$

- លោក **អឿង កៅ** និង **លន់ ច័ន្ទថុល** ព្រមទាំងបុត្រ 10$
- ឧបាសក **សុខ ឡុង** ព្រមទាំងកូនចៅ 10$
- ឧបាសិកា **គ្រៀល ស៊ីយ៉ា** និងស្វាមី ព្រមទាំងកូនចៅ 10$
- ឧបាសិកា **គីម អេងស៊ីវហេង** និងស្វាមី ព្រមទាំងកូនចៅ 10$
- ឧបាសិកា **ទ៉ាន់ មុនី** ព្រមទាំងកូនចៅ 10$
- ឧបាសក **ខៀវ កុឡា**និងឧបាសិកា **លឿង លៀងហួរ**ព្រមទាំងកូនចៅ 10$
- លោក **អឿង កៅ** និងអ្នកស្រី **លន់ ច័ន្ទថុល** ព្រមទាំងបុត្រ 10$
- ឧបាសិកា **មាឃ យ៉ារី** ព្រមទាំងកូនចៅ 10$
- លោក **ម៉ុក ឆៅសេង** និងភរិយា ព្រមទាំងបុត្រ 6$
- ឧបាសិកា **ភាំង ឆៅឆាង** និង **ហេ អេន** ព្រមទាំងបុត្រ 5$
- ឧបាសក **ផុន តឿង** និងឧបាសិកា **ផុន យ៉េត** ព្រមទាំងកូនចៅ 5$
- ឧបាសក **ហង់ វណ្ណះ** និងភរិយា ព្រមទាំងបុត្រ 5$
- ឧបាសិកា **ហេង លាងស៊ីម** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ជុំ នូច** ព្រមទាំងកូនចៅ 5$
- ឧបាសក **ឃ្លោក ម៉េងឆាង** និងឧបាសិកា **ឱម សារឿន**ព្រមទាំងកូនចៅ5$
- ឧបាសក **លន់ គីមស៊ុយ** ព្រមទាំងកូនចៅ 5$
- លោក **ហៀង សារ៉ា** និងឧបាសិកា **ស្រី ស៊ីវុឌ្ឍថា** ព្រមទាំងកូនចៅ 5$
- លោក **ឡាយ ស្រ៊ី** និងភរិយា **ខុង ប៊ូគីម** ព្រមទាំងបុត្រ 5$
- ឧបាសិកា **ចាំង នីម** និង **ចាំង គីមនូច** ព្រមទាំងក្មួយៗ 5$

- ឧបាសក **ចាន់ ម៉ែត** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ខុម** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ថុំ សម្បត្តិ** ព្រមទាំងក្មួយៗ 5$
- លោក **ចាន់ សាម៉េត** និងភរិយា ព្រមទាំងកូនចៅ 5$
- លោក **ឱក សារ៉ាន់** និងភរិយា ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ហេង ម៉ុច** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ផៅ ស៊ីមុន** ព្រមទាំងកូនចៅ 5$
- កញ្ញា **អ៊ឹង មួយលី** និងប្អូនៗ និង **ឡេង វ៉ាន់ថា** 2$
- អ្នកស្រី **សោម សុឃឿន** និងស្វាមី ព្រមទាំងបុត្រ 1$
- ឧបាសិកា **អ៊ឹង គីមរស់** ព្រមទាំងកូនចៅ 150000៛
- ឧបាសិកា **អ៊ួង ឈុនហួង** និងអ្នកស្រី **ពុទ្ធិដា** ព្រមទាំងបុត្រ 60000៛
- ឧបាសិកា **ឧតមា ពេជ្រអូន** ព្រមទាំងកូនចៅ 50000៛
- ឧបាសក **ម៉ែន ម៉ុល** និងកូនស្រី **ម៉ុល វណ្ណា** 40000៛
- ឧបាសក **យន្ត ស្ងួន** និងភរិយា ព្រមទាំងកូនចៅ 40000៛
- លោក **សេង ហ៊ត់** និងអ្នកស្រី **អ៊ាម មុយ** ព្រមទាំងបុត្រ 40000៛
- លោកវេជ្ជ. **ម៉ី ណយ** និងភរិយា ព្រមទាំងបុត្រ 30000៛
- ឧបាសិកា **ជួង រ៉ាវី** និងស្វាមី ព្រមទាំងបុត្រ 30000៛
- អ្នកស្រី **តាន់ ទួចលីម** និងស្វាមី ព្រមទាំងបុត្រ 30000៛
- ឧបាសក **អ៊ុក សាម៉ាណារា** និងឧបាសិកា **ហ៊ាប តេង** ព្រមទាំងកូនចៅ30000៛

- ឧបាសក **នរ មេត្តា** និងឧបាសិកា **ជួង គុយអេង** ព្រមទាំងកូនចៅ 20000៛
- ឧបាសក **ម៉ូយ ពៅ** និងឧបាសិកា **គឹម ឡេង** ព្រមទាំងកូនចៅ 20000៛
- ឧបាសក **ឃួន យ៉ា** និងឧបាសិកា **មាស ឡៃស្រួយ** ព្រមទាំងកូនចៅ20000៛
- ឧបាសិកា **ហុង លាក់** ព្រមទាំងកូនចៅ 20000៛
- ឧបាសិកា **ភាំង ចៅឆាង** និង**ហេង អេន** ព្រមទាំងបុត្រ 20000៛
- លោក **ទ៉ុច យៀកហ៊្វរ** និងភរិយា ព្រមទាំងបុត្រ 20000៛
- ឧបាសិកា **លន់ គឹមហុង** ព្រមទាំងបុត្រ 20000៛
- ឧបាសិកា **កែវ ណៃហេង** ព្រមទាំងបុត្រ 20000៛
- លោក **ណី ចាន់ថន** និងអ្នកស្រី **ឈាង ចរិយា** ព្រមទាំងបុត្រ 20000៛
- ឧបាសិកា **ឈឹម ផលវិទ្យា** និងក្មួយប្រុស **ទរុខោភក្តី** 20000៛
- ឧបាសក **តេន សាមាន**និងឧបាសិកា **នន់ ឈៀង** ព្រមទាំងកូនចៅ 20000៛
- ឧបាសិកា **កែន ខ៊ែត** ព្រមទាំងកូនចៅ 20000៛
- ឧបាសិកា **ខឹម តាន់** ព្រមទាំងកូនចៅ 15000៛
- ឧបាសិកា **ខាំ នាងសុខី** ព្រមទាំងកូនចៅ 15000៛
- ឧបាសិកា **សេង ឡាង** និងស្វាមី ព្រមទាំងបុត្រ 15000៛
- លោក **ឡាក់ ហោ** និងភរិយា ព្រមទាំងបុត្រ 15000៛
- ឧបាសិកា **ឈុប សុយ៉េត** ព្រមទាំងកូនចៅ 14000៛
- ពុទ្ធបរិស័ទចូលរួម 2000៛ ចំនួន ៦ នាក់ 12000៛
- ឧបាសិកា **តាំង អ៊ឹម** ព្រមទាំងកូនចៅ 10000៛

- ឧបាសក ជា ខេង និងឧបាសិកា សៀង យូលាភ 10000៛
- ឧបាសក ឆេង ហ៊ិន និងឧបាសិកា ជួប ម៉ារ៉ា ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា ស៊ីន ជឹម ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា ទៀន គង់ ព្រមទាំងកូនចៅ 10000៛
- ឧបាសក ជួរ ប៊ុនស្រេង និងឧបាសិកា ឆាម អ៊ាងជូ 10000៛
- ឧបាសិកា អៀង ណារី និងស្វាមី ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា នាង ស និងស្វាមី ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា នឹម វណ្ណី ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា ម៉ើ លោកកុយ ព្រមទាំងកូនចៅ 10000៛
- លោក ជា ស្រ៊ែង និងភរិយា ជូ យឿន 10000៛
- ឧបាសិកា ពិន ណារិន ព្រមទាំងបុត្រ 10000៛
- ឧបាសិកា ម៉ឹង សំណាង ព្រមទាំងបុត្រ 10000៛
- ឧបាសិកា ញ៉ៀម ទេពបូរី ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា ឡោ ចិនអេង និងយាយ លីយ ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា ញ៉ៀម ទេពបូរី ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា យាយ លេនតាហាម 10000៛
- ឧបាសិកា យាយ ឆាង 10000៛
- ឧបាសិកា សោម សុវណ្ណារ៉េក 10000៛
- ឧបាសិកា វង្ស ចាន់ដារ៉ា ព្រមទាំងកូនចៅ 10000៛

- ឧបាសិកា **ស្រី វង** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **ហេង សុចិន្តា**និងស្វាមី ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **ឈន អន** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **អ៊ុក គីម** ព្រមទាំងកូនចៅ 10000៛
- លោក **ពេជ អ៊ីម** និង **នូច គីមអូន** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **ណេង សោមប៊ុនយ៉ា** និងស្វាមី ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **មាន់ សាម៉ន** និង **ភា ភិន** 10000៛
- ឧបាសិកា **សឹម ផាន** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **សុខ ប៊ុនណេ** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **គីម ហ៊ន់** ព្រមទាំងបុត្រ 10000៛
- ឧបាសក **ប្រាក់ ជុំ** និងភរិយា ព្រមទាំងបុត្រ 10000៛
- ឧបាសក **នៅ ប៊ុនអេង** និងឧបាសិកា **សុខ គុន** ព្រមទាំងបុត្រ 10000៛
- ឧបាសក **ព្រុំ សាធ** និងឧបាសិកា **ខេម វឿន** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **ព្រុំ ស្រីម៉ុម** និងស្វាមី ព្រមទាំងបុត្រ 10000៛
- ឧបាសក **យ៉ា ម៉េងលាង** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **គួយ ចាន់មុនី** និង **គួយ ចេងលីសាម៉ុន** 10000៛
- ឧបាសិកា **ជុំ ម៉ុន** ព្រមទាំងកូនចៅ 10000៛
- ឧបាសក **គុច ជុន** និងឧបាសិកា **សាយ ហ៊ាង** ព្រមទាំងកូនចៅ 10000៛
- ឧបាសក **សូ អុំ** ព្រមទាំងបុត្រ 10000៛

- ឧបាសិកា **ឡាស់ ខេមវត្តី** ព្រមទាំងកូនចៅ 10000៛
- ឧបាសក **ហឹង ផុន** 10000៛
- ឧបាសក **ឈួរ ទ្រី (ហៅ សាន)** និងភរិយា ព្រមទាំងបុត្រ 10000៛
- ឧបាសក **ទូច សុន្ទ័រ** និងភរិយា ព្រមទាំងបុត្រ 10000៛
- ឧបាសក **ឈឹម សាមុត** និងភរិយា ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **ឆៅ នាង** · ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **ជ័យ យ៉េង** ព្រមទាំងបុត្រ 7000៛
- ឧបាសកតី **សំអឿន, ឈាង គឹមហេង** និងកញ្ញា **ពុធ ធីតា** 7000៛
- ឧបាសិកា **នាង ម៉ៅ** ព្រមទាំងបុត្រ 6000៛
- ឧបាសក **សាម ទ្រី** និងភរិយា ព្រមទាំងកូនចៅ 3$ +5000៛
- ឧបាសិកា **គ្មានឈ្មោះ** 5000៛
- ឧបាសិកា **គឹម យត់** 5000៛
- ឧបាសិកា **ឃ្លោក សារ៉ាន** ព្រមទាំងបុត្រ 5000៛
- ឧបាសិកា **ព្រាប សុវិ** 5000៛
- ឧបាសក **យឹម ឌុក** និងភរិយា ព្រមទាំងបុត្រ 5000៛
- ឧបាសិកា **អនាម័យ** ព្រមទាំងកូនចៅ 5000៛
- ឧបាសិកា **ជួន ខេម** ព្រមទាំងកូនចៅ 5000៛
- ឧបាសិកា **យាយ គុយទាវ** 5000៛
- ឧបាសិកា **ជាវ សុខនី** ព្រមទាំងកូនចៅ 5000៛

- ពុទ្ធបរិស័ទចូលរួម 5000៛ ចំនួន ១៥ នាក់ 75000៛
- ឧបាសិកា **គីម ឆាង** និងស្វាមី ព្រមទាំងបុត្រ 5000៛
- ឧបាសិកា **យាយ ប្រាក់ស៊ុន** 5000៛
- លោកតា **ប្រាក់ លាន** និង **ម៉ុន អាន** 5000៛
- ឧបាសិកា **លាង ស៊ីវម្មួយ** និង **ឃុន លីហេង** 5000៛
- ឧបាសិកា **ម៉ឹន សំណាង** ព្រមទាំងកូនចៅ 5000៛
- ឧបាសិកា **កេត វឿង** ព្រមទាំងកូនចៅ 5000៛
- ឧបាសិកា **សោច ឆន្ទបូ (កញ្ញា)** 4000៛
- ឧបាសក **យ៉ាន លិច** 3000៛
- ឧបាសិកា **គីម ថេង** ព្រមទាំងកូនចៅ 10000៛
- ឧបាសិកា **គីម ស្រែង** ព្រមទាំងបុត្រ 5000៛
- ឧបាសិកា **ឈុន ណៃស៊ីម** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **នៅ ហួន** ព្រមទាំងបុត្រ 5000៛
- ឧបាសិកា **ឌី ម៉ក់** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **ម៉ៅ គីមស្រ៊ុន** ព្រមទាំងបុត្រ 6000៛
- ឧបាសិកា **រស់ គីមថាន** ព្រមទាំងបុត្រ 12000៛
- ឧបាសិកា **នៅ សេងអាន** ព្រមទាំងបុត្រ 6000៛
- ឧបាសិកា **ឈុន សារុន** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **តុង គីមថាន** ព្រមទាំងបុត្រ 10000៛

- លោក **ឈឹម ធី** និងភរិយា **កែវ គីម** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **សេង សារឿន** ព្រមទាំងបុត្រ 10000៛
- ពុទ្ធបរិស័ទចូលរួម 3000៛ ចំនួន ៤ នាក់ 12000៛
- អ្នកគ្រូ **រស់ សុវណ្ណារី** ព្រមទាំងបុត្រ 10000៛
- ឧបាសក **អ៊ុង ជា** និងឧបាសិកា **ម៉ម សារ៉ុន** ព្រមទាំងកូនចៅ 10000៛
- អ្នកគ្រូ **ឈិន ពៅ** ព្រមទាំងបុត្រ 10000៛
- អ្នកគ្រូ **ស៊ូរ សុផានី** ព្រមទាំងបុត្រ 10000៛
- អ្នកគ្រូ **លឹម ចំន្ទសុវណ្ណា** ព្រមទាំងបុត្រ 5000៛
- អ្នកគ្រូ **សុខ ផល្លា** ព្រមទាំងបុត្រ 5000៛
- អ្នកគ្រូ **ស៊ុន សូម៉ាណា** ព្រមទាំងបុត្រ 10000៛
- អ្នកគ្រូ **លឹម ណារី** ព្រមទាំងបុត្រ 20000៛
- ឧបាសក **ម៉ែត ហ៊ុន** ព្រមទាំងបុត្រ 5000៛
- អ្នកស្រី **នៅ កញ្ញានា** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **លី និច** ព្រមទាំងបុត្រ 5 $
- អ្នកគ្រូ **ម៉ែន និស្ស័យជាតិ** ព្រមទាំងបុត្រ 5 $
- អ្នកគ្រូ **ឈិត សុផល** ព្រមទាំងបុត្រ 5 $
- អ្នកគ្រូ **រស់ សុវណ្ណារី** ព្រមទាំងបុត្រ 10000៛
- ឧបាសិកា **តុប សុគិនី** និងឡេង **ឡៃស៊ីន** ព្រមទាំងបុត្រ 10000៛

កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ

អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។

កាលបើលោកសន្និវាសត្រូវ ភ្លើងរាគៈ ភ្លើងទោសៈ

ភ្លើងមោហៈ ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល

អ្នកទាំងឡាយ ត្រូវងងឹត គឺអវិជ្ជា រួបរឹត ហើយ (ម្តេចឡើយ)

មិនស្វែងរកប្រទីបគឺ បញ្ញា ។